ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- មជ្ឈមណ្ឌលឯកសារកម្ពុជាគាំទ្រចំពោះការស៊ើបអង្កេតករណី០០៣និង០០៤
- ២០ ឧសភា ធ្វើឱ្យមានការចងចាំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣៧ ខែឧសភា ឆ្នាំ២០១១

ស្វែងរកការពិត

លេខ១៣៧ ខែឧសភា ឆ្នាំ២០១១

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ការស៊ើបអង្កេតត្រូវតែប្រកបដោយតម្លាភាពនិងឯករាជ្យ ........................ ១

**ផ្នែកឯកសារ**

◆ការបាត់បង់វីរបុរសជាតិ រាជ សម្បត្តិ មិនអាចទទួលយកបាន ............... ២

◆រាជ សម្បត្តិ ៖ ម្ចាស់សំឡេងដើម្បីយុត្តិធម៌ ........................................ ៣

◆រាជ សម្បត្តិ ៖ វីរបុរសនៃដួងចិត្តខ្ញុំ ................................................... ៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆វត្តឥន្ទញាណជាគុកធំរបស់ខ្មែរក្រហម ................................................ ៨

◆រណ្តៅសាកសពក្បែរវត្ត ......................................................................... ១០

◆គូជីវិតរបស់ខ្ញុំ ........................................................................................ ១១

◆ថ្ងៃ២០ឧសភា ធ្វើឲ្យមានការចងចាំ ......................................................... ១៤

◆ទិវាដើម្បីចងចាំ និងការអប់រំ ................................................................ ១៦

◆ពិព័រណ៍យុវជនសម្រាប់លទ្ធិប្រជាធិបតេយ្យ .................................... ១៨

◆បន្ទំចិត្តស៊ើចនៅពេលឃើញខ្មែរក្រហមធ្វើទារុណកម្មឪពុក .................. ២០

◆ប្រវត្តិសាស្ត្រសម្រាប់អ្នកទាំងអស់គ្នា ............................................... ២២

◆អតីតទាហានខ្មែរក្រហមតស៊ូក្នុងជីវិតបីងអំពិល ................................ ២៤

◆ពិព័រណ៍រូបថត “ថ្ងៃ១៧មេសា” ................................................................ ២៦

**ផ្នែកច្បាប់**

◆សវនាការលើបណ្តឹងសាទុក្ខប្រឆាំងនឹងការកាត់ទោស ឌុច ................ ២៨

**វេទិកាពិភាក្សាសាធារណៈ**

◆បណ្តឹងឧទ្ធរណ៍របស់ ការ៉ុង ហ្គេកអ៊ាវ ............................................ ៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆គេចខ្លួនដើម្បីរស់ ...................................................................................... ៥៥

◆ជីវិតម្តាយខ្ញុំក្នុងរបបខ្មែរក្រហម ............................................................ ៥៦

◆ការបែកបាក់ក្នុងរបបខ្មែរក្រហម ............................................................ ៥៩

◆ដំណឹងស្វែងរក អៀត អ៊ិត ....................................................................... ៦០




ទិវាចងកំហឹង ២០ឧសភា នៅវាលពិឃាតជើងឯក

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** កែ មុនផិត, វ៉ាន់ថាន់ ពៅដារ៉ា, ហ៊ិន សុធានី, ទែន សុខស្រីនិត, ស សេងគា, លី សុខចំរើន, ស៊ីរិ សាវីណា, អាន ហាញឌល, ឆាល ចេកសាន់, លឹម ជ័យទត្ត និង សើ សាយ្យាណា ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា ***អ្នកបកប្រែ ៖*** ដា ដល្លា ***និពន្ធនាយកទូទៅ ៖*** ឆាំង យុ ***ជំនួយការនិពន្ធនាយក ៖*** ញាណ សុជាតិ ***ក្រាហ្វិកកុំព្យូទ័រ ៖*** ស៊ឹម សុភ័ក្ត្រ ***គ្រប់គ្រងការចែកផ្សាយ ៖*** ម៉ម សុដាត

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ការស៊ើបអង្កេតត្រូវតែប្រកបដោយតម្លាភាពនិងឯករាជ្យភាព

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមសម្តែងនូវចំណាប់អារម្មណ៍ចំពោះដំណើរការវិវឌ្ឍន៍ថ្មីៗស្តីអំពីការស៊ើបអង្កេតករណី០០៣ និង០០៤ នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដំណើរការដែលប្រកបទៅដោយឯករាជ្យភាពនិងតម្លាភាពរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាកិច្ចការមិនអាចខ្វះបាន ប្រសិនបើប្រជាជនកម្ពុជានិងត្រូវទទួលបានភាពយុត្តិធម៌ចំពោះអំពើព្រៃផ្សៃដែលខ្លួនបានទទួលរងក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

កាលពីថ្ងៃទី២៩ ខែមេសា កន្លងទៅ សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាបានធ្វើការប្រកាសយ៉ាងប្រញាប់ប្រញាល់អំពីការបិទដំណើរការស៊ើបអង្កេតចំពោះករណី០០៣ ។ ការប្រកាសជាសាធារណនោះមិនបានរៀបរាប់អំពីបទឧក្រិដ្ឋដែលបានធ្វើការស៊ើបអង្កេតរួចមកហើយទេ ទោះបីជាជនរងគ្រោះដែលទទួលរងនូវការធ្វើទុក្ខបុកម្នេញដោយបុព្វហេតុនោះផ្ទាល់ មានរយៈពេល១៥ថ្ងៃដើម្បីចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការក្តីនាថ្ងៃអនាគត ។ ការិយាល័យកិច្ចការសាធារណៈមិនបានធ្វើការពន្យល់ដល់ប្រជាជនកម្ពុជាទូទៅអំពីអត្ថន័យនិងផលលំបាកនៃដំណើរការវិវឌ្ឍន៍នេះនៅឡើយទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាប្តូរផ្តាច់និងបម្រើគោលដៅទាំងពីររបស់ខ្លួនគឺការចងចាំនិងយុត្តិធម៌ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាឃ្លាំងស្តុកឯកសារទាក់ទងនិងរបបខ្មែរក្រហមដ៏ធំបំផុតនៅលើពិភពលោក មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជំនួយនិងការគាំទ្រដល់ដំណើរការស្វែងរកការទទួលខុសត្រូវរបស់សាលាក្តីខ្មែរក្រហមតាំងពីស្ថាប័ននេះចាប់ដំណើរការដំបូងមកម្ល៉េះ ។ ប្រជាជនកម្ពុជាដែលរួចរស់ជីវិតពីរបបខ្មែរក្រហមរាប់លាននាក់សមនឹងទទួលបានព័ត៌មានថាតើសាលាក្តីខ្មែរក្រហមកំពុងធ្វើអ្វីដើម្បីបម្រើផលប្រយោជន៍ខ្លួនដែលជាជនរងគ្រោះ ប៉ុន្តែសាលាក្តីខ្មែរក្រហមមិនបានផ្តល់ព័ត៌មានដ៏មានអត្ថន័យណាមួយដល់សាធារណជនអំពីករណី០០៣និង០០៤ទេ ចាប់តាំងពីសហចៅក្រមស៊ើបអង្កេតចាប់ផ្តើមដំណើរការស៊ើបអង្កេតរបស់ខ្លួនតាំងពី២០ខែកន្លងមកហើយយ៉ាងណាក្តី ។

ក្នុងនាមជាស្ថាប័នដែលមានជំនឿលើភាពស្របច្បាប់របស់ដំណើរការសាលាក្តីខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាគោរពនូវភាពលាក់ការណ៍នៃដំណើរការស៊ើបអង្កេតរបស់តុលាការ ។ ជាមួយគ្នានោះដែរ យើងនៅតែចង់ដឹងហេតុការណ៍ប្រវត្តិសាស្ត្រពិតទាក់ទងទៅនិងបទឧក្រិដ្ឋដែលប្រព្រឹត្តិឡើងដោយរបបខ្មែរក្រហមរួមទាំងអ្នកដែលនិងត្រូវស៊ើបអង្កេតសម្រាប់ករណី០០៣និង០០៤ ព្រមទាំងដើម្បីប្រមូលឯកសារដែលនិងអាចប្រើប្រាស់បាននៅក្នុងដំណើរការច្បាប់នេះផង ។

យើងរំពឹងថាសាលាក្តីខ្មែរក្រហមនិងមានដំហរប្រកបទៅដោយបទដ្ឋានខ្ពស់បំផុតនៃឯករាជ្យភាពខាងផ្លូវច្បាប់របស់ខ្លួន ។ រាល់សេចក្តីសម្រេចទាំងអស់របស់សាលាក្តីខ្មែរក្រហមត្រូវតែធ្វើឡើងដោយឯករាជ្យពីសម្ពាធនយោបាយ និងអនុលោមតាមការបកស្រាយដ៏ច្បាស់លាស់របស់វិធានតុលាការ ។ លើសពីនេះទៅទៀត យើងសូមស្នើថា តុលាការជម្រាបដំណឹងដល់ប្រជាជនកម្ពុជាឲ្យបានគ្រប់គ្រាន់អំពីដំណើរកិច្ចការងាររបស់ខ្លួន ។ **ឆាំង យុ**

# ការបាត់បង់វីរបុរសជាតិ រាជ សម្បត្តិ មិនអាចទទួលយកបាន



រាជ សម្បត្តិ

កាលពីយប់ថ្ងៃពុធ ទី១១ ខែឧសភា ឆ្នាំ២០១១ ខ្ញុំទទួលបានសារមួយក្នុងទូរស័ព្ទរបស់ខ្ញុំពីលោកស្រី អែម សុខឃីម ដែលធ្វើការនៅផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបញ្ជាក់ថាលោក រាជ សម្បត្តិ បានទទួលមរណភាពហើយ ។ ខ្ញុំដឹងថា សុខឃីម កំពុងតែយំពេលដែលគាត់កំពុងសរសេរសារនេះមកខ្ញុំ ។ ខ្ញុំក៏បានសរសេរសារខ្លីមួយឆ្លើយតបទៅគាត់វិញដែរ ហើយខ្ញុំក៏ត្រឡប់ទៅគេងវិញដោយបន្ទប់ខ្លួនឯងថា ដំណឹងនេះគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ ។

ព្រឹកឡើង ខ្ញុំបានប្រាប់ទៅលោកនាយករង វ៉ាន់ថាន់ពោដារ៉ា ឲ្យរៀបចំប្រាប់បុគ្គលិកទាំងអស់ឲ្យទៅចូលរួមពិធីបុណ្យសពលោក រាជ សម្បត្តិ ដើម្បីគោរពទៅដល់វិញ្ញាណក្ខន្ធរបស់គាត់ ។ ខ្ញុំមិនបានទៅចូលរួមក្នុងពិធីបុណ្យនៅថ្ងៃនោះទេដោយបន្ទប់ខ្លួនឯងថា ខ្ញុំកំពុងតែជាប់រវល់ការងារនៅការិយាល័យ ។

ដំណឹងពីមរណភាពរបស់លោក រាជ សម្បត្តិ ត្រូវបានមហាជនក្នុងនិងក្រៅប្រទេសដឹងឮជាទូទៅ ប៉ុន្តែខ្ញុំនៅតែបន្ទប់ខ្លួនឯងថា ដំណឹងនេះគ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ ។ ដំណឹងនេះមិនពិតទេ ។

ពេលដែលខ្ញុំអានអត្ថបទមួយសរសេរដោយលោក កែ មុនធិត ចុះផ្សាយក្នុងសារព័ត៌មានមួយដែលមានចំណងជើងថា «ពេលកំពុងមានទុក្ខ នឹកឃើញដល់អនុស្សាវរីយ៍ជាមួយលោក រាជ សម្បត្តិ ធ្វើឲ្យយើងញញឹម» ទឹកភ្នែកខ្ញុំស្រក់យ៉ាងខ្លាំងដោយសារតែខ្ញុំស្គាល់អ្នកទាំងពីរយ៉ាងច្បាស់ និងជិតស្និទ្ធយ៉ាងខ្លាំង ។

អ្នកទាំងពីរមិនដែលកុហកខ្ញុំទេ ហើយក៏មិនដែលកុហកសាធារណជនដែលខ្លួនកំពុងបម្រើដែរ ។ ខ្ញុំមិនមានហេតុផលអ្វីនឹងកុហកខ្លួនឯងតទៅទៀតទេ ឬធ្វើការបន្ទប់ខ្លួនឯងថា មរណភាពរបស់លោក រាជ សម្បត្តិ ជារឿងមិនពិតដែរ ។ ខ្ញុំពិតជាមិនអាចទទួលយកដំណឹងដ៏អកុសលបែបនេះបានទេ ។

ខ្ញុំបានសុំឲ្យ មុនធិត ផ្ញើអត្ថបទដែលគាត់សរសេរមកខ្ញុំតាមរយៈអ៊ីម៉ែល ហើយខ្ញុំចង់ប្រាប់ពិភពលោកថា យើងនៅតែអាចសើចសប្បាយជាមួយគ្នាបន្តទៀត ។

ប៉ុន្តែទឹកភ្នែកខ្ញុំនៅតែស្រក់ ។ មុនធិត បានប្រាប់ខ្ញុំឲ្យដូរចំណងជើងថ្មី ព្រោះអត្ថបទដែលគាត់ផ្ញើមកខ្ញុំត្រូវបានចុះក្នុងសារព័ត៌មាន ឌឹ ខេមបូឌា ដេលី រួចហើយ ។ ខ្ញុំក៏ដូរចំណងជើងអត្ថបទនេះថា «រាជ សម្បត្តិ ៖ វីរបុរសនៃដួងចិត្តខ្ញុំ» ។

ទឹកភ្នែកខ្ញុំស្រក់កាន់តែខ្លាំងពេលដែលកំពុងសរសេរសំបុត្រខ្លីមួយនេះ ហើយខ្ញុំនៅតែមិនអាចឈប់សោកស្តាយបានទេត្រង់ថា ខ្ញុំមិនបានញ៉ាំអាហារឆ្ងាញ់មួយពេលជាមួយ សម្បត្តិ បានទោះបីជាគាត់អញ្ជើញខ្ញុំជាច្រើនលើកច្រើនសាជាយូរឆ្នាំមកហើយក៏ដោយ ។

ខ្ញុំតែងតែរក្សាគម្លាតពីគាត់តាំងពីគាត់ក្លាយជាអ្នកសារព័ត៌មានមក ព្រោះខ្ញុំជាអ្នកស្រាវជ្រាវរកឯកសារដើម្បីនាំយកខ្មែរក្រហមមកកាត់ទោស ។ ខ្ញុំខ្លាចមានការប៉ះពាល់ដល់ការស្រាវជ្រាវដើម្បីប្រទេសជាតិរបស់ខ្ញុំ ប៉ុន្តែទីបញ្ចប់ ខ្ញុំមិនបានទទួលយកសំណើពីមិត្តល្អម្នាក់របស់ជាតិខ្ញុំ ។

ឥឡូវនេះ ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ។ ខ្ញុំបានទៅចូលរួមបុណ្យសពនៅផ្ទះគាត់កាលពីថ្ងៃសៅរ៍ ហើយខ្ញុំអង្គុយសញ្ជឹងក្នុងសភាពស្ងៀមស្ងាត់អស់ជាច្រើនម៉ោង ។ ខ្ញុំមិនដឹងរកពាក្យអ្វីនឹងនិយាយទៅកាន់ប្រពន្ធនិងកូនរបស់គាត់ទេ ។ ខ្ញុំនៅតែមិនអាចទទួលយកការពិតបានត្រង់ថា គាត់នឹងមិនអាចនៅជាមួយយើងតទៅទៀតបាន ។ គាត់គឺជាវីរបុរសនៃដួងចិត្តខ្ញុំ ។ **ឆាំង យុ**

# រាជ សម្បត្តិ : ម្ចាស់សំឡេងដើម្បីយុត្តិធម៌

ប្រសិនបើយើងនឹកឃើញដល់សាលាក្ដីខ្មែរក្រហម យើងនឹងគិតដល់លោក រាជ សម្បត្តិ ។ ប៉ុន្ដែចាប់ពីពេលនេះតទៅ យើងនឹងមិនអាចឮសម្ដីរបស់គាត់ និងឃើញគាត់នៅក្នុងទូរទស្សន៍ទៀតឡើយ ។ លោក រាជ សម្បត្តិ បានទទួលមរណភាពកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ ក្នុងជន្មាយុ៤៧ឆ្នាំ ។ លោក រាជ សម្បត្តិ បានធ្វើកិច្ចការជាច្រើនយ៉ាង ។ គាត់គឺជាសាស្ត្រាចារ្យផ្នែកសារព័ត៌មាននិងទំនាក់ទំនងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាប្រធានផ្នែកកិច្ចការសាធារណៈនៃសាលាក្ដីខ្មែរក្រហម និងជាអ្នកសារព័ត៌មានមួយរូបដែលបានធ្វើការពេញមួយជីវិតរបស់គាត់ដើម្បីធ្វើឲ្យប្រសើរឡើងនូវវិស័យសារព័ត៌មានក្រោយពីប្រទេសជាតិទទួលរងនូវភាពខ្ទេចខ្ទាំដោយសង្រ្គាមនិងអំពើប្រល័យពូជសាសន៍ ។ លោក រាជ សម្បត្តិ បានលាចាកលោកនេះទៅដោយបន្សល់នូវភរិយានិងកូនបីនាក់ និងនិស្សិតសារព័ត៌មានជាច្រើននាក់ដែលកំពុងចាំក្រេបយកចំណេះដឹងពីគាត់ ។

ពេញមួយជីវិតរបស់គាត់ លោក រាជ សម្បត្តិ បានខិតខំតស៊ូយ៉ាងស្វិតស្វាញដើម្បីជីវិតរស់ និងដើម្បីស្វែងរកយុត្តិធម៌ ។ លោកកើតនៅឆ្នាំ១៩៦៤ នៅខេត្តស្វាយរៀង ។ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ទើបតែមានអាយុ១១ឆ្នាំប៉ុណ្ណោះ ។ នៅថ្ងៃនោះហើយដែលឪពុករបស់គាត់ដែលជាប្រធានស្រុកត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។ ភ្លាមៗនោះ លោក រាជ សម្បត្តិ ត្រូវបានជម្លៀសឲ្យទៅនៅខេត្តបាត់ដំបងជាមួយបងប្រុសរបស់គាត់ឈ្មោះ រាជ សំណាង ។ រីឯម្ដាយនិងបងប្អូនបង្កើតផ្សេងទៀតត្រូវបានជម្លៀសឲ្យទៅនៅទីកន្លែងផ្សេង ។ លោកនិងបងប្រុសរបស់លោកបានរួចរស់ជីវិត តែម្ដាយនិង




រាជ សម្បត្តិ ជាមួយចាមមូស្លីមនៅពីមុខអគារសាលាក្ដីខ្មែរក្រហម

បងប្អូនផ្សេងទៀតមិនមានឱកាសនិងរស់រានមានជីវិតទេ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ លោក រាជ សម្បត្តិ ដែលជាក្មេងកំព្រា បានផ្លាស់ប្តូរទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀតដើម្បីរកស៊ីចិញ្ចឹមជីវិតមុនពេលដែលគាត់មកដល់ទីក្រុងភ្នំពេញនិងបានចូលរៀននៅសាលាភ្នំដូនពេញ (បច្ចុប្បន្នវិទ្យាល័យព្រះស៊ីសុវត្ថិ) ។

លោក ពុយ គា ដែលបានរៀននៅសាលាភ្នំដូនពេញបានឲ្យដឹងថាលោក រាជ សម្បត្តិ ជាមនុស្សឆ្លាត ហើយគាត់ចេះនិយាយភាសាអង់គ្លេសបាន ។ គា បានស្គាល់លោក រាជ សម្បត្តិ តាំងពីឆ្នាំ១៩៨៥ នៅពេលលោក រាជ សម្បត្តិ បង្រៀន



រាជ សម្បត្តិ ធ្វើការណែនាំដល់និស្សិតក្នុងបរិវេណសាលាក្តីខ្មែរក្រហម




រាជ សម្បត្តិ ពេលធ្វើសន្និសីទសារព័

ភាសាអង់គ្លេសនៅផ្ទះតូចមួយខាងក្រោយព្រះបរមរាជវាំងដែលពេលនោះការរៀនភាសាអង់គ្លេសមិនមានការអនុញ្ញាតិឡើយ ។ គា បានរំឭកថា នៅពេលនោះគាត់និងលោក រាជ សម្បត្តិ មានភាពជិតស្និទ្ធនឹងគ្នា ហើយ សម្បត្តិ មិនឲ្យគាត់បង់ប្រាក់ថ្លៃរៀនភាសាអង់គ្លេសទេ ។ គា បាននិយាយថា «សម្បត្តិ បានឲ្យខ្ញុំដើរប្រមូលប្រាក់ពីសិស្ស ហើយគាត់មិនបានឲ្យខ្ញុំបង់ប្រាក់ទេ» ។

នៅឆ្នាំ១៩៨៨ លោក រាជ សម្បត្តិ ទទួលបានអាហារូបករណ៍ទៅសិក្សាផ្នែកកសិកម្មនៅប្រទេសឥណ្ឌា ទោះបីជាគាត់មិនសូវជាចាប់អារម្មណ៍នឹងមុខជំនាញនេះក៏ដោយ ។ នៅឆ្នាំ១៩៩២ គាត់បានត្រឡប់មកវិញ និងចាប់ផ្តើមធ្វើការនៅភ្នាក់ងារសារព័ត៌មាន បារាំង អា អេហ្វ ប៉េ ក្នុងខណៈពេលដែលប្រទេសស្ថិតនៅក្នុងភាពចលាចលនៃសង្គ្រាមស៊ីវិលនៅឡើយ ។ គាត់បានធ្វើសេចក្តីរាយការណ៍សម្រាប់សារព័ត៌មាន អា អេហ្វ ប៉េ នាអំឡុងពេលបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ការបោះឆ្នោតនៅឆ្នាំ១៩៩៣ ហេតុការណ៍ក្រោយបោះឆ្នោត ការប៉ះទង្គិចផ្នែកនយោបាយនៅឆ្នាំ១៩៩៧ និងព្រឹត្តិការណ៍ក្រោយៗទៀត ។

គា ដែលបច្ចុប្បន្នជាអ្នកកាសែត និងជាមិត្តរួមការងាររបស់លោក រាជ សម្បត្តិ មានអនុស្សាវរីយ៍យ៉ាងជូរចត់ជាមួយគ្នា ។ គា បានរំឭកពីបទពិសោធន៍កាលទៅស្រុកម៉ាឡៃ និងអន្លង់វែងជាមួយគ្នាខណៈពេលដែលតំបន់ទាំងពីរនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឡើយ ។ គា បាននិយាយថា មានពេលមួយនៅអន្លង់វែង អាគុយរបស់ឧទ្ធម្ភាគចក្រអស់ភ្លើង អ្នកជិះទាំងអស់បានហៅឡានយោធាមកបញ្ចូលអាគុយ ដើម្បីឲ្យឧទ្ធម្ភាគចក្រដំណើរការបាន ។ ប៉ុន្តែក្រោយពីឧទ្ធម្ភាគចក្រដំណើរការហើយនៅតែមិនអាចហោះបាន ពីព្រោះមានមនុស្សនៅក្នុងនោះច្រើនពេក ។ ហោះឡើងលើបានបន្តិច ឧទ្ធម្ភាគចក្រនោះបានចុះមកវិញ ។ ពីរបីដងក្រោយមកទើបឧទ្ធម្ភាគចក្រអាចហោះឡើងបាន ។ គា បានបន្តទៀតថា មានពេលមួយទៀតនៅពេលដែលគាត់ហើយនិងលោក រាជ សម្បត្តិ កំពុងធ្វើដំណើរដោយរថយន្តយោធា

គ្រាប់ផ្លោងរបស់ខ្មែរក្រហមបានធ្លាក់នៅក្បែររថយន្តនោះ ។

លោក ឡាក់ ហាន់ ដែលបានចូលធ្វើការនៅភ្នាក់ងារសារព័ត៌មាន អា អេហ្វ ប៉េ បានសរសេរថា «ក្នុងនាមជាអ្នកយកការណ៍ក្នុងអំឡុងពេលមានសង្គ្រាម សម្បត្តិ គឺជាអ្នកសារព័ត៌មានដែលក្លាហានជាងគេបង្អស់» ។ គាត់ បានឲ្យដឹងថាដោយសារតែភាពក្លាហាននោះហើយ ដែលលោក រាជ សម្បត្តិ ត្រូវបានអ្នកសារព័ត៌មានចាត់ទុកថាជាអាត់មួយ «ក្នុងចំណោមអាត់ទាំងបួន» ក្នុងវិស័យសារព័ត៌មានដែលក្នុងនោះក៏មានលោក កែ មុនធិត ដែរ ។ មុនធិត និងលោក រាជ សម្បត្តិ បានស្គាល់គ្នាតាំងពីឆ្នាំ១៩៩២ ហើយអ្នកទាំងពីរបានទៅបន្តការសិក្សានៅសាកលវិទ្យាល័យកូឡុំបៀ



័ត៌មាន


រាជ សម្បត្តិ កំពុងនាំជនរងគ្រោះចូលបន្ទប់សវនាការ

ជាមួយគ្នាពីឆ្នាំ២០០០ដល់២០០១ ។

ក្នុងនាមជាមិត្តរួមបន្ទប់ជាមួយគ្នា មុនធិត ស្គាល់លោក រាជ សម្បត្តិ យ៉ាងច្បាស់ ។ មុនធិត បាននិយាយថា «សម្បត្តិ គឺជាសិស្សដែលមានការតាំងចិត្តខ្ពស់ ។ កិច្ចការសាលារបស់គាត់មិនដែលយឺតពេលទេ» ។ បន្ទាប់ពីមកដល់ប្រទេសកម្ពុជាវិញ មុនធិត បានទៅធ្វើការនៅភ្នាក់ងារសារព័ត៌មាន អេ.ភី រីឯលោក រាជ សម្បត្តិ ចាប់ផ្តើមការងាររបស់គាត់ឲ្យសារព័ត៌មាន អា អេហ្វ ប៉េ នៅឆ្នាំ ២០០២ ។

មួយឆ្នាំក្រោយមក លោក រាជ សម្បត្តិ បានទៅធ្វើជាសាស្ត្រាចារ្យផ្នែកសារព័ត៌មាននិងទំនាក់ទំនងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ ។ នៅដើមឆ្នាំ២០០៦ លោក រាជ សម្បត្តិ ចាប់ផ្តើមធ្វើការជាអ្នកនាំពាក្យនៅសាលាក្តីខ្មែរក្រហម ហើយនៅខែមិថុនាឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជាប្រធានកិច្ចការសារធារណៈរបស់សាលាក្តីខ្មែរក្រហមរហូតដល់ថ្ងៃដែលគាត់ស្លាប់ ។

និស្សិត មិត្តរួមការងារ និងមិត្តភក្តិរបស់លោក រាជ សម្បត្តិ មានសេចក្តីសោកស្តាយយ៉ាងខ្លាំង ដែលលោកបានលាចាកលោកភ្លាមៗដូច្នេះ ។ លោក ទៀង សុភវិជ្ជា ប្រធានផ្នែកសារព័ត៌មាននិងទំនាក់ទំនងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញបាននិយាយថា «លោក រាជ សម្បត្តិ គឺជាសាស្ត្រាចារ្យដ៏ល្អម្នាក់ដែលបានជួយជំរុញអភិវឌ្ឍវិស័យសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាឲ្យមានភាពប្រសើរជាងមុន ។ គាត់ជាមនុស្សដែលមានសមត្ថភាពផ្នែកសារព័ត៌មាន ។ ការបាត់បង់រូបគាត់គឺជាការបាត់បង់ដ៏ធំមួយ» ។

គាត់ មានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះការស្លាប់របស់លោក រាជ សម្បត្តិ ។ គាត់បាននិយាយថា «ការស្លាប់របស់លោក រាជ សម្បត្តិ គឺជាការបាត់បង់ធនធានមនុស្សដ៏កម្រកបានមួយនៅក្នុងប្រទេស ពីព្រោះគាត់គឺជាអ្នកកាសែតជើងចាស់ដែលអ្នកផ្សេងទៀតកម្រធ្វើបានដូចគាត់ណាស់ ។ គាត់បានបូជាកម្លាំងកាយនិងចិត្តដើម្បីបំពេញកិច្ចការផ្នែកសារព័ត៌មាន» ។

**ញាណ សុជាតិ**

# រាជ សម្បត្តិ : ទីរបុរសនៃដួងចិត្តខ្ញុំ

សប្តាហ៍នេះ ប្រជាជនកម្ពុជា ក៏ដូចជាជនបរទេសជាច្រើន មានភាពទុក្ខសោកឥតឧបមាពេលដែលបានមកចូលរួមបុណ្យសពរបស់លោក រាជ សម្បត្តិ ដែលជាមិត្តជាទីស្រឡាញ់របស់យើង ។ មរណភាពរបស់ សម្បត្តិ បានធ្វើឲ្យយើងមានការឈឺចាប់ផ្លូវចិត្ត ហើយចម្ងល់នៅតែតាមលងយើងថាតើនេះគឺជាការពិតដែរឬទេ? យើងទាំងអស់គ្នាបានបាត់បង់អ្នកសារព័ត៌មានដ៏កម្រម្នាក់ជាអ្នកបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មានមួយរូបជាមិត្តភក្តិដ៏ជិតស្និទ្ធម្នាក់និងជាអ្នកស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមម្នាក់នៅក្នុងប្រទេសកម្ពុជា ។


រាជ សម្បត្តិ ធ្វើការណែនាំដល់និស្សិតក្នុងបន្ទប់សវនាការ

ខ្ញុំបានស្គាល់ សម្បត្តិ នៅឆ្នាំ១៩៩២ ដែលនៅពេលនោះ ប្រទេសកម្ពុជានៅមិនទាន់មានស្ថេរភាពនៅឡើយទេ ។ កាលនោះ យើងទាំងពីរនាក់គឺជាអ្នកសារព័ត៌មានថ្មីថ្មោងដែលកំពុងតែខិតខំត្រងត្រាប់វិជ្ជាជីវៈរបស់ខ្លួន ហើយយើងបានតាមដានរកព័ត៌មានធំ តូចនិងពិសេសៗ និងជាអ្នកកាសែតដែលព្យាយាមរក «ព័ត៌មានថ្មីនិងទាន់ហេតុការណ៍» ។ សម្បត្តិ តែងតែជួយមនុស្សគ្រប់ៗគ្នារួមទាំងខ្ញុំផងដែរ ។ ខណៈពេលដែលពេលវេលាចេះតែដើរទៅមុខ មិត្តភាពរបស់យើងទាំងពីរកាន់តែមានភាពល្អឡើង ទាំងផ្នែកការងារនិងជាលក្ខណៈបុគ្គល ។ ខ្ញុំរំពឹងថា ខ្ញុំនឹងអាចរំឭករឿងរ៉ាវគ្រប់យ៉ាងដែលយើងបានសាងរួមគ្នានៅពេលយើងធ្វើការជាមួយគ្នា ប៉ុន្តែដោយខ្ញុំមានការលំបាកក្នុងការសរសេររឿងរ៉ាវទាំងអស់នោះ ខ្ញុំសូមលើកឡើងតែចំណុចខ្លះៗប៉ុណ្ណោះ ។

កាលពីចុងខែមិនាឬដើមខែមេសា ឆ្នាំ១៩៩៨ នៅពេលដែលទាហានរដ្ឋាភិបាលវាយយកបានទីក្រុងប៉ៃលិនពីកងខ្មាំងខ្មែរក្រហម សម្បត្តិ ហើយនិងខ្ញុំបានទៅជាមួយអ្នកកាសែតនិងយោធាបរទេសមួយក្រុមដោយដើរកាត់ព្រៃដ៏ក្រាស់ពីខេត្តបាត់ដំបងទៅក្រុងប៉ៃលិន ។ យើងទាំងអស់គ្នាចង់មើលឃើញជ័យជម្នះរបស់ទាហានរដ្ឋាភិបាលដោយផ្ទាល់ភ្នែកដើម្បីរាយការណ៍ទៅឲ្យអង្គភាពរបស់យើង ។ ពេលរសៀលចូលមកដល់ ប៉ៃលិនដែលជាគោលដៅរបស់យើងឋិតនៅក្នុងសភាពដាច់កន្ទុយភ្នែកនៅឡើយ ។ យើងទាំងអស់គ្នាទទឹកជោគនិងអាកាសធាតុមានសភាពត្រជាក់ ។ នៅពេលដែលយើងឈប់សម្រាកបោះតង់នៅពេលយប់ខ្ញុំបានព្យាយាមគាស់កំប៉ុងត្រីខដើម្បីយកមកបរិភោគជាមួយនំបុ័ងសម្រាប់អាហារពេលល្ងាច ។ ចៃដន្យខ្ញុំរអិលដៃ ហើយដៃរបស់ខ្ញុំក៏មុត ។ សម្បត្តិ បានប្រាប់ខ្ញុំថា «មុនផិតឯងនោមដាក់របួសនោះទៅ ដើម្បីកុំឲ្យឈាមហូរ» ។ ខ្ញុំបានធ្វើតាមគាត់ ហើយឈាមក៏ឈប់ហូរមែន ។ បន្ទាប់ពីទទួលទានអាហារពេលល្ងាចរួច យើងបានដេកនៅលើក្នុងអង្រឹងរបស់យើងដែល

ចងនៅចន្លោះដើមឈើ ។ នៅពេលនោះ សម្បត្តិ បានយកអង្រឹងរបស់គាត់ពីផ្ទះ ប៉ុន្តែខ្ញុំត្រូវជួលអង្រឹងពីប្រពន្ធរបស់ទាហានម្នាក់សម្រាប់មួយយប់ដែលមានតម្លៃ១៥ដុល្លារ ។ តម្លៃនោះពិតជាថ្លៃណាស់ ប៉ុន្តែខ្ញុំមិនមានជម្រើសអ្វីផ្សេងទៀតឡើយ ។ យប់នោះខ្ញុំរងាខ្លាំងណាស់ ។ សម្បត្តិ ក៏បានណែនាំខ្ញុំ «ឲ្យដាក់ដៃទាំងពីរចូលទៅក្នុងខោនិងចន្លោះភ្លៅដើម្បីឲ្យកក់ក្តៅ» ។ ខ្ញុំបានធ្វើតាមគាត់ ហើយវិធីនេះពិតជាមានប្រសិទ្ធភាពមែន ។ យប់នោះខ្ញុំក៏ដេកលក់ទៅ ។ នៅព្រលឹមស្រាងៗ យើងបានក្រោកឡើង និងរៀបចំឥវ៉ាន់ដើម្បីបន្តដំណើរទៅប៉ៃលិនដោយថ្មើរជើង ។ នៅក្នុងព្រៃ យើងបានជួបប្រទះសព្វាវុធ គ្រាប់កាំភ្លើង និងគ្រាប់រ៉ុកកែតដែលគេបោះបង់ចោលជាច្រើន ។ យើងប្រហែលជាន់មីនផងក៏មិនដឹង ពីព្រោះទីនោះគឺជាទីតាំងសមរភូមិប្រយុទ្ធ ប៉ុន្តែសំណាងល្អយើងទាំងអស់គ្នាបានទៅដល់គោលដៅដោយសុវត្ថិភាព ។ យើងទៅដល់ទីនោះដោយអស់កម្លាំងជាខ្លាំង បន្ទាប់ពីធ្វើដំណើរអស់រយៈពេល១២ម៉ោង ។ នៅថ្ងៃបន្ទាប់ យើងបានភ្ញាក់ពីដំណេកដើម្បីសង្កេតមើលទិដ្ឋភាពតំបន់ប៉ៃលិន និងធ្វើរបាយការណ៍ ។

មិនដែលខ្វះរឿងរ៉ាវសំខាន់ៗក្នុងការយកមកសរសេរទេ ។ មានរឿងមួយនោះគឺការធ្វើបាតុកម្មប្រឆាំងនឹងការចាក់កាកសំណល់ពុលនៅក្រុងព្រះសីហនុ (បច្ចុប្បន្នខេត្តព្រះសីហនុ) នៅខែធ្នូ ឆ្នាំ១៩៩៨ ។ ប្រជាជននៅតំបន់នោះមានភាពភ័យខ្លាចចំពោះផលប៉ះពាល់ទៅលើសុខភាពរបស់ខ្លួនដែលបណ្តាលមកពីកាកសំណល់ពុលនោះ ។ ប្រជាជនជាច្រើនបានដើរជាក្បួនធ្វើបាតុកម្មនៅក្នុងក្រុង ។ យើងបានដើរតាមអ្នកទាំងនោះទៅគ្រប់កន្លែងដើម្បីធានាថាយើងបានតាមដានគ្រប់ហេតុការណ៍ដែលកំពុងកើតឡើង ។ នៅពេលដែលក្រុមបាតុករទៅដល់ផ្ទះរបស់មន្ត្រីជាន់ខ្ពស់ម្នាក់នៅទីនោះ បុរសម្នាក់បាញ់កាំភ្លើងឡើងលើជាច្រើនគ្រាប់ ។ សំឡេងកាំភ្លើងនោះឮយ៉ាងកងរំពង ។ ក្រុមមនុស្សបានរត់ចេញខ្ចាត់ខ្ចាយដើម្បីរស់ រីឯខ្ញុំនឹង សម្បត្តិ បានឡើងម៉ូតូឌុបដើម្បីរត់គេច ។ នៅពេលទៅដល់ការិយាល័យរដ្ឋាភិបាលមួយដែលនៅឆ្ងាយពីកន្លែងបាញ់កាំភ្លើងនោះ យើងបានឈប់ដើម្បីសម្រួលដង្ហើម ។ សម្បត្តិ មិនដឹងថាសម្លៀកបំពាក់របស់គាត់មានបញ្ហាអ្វីទេនៅពេលដែលគាត់រត់ដើម្បីសុវត្ថិភាពនោះ ។ ក្រោយមកនៅពេលដែលគាត់អង្គុយទើបគាត់ដឹងថាគូថខោរបស់គាត់រហែកដែលធ្វើឲ្យលេចខោក្នុងរបស់គាត់ ។ ក្រោយពីភ័យមួយសន្ទុះ យើងបានសើចទាំងអស់គ្នា ។

វាប្រហែលជាចម្លែកដែលនិយាយអំពីសាច់រឿងល្អសើចនៅក្នុងស្ថានភាពទុក្ខព្រួយក្នុងពេលនេះ ។ ប៉ុន្តែខ្ញុំចង់ចែករំលែករឿងរ៉ាវឲ្យរសាយចិត្តបន្តិចដែលខ្ញុំធ្លាប់មានជាមួយ សម្បត្តិ ។ ខណៈពេលដែលយើងស្តាយស្រណោះគាត់ យើងក៏អាចរំឭកនូវសមិទ្ធផលរបស់គាត់ដោយចងក្រងរឿងរ៉ាវធំនិងតូចដែលយើងបានឆ្លងកាត់ជាមួយគាត់ ។ រឿងរ៉ាវនោះនឹងនៅជាមួយយើងជារឿងរហូតនិងរំឭកយើងពីបុរសម្នាក់ដែលចិត្តសប្បុរស ទូលាយនិងភាពស្មោះត្រង់របស់គាត់បានជះឥទ្ធិពលដល់មនុស្សជាច្រើនដូចជាអ្នកនយោបាយ មិត្តភក្តិ អ្នកសារព័ត៌មាន សិស្ស និងសាច់ញាតិ ។ មិនមានពាក្យពេចន៍អ្វីមកនិយាយឲ្យសមពីសមិទ្ធផលដែល សម្បត្តិ បានសាងឡើយ ។ ឥឡូវគាត់បានទៅកាន់សុគតិភពហើយ ហើយយើងនឹងនឹករំឭកដល់គាត់ជារៀងរហូត ។ **រ៉ៃ មុនធិត**



រាជ សម្បត្តិ និមន្តព្រះសង្ឃចូលបន្ទប់សវនាការ

# វត្តឥន្ទញ្ញាណជាគុកធំរបស់ខ្មែរក្រហម : រឿងរ៉ាវរបស់អ៊ំស្រីម្នាក់

អ៊ំស្រី សោម សារុន ក្នុងវ័យ ៦៧ ឆ្នាំ បានមករស់នៅជាមួយក្មួយនៅខេត្តព្រះសីហនុ ។ អ៊ំស្រីបានរស់រានមានជីវិតពីរបបខ្មែរក្រហមជាមួយនឹងកូនប្រុសម្នាក់ទាំងក្តីឈឺចាប់យ៉ាងជ្រាលជ្រៅ ។ អ៊ំស្រីបានចូលនិវត្តន៍ពីការងាររអប់រំកាលពីបួនឆ្នាំមុននេះ ។ អ៊ំស្រីបានបន្តរស់នៅខេត្តព្រះសីហនុ កាលពីមុនហៅថាខេត្តកំពង់សោម តាំងពីឆ្នាំ១៩៧៩ និងជាជនរងគ្រោះ និងសាក្សីតែម្នាក់គត់ដែលជាប់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅវត្តឥន្ទញ្ញាណ ។ ប្តីរបស់អ៊ំស្រីត្រូវបានសម្លាប់នៅក្នុងទីតាំងវត្តឥន្ទញ្ញាណនេះដែលជាគុកធំរបស់ខ្មែរក្រហម ។

អ៊ំស្រីមានដើមកំណើតនៅខេត្តកំពង់ចាម ។ អ៊ំស្រីបានមកកំពង់សោមរយៈពេល១២ថ្ងៃមុនក្រុមខ្មែរក្រហមឡើងកាន់អំណាចដើម្បីមករួមរស់ជាមួយគ្រួសាររបស់គាត់ដែលបម្រើការងារជាអ្នកបច្ចេកទេសភ្លើងនៅព្រលានយន្តហោះកងកេង ។ ក្នុងដំណើរទៅជួបជុំគ្រួសារនេះ អ៊ំស្រីបានយកកូនប្រុសទៅជាមួយផង ។ ពេលមកដល់មុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ (ពីមុនឈ្មោះថាព្រលានយន្តហោះពោធិ៍ចិនតុង) ដើម្បីធ្វើដំណើរទៅកំពង់សោម អ៊ំស្រីទទួលរងរបួសជើងឆ្វេងដោយអំបែងគ្រាប់ផ្លោងរបស់ខ្មែរក្រហម ។ ពេលនោះ ខ្មែរក្រហមប្រើងវាយសំរុកយ៉ាងខ្លាំងដើម្បីកាន់កាប់ទីក្រុងភ្នំពេញ ។ អ៊ំស្រីបានឡើងជិះយន្តហោះយោធាទាំងឈាមដាបនឹងជើងទៅកាន់កំពង់សោម ។ អ៊ំស្រីបានមកដល់ព្រលានយន្តកងកេង ហើយបានជួបប្តីរបស់អ៊ំនិងបានព្យាបាលរបួសជើងនៅទីនោះ ។

អ៊ំស្រីនិងគ្រួសារមិនរស់នៅជាមួយគ្នាទេ នៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងកំពង់សោម ។ អ៊ំស្រីចាំបានថា នៅខែកក្កដា ឆ្នាំ១៩៧៥ អ្នកស្គាល់អ៊ំស្រីបានប្រាប់គាត់ថា ខ្មែរក្រហមបានមកចាប់ប្តីរបស់គាត់យកទៅដាក់គុកនៅ



សាលាឆាន់ក្នុងវត្តឥន្ទញ្ញាណដែលជាអតីតមន្ទីរឃុំឃាំងក្នុងរបបខ្មែរក្រហម

វត្តឥន្ទញ្ញាណដោយចោទប្រកាន់ថាជាអ្នកបើកយន្តហោះ (ពីឡុត) ។ «រកមុខឃ្យូរហើយ» អ៊ឹស្រីចងចាំសម្តីគំរោះគំរើយរបស់ខ្មែរក្រហម ។ តាមពិត ប្តីអ៊ឹស្រីធ្វើជាងភ្លើងនៅព្រលានយន្តហោះកងកេងក្រោមការគ្រប់គ្រងរបស់អាកាសចរណ៍ស៊ីវិល ។ ក្រុមខ្មែរក្រហមយល់ថា អ្នកទាំងឡាយណាធ្វើការផ្នែកអាកាសចរណ៍គឺសុទ្ធតែអ្នកដែលចូលរួមការទម្លាក់គ្រាប់បែកដាក់បដិវត្តន៍ខ្លួនទាំងអស់ ។ អ៊ឹស្រីប្រាប់ថា ខ្មែរក្រហមវាយធ្វើបាបប្តីគាត់ព្រឹកល្ងាចស្ទើររាល់ថ្ងៃ ។ ប្តីរបស់គាត់ត្រូវបង្ខំឲ្យធ្វើការផងទាំងដើងជាប់ច្រវ៉ាក់ ។ អ៊ឹស្រីបន្តទាំងសំឡេងអួលដើមកថា ប្តីរបស់គាត់បានលោតចូលភ្លើងដើម្បីសម្លាប់ខ្លួន ព្រោះទ្រាំទ្រនឹងការលំបាកមិនបាន ។ អ៊ឹស្រីរន្ធត់ខ្លាំងណាស់នៅពេលឮដំណឹងនេះ ។ អ៊ឹស្រីនៅចងចាំសម្តីខ្មែរក្រហមនៅក្នុងចិត្តនៅឡើយដែលនិយាយថា «អាពីឡុត វាលោតចូលភ្លើងសម្លាប់ខ្លួនហើយ» ។ អ៊ឹស្រីតក់ស្លុតរួមនឹងក្តីក្តុកក្តួលក្នុងចិត្តជាខ្លាំង ។ អ៊ឹស្រីមិនហ៊ាននិយាយស្តីអ្វីក្រៅតែពីនៅស្ងៀមនិងខំប្រឹងធ្វើការដើម្បីកុំឲ្យខ្មែរក្រហមមានការសង្ស័យមកលើរូបគាត់ទេ ។

រឿងរ៉ាវមិនបានបញ្ចប់ត្រឹមហ្នឹងទេ ។ ខ្មែរក្រហមបានបន្តស្រាវជ្រាវរកក្រុមគ្រួសារទៀត ។ ចំណែកអ៊ឹស្រីដែលរស់នៅតាមកងនារីទទួលបានការខ្សឹបខ្សាវប្រាប់ឲ្យប្រយ័ត្នប្រយែងពាក្យសម្តី ។ អ៊ឹស្រីនិយាយថា «មែន ព្រឹកឡើងវាទៅអង្គុយចាំនៅមុខផ្ទះតែម្តង ។ វាប្រាប់ថា មិត្តនារីឯង អង្គការឲ្យទៅរស់នៅជួបជុំគ្រួសារវិញ» ។ អ៊ឹស្រីយល់ភ្លាមថា នេះគ្រាន់តែជាលេសសម្រាប់យកគាត់ទៅសម្លាប់ប៉ុណ្ណោះ ។ ដើម្បីគេចឲ្យផុតពីសេចក្តីស្លាប់ អ៊ឹស្រីតបនឹងខ្មែរក្រហមវិញថា «គ្រួសារខ្ញុំបែកបាក់គ្នាហើយ ឲ្យខ្ញុំទៅនៅជុំគ្នាវិញយ៉ាងម៉េចនឹងកើត ។ ខ្ញុំមិនទៅទេ» ។ ខ្មែរក្រហមប្រឹងល្បួងបន្ថែមថា «ប្រពន្ធដើមអង្គការឲ្យត្រូវគ្នាវិញ» ។ គាត់ប្រាប់ខ្មែរក្រហមវិញថា «បើខ្ញុំទៅ ក៏យើងមិនត្រូវគ្នាវិញដែរ ។ សុខចិត្តនៅបម្រើអង្គការវិញ» ។

អ៊ឹស្រីបានរួចផុតពីសេចក្តីស្លាប់ ដោយអ៊ឹស្រីបានដឹងរឿងនេះមុន ហើយបានរៀបពាក្យសម្តីប្រឌិតនេះឡើង ។ ក្នុងចិត្តវិញ អ៊ឹស្រីមានការភិតភ័យ និងឈឺចាប់ពន់ពេក ។ អ៊ឹស្រីបន្តថា នៅពេលយប់ខ្មែរក្រហមបានបញ្ជូនឈ្លបឲ្យមកតាមដានដល់ផ្ទះទៀត ។ ដោយសារគាត់ដឹងមុន អ៊ឹស្រីមិនបាននិយាយអ្វី ប្តុសម្តែងអ្វីឲ្យខ្មែរក្រហមដឹងថា គាត់មានការក្តុកក្តួល និងឈឺចាប់នោះទេ ។

ក្រោយឆ្នាំ១៩៧៩ភ្លាម អ៊ឹស្រីធ្លាប់បានទៅវត្តឥន្ទញ្ញាណដែរ ហើយដឹងថា សាលាឆាន់គឺជាបន្ទប់គុក ។ អ្នកភូមិម្នាក់រស់នៅក្បែរវត្តបានអះអាងដូចគ្នា ដោយគូសបញ្ជាក់ថា សាលាឆាន់នេះជារោងមានរាងទ្រវែងដែលខណ្ឌជាបន្ទប់តូចៗសម្រាប់ដាក់អ្នកទោស ។ អ៊ឹស្រីយល់ថា វត្តឥន្ទញ្ញាណគឺជាគុកធំ នៅខេត្តកំពង់សោមក្នុងរបបខ្មែរក្រហម ។ អ៊ឹស្រីធ្លាប់បានដើរទៅកាប់អំពៅក្បែរបរិវេណវត្តនោះដែរកាលក្នុងជំនាន់ ប៉ុល ពត ។ អ៊ឹស្រីនិយាយថា អ៊ឹស្រីមិនចង់ទៅវត្តនោះទេ ។ បើកាលណាទៅវត្តនោះ ធ្វើឲ្យអ៊ឹស្រីនឹកឃើញរឿងគ្រួសារ ហើយធ្វើឲ្យគាត់មានអារម្មណ៍ក្តុកក្តួល ។ បើកាលណាមានអារម្មណ៍បែបនេះពេកនឹងធ្វើឲ្យអ៊ឹស្រីធ្លាក់ខ្លួនឈឺ ។ អ៊ឹស្រីនិយាយទៀតថា «សព្វថ្ងៃ ខ្ញុំរំងាប់ចិត្តបានហើយ» ។ ការរំឭករឿងនេះឡើងវិញក៏មិនថ្វីដែរ ពីព្រោះអ៊ឹស្រីបានស្វែងយល់ពីធម៌ព្រះពុទ្ធដែលសម្តែងមកថាមនុស្សយើងម្នាក់ៗមិនអាចគេចផុតពីសេចក្តីស្លាប់បានឡើយ ។

អ៊ឹស្រីមានសម្តីសំដៅទន់ភ្លន់ណាស់ ។ អ៊ឹស្រីសម្តែងការរាក់ទាក់បានយ៉ាងល្អប្រពៃ ។ អ៊ឹស្រីបានចែករំលែករឿងរ៉ាវនេះដោយទឹកចិត្តស្មោះស ។ សុខភាពរបស់អ៊ឹស្រីមិនសូវជាល្អប៉ុន្មានទេ ។ ពេលដែលខ្ញុំកំពុងនិយាយជាគាត់ អ៊ឹស្រីមានជំងឺសន្លាក់ហើយ សព្វថ្ងៃរស់នៅជាមួយក្មួយ ។ អ៊ឹស្រីទំនងជាមិនសូវរវីរវល់នឹងសាលាក្តីខ្មែរក្រហមដែលព្យាយាមនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសប៉ុន្មាននោះទេ ។ **ទ៉ាន់ថាន់ ពៅដារ៉ា**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# រណ្តៅសាកសពក្បែរវត្ត

ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផលិតខ្សែភាពយន្តឯកសារថ្មីមួយទៀតដែលមានចំណងជើងថា «រណ្តៅសាកសពក្បែរវត្ត» ថតដោយ ឡេង រតនៈ ។ ជាខ្សែភាពយន្តឯកសារទីបួន «រណ្តៅសាកសពក្បែរវត្ត» រៀបរាប់អំពីដំណើរជីវិតរបស់ស្ត្រីពីររូបគឺ លៀប និង វាំង ដែលប្រឈមមុខរាល់ថ្ងៃទៅនឹងហេតុការណ៍ពិតដែលថា ឪពុកនិងពូជាទីស្រលាញ់របស់ខ្លួនត្រូវបានសម្លាប់ដោយស្នាដៃរបស់បុរសម្នាក់ឈ្មោះ គិន ដែលជាអតីតឈ្លបឃុំមួយរូបកាលពីជំនាន់ខ្មែរក្រហម ។




ភ្លាមៗក្រោយពីរបបខ្មែរក្រហមដួលរំលំទៅ លៀប បានរកឃើញផ្នូររបស់ឪពុកគាត់តាមរយៈការសារភាពរបស់ គិន ចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ។

រណ្តៅសាកសពរបស់ឪពុក លៀប ដែលមានទីតាំងនៅក្បែរវត្តដែល គិន ធ្វើជាអាចារ្យនាពេលបច្ចុប្បន្ននេះគឺជារណ្តៅមួយក្នុងចំណោមរណ្តៅចំនួនជាងពីរម៉ឺនកន្លែងដែលបន្សល់ពីជំនាន់ខ្មែរក្រហម ។ គិន ជាជនដៃដល់ម្នាក់ក្នុងចំណោមជនដៃដល់ជាច្រើនទៀតដែលបានរួចរស់ជីវិតពីរបបនេះ ។ កម្មាភិបាលខ្មែរក្រហមមួយចំនួនផ្សេងទៀតបានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃជាមួយមេដឹកនាំខ្មែរក្រហម ។ ចំណែកកម្មាភិបាលមួយចំនួនទៀត រួមទាំង គិន ផងបានចូលបួសជាសង្ឃ ឬធ្វើជាអាចារ្យ ដែលសព្វថ្ងៃជនរងគ្រោះដែលខ្លួនធ្លាប់ធ្វើបាបមកគោរពដើម្បីកសាងកុសលផលបុណ្យ និងដើម្បីផ្សះផ្សារបួស ។

អ្វីដែលដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា ទោះបីជា គិន ទទួលខុសត្រូវចំពោះមរណភាពឪពុករបស់ លៀប និងពូរបស់ វាំង ក៏ដោយ ក៏ គិន នៅតែទទួលបាននូវការគោរពពីសំណាក់អ្នកភូមិរួមទាំង លៀប និង វាំង ផង ដោយសារតែគាត់ជាអាចារ្យវត្ត ។ ដូចគ្នាទៅនឹងអ្នកភូមិផ្សេងទៀតដែរ លៀប និង វាំង ធ្វើបុណ្យរួមគ្នានៅវត្តរបស់ គិន ដើម្បីឧទ្ទិសដល់ញាតិសណ្តានដែលបានស្លាប់ទៅ ។

ដូចអ្នករស់រានពីរបបខ្មែរក្រហមផ្សេងទៀតដែរ លៀប និង វាំង មិនបានសងសឹកជាមួយជនដៃដល់ទេ ។ ប៉ុន្តែ នេះមិនប្រាកដថា អ្នកទាំងពីរអាចអត់ឱនទោសឲ្យ គិន បានទេ ។ លៀប និង វាំង នៅតែត្រងត្រាប់តាមឱវាទរបស់ព្រះពុទ្ធដោយ «ពៀររំងាប់ដោយការមិនចងពៀរ» ។ នៅក្នុងខ្សែភាពយន្តឯកសារនេះ លៀប បាននិយាយថា «ប្រហែលជាឪពុកខ្ញុំជំពាក់ តាគិន បានជា តាគិន មកសម្លាប់ឪពុកខ្ញុំ ។ ខ្ញុំមិនឲ្យប្អូនទៅសងសឹក (គិន) ទេ ព្រោះខ្លាចជំពាក់ឈាមតគ្នា» ។

ព្រះពុទ្ធបានថែងថា អ្នកធ្វើអំពើអាក្រក់និងទទួលបានផលអាក្រក់ ទោះជាតិនេះក្តីឬជាតិក្រោយក្តី ។

ខុសពី គិន អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត មិនដែលសារភាពពីអ្វីដែលខ្លួនបានធ្វើកាលពីជំនាន់ខ្មែរក្រហមទេ ។ ប៉ុន្តែការអត់ឱនពិតជាអាចកើតឡើងបាន ហើយជនដៃដល់មួយចំនួនក៏ទទួលស្គាល់ពីកំហុសរបស់ខ្លួនដែរ ។ រឿងរ៉ាវរបស់ គិន លៀប និង វាំង គឺជាករណីមួយក្នុងចំណោមករណីជាច្រើនទៀតទូទាំងប្រទេស ដែលជនដៃដល់និងជនរងគ្រោះរស់នៅជាមួយគ្នាក្នុងភូមិ ឬសហគមន៍តែមួយ ។ «រណ្តៅសាកសពក្បែរវត្ត» អាចរកមើលបាននៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ឬ ក៏តាមរយៈគេហទំព័រ *http://www.dccam.org/Archives/Films/Films.htm* ឬក៏តាមរយៈគេហទំព័រ youtube ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# គូជីវិតរបស់ខ្ញុំ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានផ្សំផ្គុំឲ្យបុរស និងនារីរៀបការជាមួយគ្នាជាច្រើនគូ ដោយខ្លះរៀបការដោយការបង្ខិតបង្ខំ ខ្លះទៀតដោយការស្ម័គ្រចិត្ត ។ ដូច្នេះហើយ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ប្តីប្រពន្ធខ្លះក៏បានរួមរស់ជាមួយគ្នារហូតដល់ចាស់ ខ្លះទៀតក៏បានលែងលះគ្នា ព្រោះថាការរៀបការនៅសម័យនោះមិនបានស្រឡាញ់គ្នានោះទេ គឺជាការរៀបចំរបស់អង្គការ ប៉ុណ្ណោះ ។ ប៊ុន ឈួត សព្វថ្ងៃជាមេភូមិរស់នៅភូមិថ្មី ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បានរៀបរាប់ឲ្យដឹងថា នៅសម័យនោះគាត់សំណាងណាស់ ព្រោះគាត់បានរៀបការជាមួយនារីតម្បាញម្នាក់ឈ្មោះ ឆ ឈឺន ដោយការស្រឡាញ់គ្នា មិនមែនជាការចាត់តាំងរបស់អង្គការទេ ហើយគាត់ក៏បានរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃនេះដែរ ។ ខាងក្រោមនេះជាជីវិតរស់នៅរបស់ ឈួត នៅសម័យខ្មែរក្រហមៈ

នៅជំនាន់ លន់ នល់ ខ្ញុំរស់នៅភូមិសាលាឆេះ ឃុំរហាល ស្រុកព្រះនេត្រព្រះ ។ ក្រោយពីខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ ខ្ញុំដែលទើបតែមានអាយុ១៨ឆ្នាំត្រូវបានចាត់តាំងឲ្យចូលក្នុងកងចល័តជាមួយសមាជិកពីរទៅបីនាក់ទៀតនៅភូមិថ្មី ខាងពាណិជ្ជកម្មឃុំទឹកជោរ មានតួនាទីដឹកអង្ករ ពោត ដំឡូង និងស្បៀងក្រោមការគ្រប់គ្រងរបស់ប្រធានឈ្មោះ គៀល ។ នៅទីនេះការរស់នៅមានលក្ខណៈតឹងតែងណាស់ សូម្បីតែបងប្អូនស្គាល់គ្នាក៏មិនហ៊ាននិយាយសួរសុខទុក្ខគ្នាលេងដែរ ព្រោះខ្លាចអង្គការស្តីបន្ទោស ដោយម្នាក់ៗត្រូវធ្វើការតាមការងាររៀងៗខ្លួន ។ លើសពីនេះទៅទៀត ខ្ញុំត្រូវចូលរួមប្រជុំទិតៀន ឬស្វ័យតិទៀននៅរៀងរាល់បីថ្ងៃម្តងស្តីអំពីការខិតខំធ្វើការបម្រើអង្គការក្រោមអធិបតីភាពរបស់មេភូមិ និងមេឃុំ ។

នៅទីនេះ ដំបូងឡើយការគ្រប់គ្រងមានលក្ខណៈមិនសូវតឹងតែងទេ ហើយក៏មិនដែលយកមនុស្សទៅសម្លាប់ដែរ ក្រោមការដឹកនាំរបស់ តាឆាង ជាប្រធានឃុំ ដោយគាត់ជាអ្នកមូលដ្ឋាន ។ ប៉ុន្តែក្រោយពីប្រធានភូមិឈ្មោះ យាន មកពីនិរតីចូលមកគ្រប់គ្រងជំនួសវិញ ខ្ញុំនៅតែឃើញខ្មែរក្រហមសម្លាប់មនុស្សជាបន្តបន្ទាប់ ។

នៅឆ្នាំ១៩៧៧ខ្ញុំក៏បានស្នើទៅអង្គការដើម្បីរៀបការជាមួយនារីតម្បាញម្នាក់នៅក្នុងសហករណ៍ ទី២ប្រពន្ធខ្ញុំសព្វថ្ងៃ ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំរៀបការជាមួយដោយការពេញចិត្តគ្នាទៅវិញទៅមក ហើយថែមទាំងថ្ងៃការនោះមានឪពុកម្តាយទាំងសងខាងមកចូលរួមដែរ ។ នៅពេលនោះ គូទាំងអស់មានចំនួន២៣គូ ដោយខ្ញុំទាំងពីរនាក់ឡើងប្តេជ្ញាចិត្តថា «ខ្ញុំទាំងពីរនាក់ស្រឡាញ់គ្នាដោយពិតប្រាកដ ហើយសន្យាថានឹងដើរតាមមាគ៌ារបស់បក្ស» ។ ក្រោយពីយើងឡើងប្តេជ្ញារួច ប្រជាជនទាំងអស់គ្នាទះដៃអបអរសាទរ រួចអញ្ជើញអនុឃុំ ឬគណឃុំឡើងមានចំណាប់អារម្មណ៍ដោយនិយាយថា «ឲ្យចេះស្រឡាញ់គ្នា គោរពមាគ៌ារបស់បក្សដើរតាមបក្ស ។ មិនត្រូវរីងទទឹងនឹងកង់ប្រវត្តិសាស្ត្រនេះទេ ។ ក្រោយពីរៀបការហើយ អង្គការបានបំបែកខ្ញុំទាំងពីរនាក់មិនឲ្យរស់នៅជុំគ្នាទេ រហូតដល់ជិតបែករបបខ្មែរក្រហម ទើបខ្ញុំទាំងពីរនាក់បានជួបគ្នាវិញ ។

ក្រោយពីកងទ័ពវៀតណាមបានចូលមករំដោះ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំបាននាំគ្នារត់ត្រឡប់មកស្រុកកំណើតវិញ ។ មកដល់ពេលនេះ ខ្ញុំស្ទើរតែមិនជឿថា ខ្ញុំមានឱកាសបានជួបជាមួយគ្រួសារខ្ញុំម្តងទៀតទេ ដែលនេះពិតជាសំណាងល្អមែន ព្រោះខ្ញុំរស់នៅដោយភាពសុខសាន្តជាមួយគ្រួសារខ្ញុំ ប៉ុន្តែមានអ្នកខ្លះទៀតបែរជាបែកបាក់គ្នាទៅវិញ ។ ដូច្នេះហើយ ខ្ញុំយល់ឃើញថានេះជាគូព្រេងរបស់ខ្ញុំ ព្រោះបើមិនមែនជាគូព្រេងទេ ខ្ញុំក៏មិនអាចរស់នៅជុំគ្នាបានទេដែលនេះជាគូកម្ម ។ មកដល់សព្វថ្ងៃ ខ្ញុំមានកូនទាំងអស់៥នាក់ ដោយពីរនាក់រៀបការហើយ និងបីនាក់ទៀតនៅក្នុងបន្ទុករបស់ខ្ញុំ ។

**ហ៊ិន សុធានី**

# វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី៤

## ថ្ងៃទី៥-១១ ខែ











# នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល

## មេសា ឆ្នាំ២០១១











# ថ្ងៃ២០ឧសភា ធ្វើឱ្យមានការចងចាំ

របបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់១៩៧៩បានធ្វើឲ្យប្រទេសជាតិខ្ទេចខ្ទាំទាំងស្រុង ចំណែកឯអ្នកដែលរួចរស់ជីវិតពីរបបនេះក៏ទទួលនូវការឈឺចាប់ខាងផ្លូវចិត្តឥតគណនាដោយសារអំពើឃោរឃៅមួយចំនួនដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមដូចជាការធ្វើទារុណកម្ម ការបង្អត់អាហារ ការជម្លៀសឲ្យបាកឆ្ងាយពីសមាជិកគ្រួសារនិងការសម្លាប់ជាដើម ។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំទៅប្រជាជនកម្ពុជាចាប់ផ្តើមសាងជីវិតឡើងវិញទាំងភាពឈឺចាប់ផ្លូវចិត្ត ភាពលំបាកខាងផ្លូវកាយ ក្តីបារម្ភខ្លាចរបបខ្មែរក្រហមវិលមកវិញនិងភាពចង់សងសឹកដែលមិនអាចធ្វើបាន ។

រហូតមកដល់ពេលនេះ ប្រជាជនខ្មែរនៅតែចាំមិនភ្លេចពីអំពើឃោរឃៅរបស់ខ្មែរក្រហម តែថ្ងៃ២០ឧសភា ដែលស្គាល់ជាទូទៅថា «ទិវាចងកំហឹង» បានធ្វើឲ្យជនរងគ្រោះនឹកឃើញពីរបបខ្មែរក្រហមកាន់តែខ្លាំងជាងមុន ។ ទិវា២០ឧសភា ត្រូវបានចាប់ផ្តើមប្រារព្ធឡើងតាំងពីឆ្នាំ១៩៨៤មក ក្រោមរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ។

នៅរាជធានីភ្នំពេញ ទីតាំងវាលពិឃាតជើងឯកគឺជាកន្លែងដែលមានការប្រារព្ធរាល់ឆ្នាំដោយមានការចូលរួមពីប្រជាពលរដ្ឋនិងមន្ត្រីរដ្ឋាភិបាលមួយចំនួន ។ ពិធីនេះអាចមានអត្ថន័យពីរយ៉ាង៖ ទីមួយ គឺដើម្បីជាការចងចាំដល់ហេតុការណ៍ដែលបានប្រព្រឹត្តិឡើងដោយរបបខ្មែរក្រហម និង ទីពីរ ដើម្បីឧទ្ទិសអ្នកដែលបានស្លាប់កាលពីជំនាន់នោះ ។

កាលពីថ្ងៃទី២០ខែឧសភាឆ្នាំមុន មានពិធីមួយធ្វើឡើងនៅវាលពិឃាតនេះដោយមានការចូលរួមពីសំណាក់អភិបាលរាជធានីភ្នំពេញ កែប ជុតិមា និងមន្ត្រីរដ្ឋាភិបាលជាច្រើនរូបទៀត ។ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ព្រះសង្ឃ ជនរងគ្រោះ និងប្រជាជនតាមបណ្តាលខេត្តផ្សេងៗបានមកចូលរួមដើម្បីរំឭកទៅដល់វិញ្ញាណក្ខន្ធចំពោះឪពុកម្តាយ បងប្អូន ជីដូន ជីតា និង សាច់ញាតិនៅវាលពិឃាតជើងឯកនេះ ។

ព្រាប មុំ អាយុ៥១ រស់នៅក្នុងខណ្ឌចម្ការមនរាជធានីភ្នំពេញបានមកប្រារព្ធពិធីនៅវាលពិឃាតជើងឯកនេះ ។ ទោះបីជា


ការសម្តែងរឿងរ៉ាវ[illegible]នៃរបបខ្មែរក្រហម


អ្នកចូលរួមថ្ងៃ២០ឧសភា

ចូលរួមពីធីនេះធ្វើឲ្យ ព្រាប មុំ នឹកឃើញដល់ភាពឈឺចាប់ពីជំនាន់ខ្មែរក្រហម គាត់បាននិយាយថា គាត់តែងតែមកចូលរួមពិធីនេះរៀងរាល់ឆ្នាំ ។ មុំ បានរៀបរាប់ជាច្រើន អំពីបទពិសោធន៍ជីវិតរបស់គាត់តាំងពីឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ។ មុំ បាននិយាយរៀបរាប់ថា នៅក្នុងឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់គាត់ឲ្យចាកចេញពីទីក្រុងភ្នំពេញទៅវិហារសួគ៍ស្រុកខ្សាច់កណ្តាល ។ នៅពេលទៅដល់ទីនោះ កម្មាភិបាលខ្មែរក្រហមបង្ខំឲ្យគាត់ធ្វើការហួសកម្លាំងគ្មានពេលសម្រាកនិងមិនបានហូបគ្រប់គ្រាន់ ។ មកដល់ពេលនេះ មុំ នៅតែបាត់ដំណឹងសាច់ញាតិរបស់ខ្លួនជាច្រើននាក់ដោយមិនដឹងថាស្លាប់នៅទីណា ។

គង់ សម្បត្តិ អាយុ៥៥ឆ្នាំ បានរៀបរាប់ថា គាត់មកចូលរួម «ទិវាចងកំហឹង» នេះ ដោយសារតែពិធីនេះមានសារៈសំខាន់ចំពោះប្រជាជនកម្ពុជាទាំងមូលក្នុងការចងចាំនូវហេតុការណ៍ប្រវត្តិសាស្ត្រ ។ សម្បត្តិ បានរៀបរាប់ថា «ថ្ងៃ២០ឧសភានេះពិតជាមានសារៈសំខាន់ណាស់ដើម្បីជាការចងចាំជាប់ជានិច្ចនូវហេតុការណ៍ដែលធ្លាប់ជួបប្រទះកាលពីជំនាន់បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ» ។ សម្បត្តិ បានបន្តទៀតថា «នៅពេលមកចូលរួមពិធីនេះ ខ្ញុំហាក់បីដូចជានឹកឃើញរឿងដើមម្តងទៀតដែលធ្លាប់ជួបប្រទះ» ។

ដូចគ្នាទៅនឹងរឿងរ៉ាវជីវិតរបស់ ព្រាប មុំ ដែរ សម្បត្តិ បានបាត់បង់បងប្អូនចំនួនប្រាំបីនាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មកដល់ពេលនេះគាត់មិនដឹងទីតាំងដែលអ្នកទាំងប្រាំបីនោះស្លាប់ទេ ។

ព្រាប មុំ និង គង់ សម្បត្តិ មកចូលរួមក្នុងទិវាចងកំហឹងនេះក្នុងគោលបំណងដូចគ្នាគឺដើម្បីរំឭកដល់ដួងព្រលឹងបងប្អូនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ តាំងពីថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ជនរងគ្រោះមានឱកាសគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់ និងដើម្បីជាការចងចាំជានូវអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។ ការអភ័យទោសនៅតែអាចទៅរួចសម្រាប់ សម្បត្តិ ។ ទោះជាធ្លាប់ជួបប្រទះនូវភាពឈឺចាប់ សម្បត្តិ បានបញ្ជាក់ថា គាត់មិនចងកំហឹងបន្តទៅទៀតទេ ។ ប៉ុន្តែគាត់ចង់ឲ្យមានការចងចាំនូវហេតុការណ៍កាលពីជំនាន់ខ្មែរក្រហមជារៀងរហូត ។

ជាចុងក្រោយ មុំ និង សម្បត្តិ មានទស្សនវិស័យដូចគ្នាថា «ទិវា២០ឧសភា» នេះមិនត្រូវបំភ្លេចចោលទេ ។ ពិធីនេះត្រូវតែប្រារព្ធឡើងដើម្បីឲ្យក្មេងជំនាន់ក្រោយចងចាំនូវអ្វីដែលបានកើតឡើងកាលពីជំនាន់ខ្មែរក្រហម ។ **ស៊ិន សុធីតា**





ការសម្តែងរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហម

# ទិវាដើម្បីចងចាំនិងការអប់រំ

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេលជាងបីទសវត្សរ៍ហើយក៏ដោយ ក៏ស្រមោលរបស់ខ្មែរក្រហមនៅតែដក់ជាប់ក្នុងចិត្តរបស់ប្រជាពលរដ្ឋខ្មែរដដែល ពីព្រោះដោយសារតែអ្នកទាំងនោះធ្លាប់ឆ្លងកាត់អំពើទណ្ឌកម្មដ៏ឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ដើម្បីជាការរំឭកដល់បទប្រល័យពូជសាសន៍ រដ្ឋាភិបាលបានកំណត់យកថ្ងៃ២០ឧសភា ជា «*ទិវាចងកំហឹង ឬហៅថាទិវានៃការចងចាំ*» ។ ទោះបីជាពិធីនេះធ្វើឲ្យប្រជាជនខ្លះនឹកឃើញពីការឈឺចាប់របស់ខ្លួនក៏ដោយ ជនរងគ្រោះជាច្រើននាក់ចង់ឲ្យមានការប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំ ។

ឆ្នាំនេះក៏ដូចជាឆ្នាំមុនៗដែរ រាជរដ្ឋាភិបាលបានប្រារព្ធពិធីទិវានេះនៅវាលពិឃាតជើងឯកដែលមានអ្នកចូលរួមពីសំណាក់មន្ត្រីរាជការ និស្សិត ព្រះសង្ឃ ដូនជី ជនរងគ្រោះ ជនបរទេស និងអ្នកកាសែតនានា ។ អ្នកដែលមកចូលរួមទាំងអស់បានបង្ហាញពីទុក្ខសោកនិងខ្លះទៀតបានយំដែលរបបដ៏ឃោរឃៅនេះបានសម្លាប់មនុស្សអស់ជាច្រើននាក់ដោយមានទាំងឯកសារនិងភស្តុតាងជាច្រើនបានបន្សល់ទុកដែលជាក់ស្តែងមានរណ្តៅសាកសពនិងឆ្អឹងលលាដ៏ក្បាលនៅក្នុងជើងឯកនេះស្រាប់ ។

មីង គឹម ចាន់ធី បាននិយាយដោយទឹកមុខក្រៀមក្រំថា គាត់បានបំភ្លេចរឿងរ៉ាវដែលបានកើតឡើងចំពោះគាត់នៅក្នុងរបបនោះទៅហើយ ប៉ុន្តែរាល់ពេលដែលមកចូលរួមក្នុងកម្មវិធីថ្ងៃនេះ គាត់តែងតែនឹកឃើញដល់សកម្មភាពដែលគាត់កំពុងតែធ្វើនៅក្នុងរបបនោះ ។ គាត់បន្ថែមទៀតថា «*នៅពេលថ្មើរនេះ ប្រហែលជាម៉ោង១០ព្រឹក ខ្ញុំកំពុងតែធ្វើការយ៉ាងសស្រាក់សស្រាំដោយមានកងឈ្លបពីរបីនាក់កំពុងតាមដានសកម្មភាពរបស់ខ្ញុំ ។ ពេលនោះខ្ញុំហត់ផង ឃ្លានផង ប៉ុន្តែខ្ញុំមិនអាចទៅសម្រាកទេ*» ។ ពេលគិតត្រឡប់ទៅវិញ ខ្ញុំស្ទើរតែមិនជឿថារបបនោះធ្លាប់កើតមានពីព្រោះវាពិតជាអាក្រក់ពេកក្រៃ ។ ឪពុកនិងប្អូនស្រីរបស់ខ្ញុំបានស្លាប់យ៉ាងអាណោចអាធម្មនៅក្នុងរបបនោះ អ្នកទាំងពីរមិនគួរស្លាប់ទេ ប្រសិនបើមានថ្នាំសម្រាប់ព្យាបាលគ្រប់គ្រាន់ ។ និយាយត្រង់ចំណុចនេះ មីង ចាន់ធី បានសម្លឹងមើលចុះក្រោមដោយក្តីអស់សង្ឃឹមហើយពោលថា «*នេះជាអ្វីដែលខ្ញុំនៅតែសោកស្តាយរហូតមកដល់សព្វថ្ងៃនេះ*» ។ គាត់បានបន្តទៀតថា ទោះបីជាទិវានេះធ្វើឲ្យគាត់នឹកឃើញពីអតីតកាល ប៉ុន្តែគាត់រីករាយនឹងចូលរួមក្នុងទិវានេះ ពីព្រោះវាអាចធ្វើឲ្យកូនចៅជំនាន់ក្រោយមួយចំនួនដែល



ការសម្តែងរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហម

មិនជឿថាពិតជាមានរបបនេះផ្លាស់ប្តូរផ្នត់គំនិត និងហើយអ្នកទាំងនោះនឹងសិក្សាបន្ថែមទៅលើរបបនេះ ។

អ្នកមីងម្នាក់ទៀតដែលមានវ័យចំណាស់បន្តិចនិងរស់នៅខណ្ឌដង្កោបានយល់ស្របនឹងទស្សនៈរបស់ ចាន់ធី ដែរ តែគាត់បានបន្ថែមទៀតថា គាត់តែងតែចូលរួមពិធីនេះជារៀងរាល់ឆ្នាំដោយធ្វើបាយសម្លនិងយករបស់របរមួយចំនួនទៀតមកប្រគេន

ព្រះសង្ឃដើម្បីឧទ្ទិសកុសលដល់អ្នកដែលស្លាប់ ។ គាត់បន្តថា ទោះបីជាគាត់មិនមានសាច់ញាតិស្លាប់នៅវាលពិឃាតនេះក៏ដោយ ក៏គាត់មកទីនេះចូលរួមដែរព្រោះវាជាកម្មវិធីប្រវត្តិសាស្ត្រមួយ ដើម្បីរំឭកដល់ជនរួមជាតិទាំងអស់ដែលបានស្លាប់នៅក្នុងរបបនេះ ។ លើសពីនេះទៅទៀត គាត់យល់ថា ជាការល្អសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងពីការដឹកនាំរបស់ខ្មែរក្រហម ព្រោះក្មេងៗទាំងនេះគឺជាសសរទ្រូងរបស់ប្រទេស ដូច្នេះអាចរួមគ្នាទប់ស្កាត់មិនឲ្យអំពើទាំងនេះកើតឡើងជាថ្មីទៀត ។

មាស សុភាព រស់នៅស្រុកបន្ទាយមាស ខេត្តកំពត ហើយបានមកចូលរួមពិធីនេះវាលពិឃាតជើងឯកនេះដែរបាន



រៀបរាប់ថា «គាត់មានបងប្អូនបីនាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាគាត់មិនដឹងថាអ្នកទាំងបីនាក់ស្លាប់នៅកន្លែងណាទេ តែគាត់មកវាលពិឃាតជើងឯកនេះជារៀងរាល់ឆ្នាំដើម្បីរំឭកដល់វិញ្ញាណក្ខន្ធអ្នកទាំងនោះដែលបានស្លាប់» ។ សុភាព បន្តថា ទិវានេះមានប្រយោជន៍ជាខ្លាំងដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងពីការតស៊ូនិងការរស់រានមានជីវិតរបស់ឪពុកម្តាយ ក៏ដូចជាបងប្អូននិងសាច់ញាតិរបស់ខ្លួនថាបានជួបការលំបាកយ៉ាងណាខ្លះ ។ ហេតុដូច្នេះហើយ ក្មេងទាំងនោះនឹងនាំគ្នាសិក្សានិងស្វែងយល់ឲ្យបានច្រើនដើម្បីបញ្ចៀសមិនឲ្យមានទៀត ។

ចំណែក សែ កុសល្យ រស់នៅក្នុងក្រុងភ្នំពេញបានរៀបរាប់ថា ពេលខ្មែរក្រហមជម្លៀសគាត់ចេញពីទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ២ យប់នោះគាត់បានឃើញខ្មែរក្រហមបញ្ជូនទាហាន លន់ នល់ រួមទាំងប្រជាជនផងដែរមកសម្លាប់ចោលនៅទីនេះ ។ លើសពីនេះទៅទៀត យប់នោះគាត់បានឮសំឡេងស្រែកថ្ងូរដែលធ្វើឲ្យគាត់ភ័យតក់ស្លុតជាខ្លាំង ។ ឥឡូវនេះ ពេលដែលគាត់ឈានជើងចូលទីនេះម្តងទៀត រឿងដែលគាត់បានឃើញហាក់ដូចជានៅថ្មីៗនៅឡើយ ។ កុសល្យ បាននិយាយទាំងទឹកមុខស្រងូតស្រងាត់ថា «ថ្ងៃ២០ឧសភា ពិតជាមានសារសារសំខាន់ជាខ្លាំងដើម្បីឲ្យប្រជាជនទាំងអស់នឹកឃើញរបបខ្មែរក្រហម ជាពិសេសរបបដែលបានសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោស» ។ ចុងក្រោយ កុសល្យ យល់ថា វាកាន់តែមានប្រយោជន៍ទៅទៀតសម្រាប់ក្មេងជំនាន់ក្រោយបានដឹងថា ខ្មែរក្រហមសម្លាប់ជាតិសាសន៍ឯង និងមិនត្រូវដើរតាមគំរូអាក្រក់បែប នេះទេ ។

**គាត លក្ខិណា និង ផា ផល្លា**

# ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ កង ឃិន អាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្លង់ជ្រៃ ឃុំអំពើន ស្រុកបន្ទាយមាស ខេត្តកំពត ។ សូមប្រកាសសួររកកូននិងប្តីដែលបាត់ខ្លួនកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ កូនរបស់ខ្ញុំឈ្មោះ ហួម ហើយប្តីឈ្មោះ ពីន ។ អ្នកទាំងពីរត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើស្រែអំបិលនៅកែប ហើយមិនឃើញត្រឡប់មកវិញរហូតដល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ***

# ពិព័រណ៍យុវជនសម្រាប់លទ្ធិប្រជាធិបតេយ្យ

## សេចក្តីផ្តើម

នៅថ្ងៃទី២៦និង២៧ ខែមិនា ឆ្នាំ២០១១ យុវជនខេត្តព្រៃវែងរាប់រយនាក់ត្រូវបានផ្តល់ឱកាសឲ្យស្វែងយល់ពីសារៈសំខាន់នៃការចូលរួមរបស់យុវជននៅក្នុងដំណើរការឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។ ក្រោមការឧបត្ថម្ភនិងកិច្ចផ្តួចផ្តើមរបស់វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិនិងក្រុមប្រឹក្សាយុវជនកម្ពុជា ពិព័រណ៍យុវជនត្រូវបានប្រារព្ធឡើងនៅពហុកីឡដ្ឋានទីរួមខេត្តព្រៃវែង ។ នេះជាលើកទីពីរហើយ ដែលកម្មវិធីនេះត្រូវបានប្រារព្ធឡើងនៅខេត្តព្រៃវែង ។ កម្មវិធីពិព័រណ៍យុវជននេះផ្តល់ឱកាសដល់យុវជនក្នុងការបង្ហាញសមត្ថភាពនិងតួនាទីរបស់ខ្លួនក្នុងការចូលរួមកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងកម្មវិធីនេះមានសកម្មភាពជាច្រើនដូចជា សិក្ខាសាលា ការតាំងពិព័រណ៍កម្មវិធីសិក្សានិងកំសាន្តជាច្រើនដូចជា ការបង្កើតបក្សនយោបាយ ការស្វែងរកសំឡេងគាំទ្រ ការអភិវឌ្ឍភាពជាអ្នកដឹកនាំ ការជជែកដេញដោល ការធ្វើយុទ្ធនាការឃោសនា ការបោះឆ្នោត ការសម្តែង និង ការប្រលងចម្រៀងជាដើម ។

កម្មវិធីនេះ ក៏ជំរុញឲ្យយុវជនចូលរួមក្នុងវិស័យអប់រំ សេដ្ឋកិច្ច និងនយោបាយ ហើយអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋនានាបានចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមនៅក្នុងកម្មវិធីនេះដែរ ហើយបានដាក់តាំងបង្ហាញសៀវភៅបោះពុម្ពផ្សាយជាច្រើនរបស់ខ្លួន ដោយបានចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៥០០ក្បាល សៀវភៅណែនាំស្តីពីសំណុំរឿង០០១និង០០២ចំនួន៥០០ក្បាល ទស្សនាវដ្តីស្វែងរកការពិត និងឯកសារជាច្រើនទៀតដល់សិស្ស-និស្សិត គ្រូបង្រៀននិងសាធារណៈជនទូទៅ ។

## សកម្មភាពនានា

នាព្រឹកថ្ងៃទី២៦ មិនា សិក្ខាសាលាស្តីពីការស្វែងរកសំឡេងឆ្នោត ការជជែកដេញដោល ការសម្តែង ដំណើរការបោះឆ្នោតនិងការផ្តល់ព័ត៌មានពីឱកាសការងារនិងអាហារូបករណ៍ត្រូវបានរៀបចំធ្វើឡើងនៅវិទ្យាស្ថានអង្គរដែលមានការចូលរួមពីយុវជនរាប់រយនាក់ ។ ដោយឡែកយុវជន យុវនារីជាច្រើននាក់ទៀតបានមកចូលរួមទស្សនាការប្រលងចំរៀងដែលប្រារព្ធធ្វើឡើងនៅពហុកីឡាដ្ឋានខេត្ត ។ ស្របពេលជាមួយគ្នានេះ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនបីរូបដែលដឹកនាំដោយកញ្ញា សើ សាយ្យណា បានមកដល់ទីកន្លែងតាំងពិព័រណ៍នៅពហុកីឡាខេត្តតាំងពីព្រលឹម ហើយចាប់ផ្តើមតុបតែងស្តង់សម្រាប់ការតាំងពិព័រណ៍នាពេលរសៀល ។ នៅម៉ោងពីររសៀល ស្តង់តាំងពិព័រណ៍ជាច្រើនបានចាប់ផ្តើមទទួលស្វាគមន៍សាធារណៈជនដែលអញ្ជើញ



ពិព័រណ៍យុវជននៅខេត្តព្រៃវែង

មកចូលរួមកម្មវិធីពិព័រណ៍យុវជននេះ ។

## យុវជនរៀនពីសារៈសំខាន់នៃប្រវត្តិសាស្ត្រអតីតកាល

កម្មវិធីតាំងពិព័រណ៍យុវជននេះបានពង្រីកវេទិកាពិភាក្សាដល់យុវជនដើម្បីឲ្យយុវជនទាំងនោះទទួលបាននូវការយល់ដឹងកាន់តែច្បាស់ពីតួនាទីរបស់យុវជននៅក្នុងដំណើរការឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ ការប្រកួតប្រជែងក្នុងដំណើរការឃោសនារកសំឡេងឆ្នោតបានធ្វើឲ្យយុវជនចេះរៀបចំធ្វើការឃោសនារកសម្លេងឆ្នោតនិងរកសំឡេងអ្នកគាំទ្រគណបក្សនយោបាយរបស់ខ្លួន ។ តាមរយៈកម្មវិធីនេះ យុវជនត្រូវបានត្រៀមខ្លួនជាស្រេចសម្រាប់តំណែងជាអ្នកដឹកនាំបម្រើឲ្យរដ្ឋាភិបាលឯករាជ្យសម្រាប់ដំណើរការអភិវឌ្ឍដែលប្រកបដោយតម្លាភាព ។ យ៉ាងណាមិញ នៅពេលដែលសួរពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងតុលាការខ្មែរក្រហម សិស្ស-និស្សិតមួយចំនួនតូចប៉ុណ្ណោះបានយល់ដឹងពីសារៈសំខាន់នៃប្រវត្តិសាស្ត្រនិងដំណើរការកាត់ទោសរបស់តុលាការខ្មែរក្រហម ។

តាមរយៈការធ្វើបទសម្ភាសន៍ជាច្រើន យើងបានរកឃើញថា សិស្សានុសិស្សថ្នាក់វិទ្យាល័យដឹងតិចតួចណាស់ទាក់ទងនិងរបបខ្មែរក្រហម ។ ស៊ីវ សុគន្ធា អាយុ២២ឆ្នាំ ជានិស្សិតឆ្នាំទីបួនបានទទួលស្គាល់ថា គាត់មិនសូវយល់ដឹងច្បាស់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុន្មានទេ ដោយសារតែគាត់ផ្តោតទៅលើបញ្ហាសេដ្ឋកិច្ចច្រើនជាង ។ ប៉ុន្តែ សុគន្ធា បានបញ្ជាក់ថាការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះពិតជាមានសារៈសំខាន់សម្រាប់ក្មេងជំនាន់ក្រោយ ដើម្បីចៀសវាងកុំឲ្យមានការប្រព្រឹត្តអំពើបែបនេះទៀត ។ សុគន្ធា បានបន្តទៀតថា ការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាជួយឲ្យគាត់មានឱកាសសិក្សាបន្ថែមទៀតពីប្រវត្តិសាស្ត្រនេះ ។

ដោយឡែក សុយ សុខុម អាយុ២២ឆ្នាំ ជានិស្សិតមូលដ្ឋាននៃសាលាគរុកោសល្យខេត្តជៀថា ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងជួយអប់រំក្មេងជំនាន់ក្រោយឲ្យចេះរៀនរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព ។ យុវជន អ៊ុំ ឈុន ក៏យល់ឃើញថាការសិក្សាពីប្រវត្តិសាស្ត្រពិតជាមានសារៈសំខាន់ពីព្រោះប្រវត្តិសាស្ត្រដែលពិតនិងត្រឹមត្រូវដូចនៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងជួយឲ្យក្មេងជំនាន់ក្រោយកាន់តែយល់ដឹងច្បាស់ពីសង្គមកម្ពុជា ។

## យុវជនជាឆ្អឹងខ្នងដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសរបស់ប្រទេសក្រោយសង្គ្រាម

នៅក្នុងសង្គមប្រជាធិបតេយ្យបច្ចុប្បន្ន យុវជនគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេស ជាពិសេសគឺប្រទេសក្រោយសង្គ្រាមដូចជាប្រទេសកម្ពុជាជាដើម ។ យុវជនមានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យអប់រំ សេដ្ឋកិច្ច និងនយោបាយនិងការអភិវឌ្ឍសង្គម ។ ប៉ុន្តែនៅសម័យខ្មែរក្រហម យុវជន និងយុវនារីជាច្រើននាក់មិនត្រូវបានអើពើ បង្ខំឲ្យធ្វើពលកម្មធ្ងន់ៗដកហូតតម្រូវការចាំបាច់ក្នុងជីវិត បង្អត់អាហារ និងសម្លាប់ដោយសារកំហុសតូចតាច ។ ក្នុងទិដ្ឋភាពបែបនេះ បើទោះបីជារបបខ្មែរក្រហមនេះមិនត្រូវបានផ្តួលរលំដោយកងទ័ពវៀតណាមក៏ដោយ ក៏របបផ្តាច់ការនេះនឹងដួលរលំទៅដោយខ្លួនឯងដោយសារតែយុវជនដែលជាឆ្អឹងខ្នងដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសបានរងគ្រោះថ្នាក់ ។ ដូច្នេះកម្មវិធីពិព័រណ៍យុវជននេះបានដើរតួយ៉ាងសំខាន់នៅក្នុងការលើកកម្ពស់ការយល់ដឹងរបស់យុវជនពីតួនាទីរបស់ខ្លួននៅក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ ។ តាមរយៈព្រឹត្តិការណ៍នេះ យុវជនមានឱកាសទទួលបានការយល់ដឹងពីលទ្ធិប្រជាធិបតេយ្យដែលជួយឲ្យយុវជនទាំងនោះធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវក្នុងការជ្រើសរើសអ្នកដឹកនាំប្រទេស ។ បន្ថែមលើនេះ ការតាំងពិព័រណ៍របស់អ្នកជំនួញក្នុងស្រុកក៏បានជួយឲ្យយុវជនធ្វើការស្វែងយល់ពីការចូលរួមរបស់យុវជននៅក្នុងវិស័យសេដ្ឋកិច្ច ។

ផុន ឈឿន អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១០នៃវិទ្យាល័យហ៊ុនសែនកំពង់លាវបានសង្កត់ធ្ងន់ថា កម្មវិធីពិព័រណ៍យុវជននេះបានផ្តល់ចំណេះដឹងយ៉ាងច្រើនស្តីពីដំណើរការលទ្ធិប្រជាធិបតេយ្យដែលជួយឲ្យគាត់យល់កាន់តែច្បាស់ពីការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ចំណែកឯ វ៉ា ធឿន អាយុ២២ឆ្នាំដែលជាសិស្សថ្នាក់ទី១២វិញបាននិយាយថា ព្រឹត្តិការណ៍នេះពិតជាមានសារៈសំខាន់ពីព្រោះពិព័រណ៍នេះជួយឲ្យយុវជនមានភាពជឿជាក់លើខ្លួនឯងកាន់តែច្រើននៅក្នុងការចូលរួមសកម្មភាពផ្សេងៗនៅក្នុងសង្គម ។ **ឌែន សុខស្រីនិត**

# បង្ខំចិត្តសើចនៅពេលឃើញខ្មែរក្រហម ធ្វើទារុណកម្មឪពុកនៅចំពោះមុខ

របបខ្មែរក្រហម ជារបបមួយដែលពោរពេញទៅដោយការធ្វើទារុណកម្ម បង្អត់អាហារ បង្ខំមនុស្សឲ្យធ្វើការងារហួសកម្លាំង គ្មានពេលសម្រាក និងកាប់សម្លាប់យ៉ាងសាហាវឃោរឃៅ ដោយមិនអនុញ្ញាតឲ្យតវ៉ា ឬប្រឆាំងនឹងអង្គការបដិវត្តន៍នេះបានឡើយ ។ ប្រសិនបើមាននរណាម្នាក់ឃើញមិត្តភក្តិ សាច់ញាតិ បងប្អូន ឪពុកម្តាយត្រូវបានចាប់ចង ធ្វើទារុណកម្ម ឬសម្លាប់ នៅនឹងមុខហើយក៏ដោយ ក៏អ្នកនោះ មិនហ៊ាននិយាយតវ៉ា ឬយំសោកនៅចំពោះមុខអង្គការបានទេ ។ ប្រសិនបើអ្នកណាហ៊ានធ្វើបែបនោះគឺនឹងត្រូវបានអង្គការចោទប្រកាន់ថា ជាខ្មាំងមិនខាន ។ នេះគឺជារឿងរ៉ាវបុរសម្នាក់ដែលបានដាក់ពាក្យបណ្តឹងប្តឹងទៅមេដឹកនាំខ្មែរក្រហម ក្នុងចំណោមអ្នកដាក់ពាក្យបណ្តឹង ១៧៥០នាក់ ។ មិន ឈៀង មានអាយុ៥៨ឆ្នាំ មកពីខេត្តសៀមរាប ។ ឈៀង មានមុខរបរជាកសិករ និងមានកូនពីរនាក់ប្រុសមួយស្រីមួយ ។

ឈៀង កើតនៅឆ្នាំ១៩៥១ ។ ពីឆ្នាំ១៩៧០ដល់៧៥ ឈៀង បានចូលធ្វើទាហាន លន់ នល់ ។ នៅថ្ងៃ១៧ មេសា ១៩៧៥ ឈៀង មានការត្រេកអរយ៉ាងខ្លាំងព្រោះគិតថាសង្គ្រាមបានរលត់ទៅហើយ ។ ប៉ុន្តែ មួយរយៈក្រោយមក ឈៀង ឃើញនៅក្នុងភូមិមានភាពខុសប្លែកពីប្រក្រតី ព្រោះ ឈៀង ឃើញខ្មែរក្រហមដើរប្រកូកប្រកាសនៅពេញភូមិថាប្រសិនបើអ្នកណាធ្វើការងារអ៊ីសូមប្រាប់អង្គការ ហើយអង្គការនឹងឲ្យទៅធ្វើការនៅកន្លែងដើមវិញ ។ ជាពិសេស អ្នកដែលធ្លាប់ធ្វើជាទាហាន លន់ នល់ ទាំងអស់ឲ្យទៅទទួលសម្តេចដើម្បីបំពាក់ស័ក្តិឡើងវិញ ។ បន្ទាប់មក ទឹម ជាប្រធានក្រុមរបស់ ឈៀង បានឲ្យ ឈៀង ដើរកត់ឈ្មោះប្រជាជន ។ ពេលនោះ ឈៀង បានចុះឈ្មោះរបស់ខ្លួនមុនគេ និងកត់ឲ្យអ្នកនៅក្នុងភូមិជាហូរហែរហូតដល់អស់មនុស្ស ហើយ ឈៀង បានយកឈ្មោះនោះទៅប្រគល់ឲ្យ ទឹម ទាំងអស់ ។ ឈៀង មិនបានដឹងថា ទឹម យកឈ្មោះនោះទៅឲ្យនរណាទេ ។ រយៈពេលប្រហែលបីថ្ងៃក្រោយមក ស្រាប់តែ ឈៀង ឃើញអង្គការមកហៅអ្នកដែលធ្លាប់ធ្វើទាហាន លន់ នល់ ទាំងអស់នោះឲ្យទៅចាំនៅជិតថ្នល់ជាតិព្រោះអង្គការយកត្រាក់ទ័រមកដឹកទៅវត្តប្រាសាទដើម្បីទៅទទួលសម្តេច ថែមទាំងប្រាប់ថាប្រពន្ធកូនចាំយកទៅតាមក្រោយ ។ ប៉ុន្តែតាមពិត មិនមែនទៅទទួលសម្តេចទេ គឺយោធាខ្មែរក្រហមដឹកអ្នកទាំងនោះយកទៅសម្លាប់ចោលនៅបារាយណ៍ទឹកថ្លាទាំងអស់ ។ ឈៀង ចាប់ផ្តើមមានការភ័យរន្ធត់ខ្លាំង ព្រោះគាត់ក៏ធ្លាប់ធ្វើទាហាន លន់ នល់ ដែរ ។ ដូច្នេះ ឈៀង ចាប់ផ្តើមលាក់ប្រវត្តិរបស់ខ្លួនរហូត ព្រោះពេលចុះឈ្មោះគាត់ដាក់ថាធ្លាប់ធ្វើជាទាហានស្ម័យត្រាណប៉ុណ្ណោះ ។ ប៉ុន្តែ ទោះបី ឈៀង មិនទាន់ឃើញអង្គការមកហៅគាត់ទៅក៏ដោយ ក៏គាត់នៅតែគិតថាថ្ងៃណាមួយនឹងដល់វេនខ្លួនមិនខាន ។

នៅឆ្នាំ១៩៧៦ ឈៀង សង្កេតឃើញខ្មែរក្រហមសម្លាប់ មនុស្សកាន់តែច្រើន ព្រមទាំងបង្ខំឲ្យអ្នកភូមិធ្វើការស្ទើរគ្មានពេលសម្រាក ព្រមទាំងឲ្យហូបមិនគ្រប់គ្រាន់ គឺមួយពេលទទួលបានតែបបររាវពីរទៅបីវែកប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៧ ឈៀង ត្រូវបានចាត់តាំងឲ្យឡើងត្នោតក្នុងមួយថ្ងៃពី២៧-២៨ដើម ដើម្បីយកទឹកត្នោតមកធ្វើស្ករនិងកាប់ស្លឹកធ្វើជាកណ្តូបប្រក់រោង និងផ្ទះ ។ បន្ទាប់ពីរដូវធ្វើទឹកត្នោត ឈៀង ត្រូវបានចាត់តាំងឲ្យទៅភ្ជួរស្រែ និងដាំដំឡូងជាមួយអ្នកភូមិ ។

ថ្ងៃមួយ ពេល ឈៀង ដើរទៅយកទឹកត្នោត គាត់បានឃើញ ហ៊ាន ជាកងឈ្លប(សព្វថ្ងៃនៅរស់) បានចងមនុស្សយកទៅសម្លាប់ចោល ។ ឃើញដូច្នេះ ឈៀង មានការរន្ធត់យ៉ាងខ្លាំង ។

រយៈពេលបីខែក្រោយមក ណុប បានបញ្ជាឲ្យ ហ៊ាន ទៅចាប់កូនប្រុស និងឪពុករបស់ ឈៀង នៅចំពោះមុខ ។ ពេលនោះ ឈៀង មិនហ៊ាននិយាយតវ៉ា យំស្រែក ឬទៅជួយទេ ព្រោះខ្លាចខ្មែរក្រហមចោទថាខ្មាំងដែរ ។

បន្ទាប់ពីចាប់ឪពុកមានិងកូនរបស់គាត់រួចហើយ ឈួប ខ្មែរក្រហមដើរមកសួរ ឈៀង ថា «ម៉េចមិត្តនៅពេលគេចងឪពុកមិត្តឯងអញ្ចឹងនោះ?» ឈៀង ខំប្រឹងសើចបន្ទប់ ព្រោះគាត់ខ្លាចឈួបនោះ ។ ឈួបបានសួរ ឈៀង បន្តថា «គេចង និងវាយធ្វើបាបឪពុកមិត្តឯងអ៊ីចឹងហើយ តើមិត្តឯងអត់ខឹងទេឬ?» ឈៀង ខំប្រឹងញញឹម ហើយនិយាយតបទៅវិញថា «ខ្ញុំអត់ខឹងទេ សក់អ្នកណាក្បាលអ្នកហ្នឹង ឪពុកខ្ញុំផ្សេង ខ្ញុំផ្សេង អត់មានអីពាក់ព័ន្ធគ្នាទេ» ។ ប៉ុន្តែតាមពិត ឈៀង អាណិតអាសូរចំពោះឪពុករបស់គាត់យ៉ាងខ្លាំង ។

នៅទីនោះ ឈៀង បានឃើញឈួបបណ្តើរមនុស្សយកទៅសម្លាប់ជាបន្តបន្ទាប់ តែមិនបានដឹងអ្នកទាំងនោះមានកំហុសអ្វី ឬយកទៅសម្លាប់កន្លែងណាទេ ។ នៅពេលធ្វើមិទ្ទីង និងប្រជុំម្តងៗ ឈៀង បានឮគណៈស្រុកនិយាយប្រាប់ទៅអ្នកចូលរួមថា អ្នកដែលអង្គការយកទៅកសាងមានបួនប្រភេទគឺ ប្រភេទទី១ៈ ជាតិញបង្កប់ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ។ ប្រភេទទី២ៈ អ្នកប្រឆាំងអង្គការបដិវត្តន៍ ។ ប្រភេទទី៣ៈ អ្នកដែលធ្វើខុសសីលធម៌ និងប្រភេទទី៤ៈ អ្នកដែលរៀនមិនចេះ ។ ឈៀង សង្កេតឃើញថា អ្នកដែលអង្គការចាត់ចូលនៅក្នុងប្រភេទទាំង៤ខាងលើនេះគឺត្រូវបានយកទៅធ្វើទារុណកម្ម ដាក់គុក និងសម្លាប់ចោលទាំងអស់ ។

នៅឆ្នាំ១៩៧៩ ក្រោយកងទ័ពវៀតណាមរំដោះបានភ្លាម ប្រជាជននៅក្នុងភូមិបានចាប់ ឈួប ប្រធានសហករណ៍ ប្រធានឃុំ គណៈស្រុក (មកពីនិរតី) សម្លាប់ចោលវិញ ។ ព្រោះប្រជាជនមានកំហឹងនឹងកម្មាភិបាលទាំងនោះដែលធ្វើបាប និងសម្លាប់បងប្អូន ឪពុកម្តាយរបស់គេ ។

ក្រោយមក រដ្ឋអំណាចបានរៀបចំសណ្តាប់ធ្នាប់ភូមិ និងបានជ្រើសរើស ឈៀង ធ្វើជាមេភូមិ ។ ឈៀង ធ្វើប្រធានភូមិបានពីរឆ្នាំ ក្រោយមកនៅឆ្នាំ១៩៨១ រដ្ឋអំណាចបានចាត់តាំង ឈៀង ទៅធ្វើការជាមួយកងទ័ពវៀតណាមបានមួយឆ្នាំ គាត់ក៏ត្រឡប់មកផ្ទះវិញ ។

នៅឆ្នាំ១៩៨៥ ប្រជាពលរដ្ឋបានបោះឆ្នោតឲ្យ ឈៀង ធ្វើប្រធានភូមិ រហូតដល់ឆ្នាំ១៩៨៦ ទើបថ្នាក់លើតំឡើងគាត់ជាអនុប្រធានឃុំ និងមានតួនាទីគ្រប់គ្រងយោធាឃុំ ។ រហូតមកដល់ពេលនេះ ឈៀង ជាមន្ត្រីចូលនិវត្តន៍ ។

នៅឆ្នាំ២០០៨ ឈៀង បានដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចុះប្រជុំជាមួយអ្នកភូមិ និងណែនាំអ្នកភូមិពីវិធីដាក់ពាក្យបណ្តឹងទៅកាន់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ឈៀង បន្ថែមថា ប្រសិនបើគាត់ និងអ្នកភូមិមិនប្តឹងមេដឹកនាំទាំងអស់នោះទេ នោះនឹងគ្មានការចាប់អ្នកទាំងនោះមកកាត់ទោសទេ ។

ពាក្យបណ្តឹងរបស់ ឈៀង ត្រូវបានតុលាការទទួលស្គាល់ ហើយនៅឆ្នាំ២០១០ បុគ្គលិកមជ្ឈមណ្ឌលឯសារកម្ពុជាបានទទួលលិខិតថ្លែងអំណរគុណពីតុលាការប្រគល់ឲ្យ ឈៀង ។ ឈៀង មានការរំភើបយ៉ាងខ្លាំងព្រោះគាត់មិននឹកស្មានថា ខាងតុលាការទទួលស្គាល់រឿងរ៉ាវរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ ឈៀង ជឿ ជាក់ថា នៅពេលខាងមុខ តុលាការនឹងរកយុត្តិធម៌ជូនគាត់ក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ ។

**ស សេងគា**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# ប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់អ្នកទាំងអស់គ្នា

មជ្ឈមណ្ឌលឯកសារកម្ពុជាមានទស្សនៈថា ការសិក្សាពីប្រវត្តិសាស្ត្រគឺពិតជាសំខាន់សំរាប់យុវវ័យជំនាន់ក្រោយឲ្យយល់ដឹងអំពីអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល និងជីវិតដ៏លំបាកនាសម័យនោះ ហើយការសិក្សាពីប្រវត្តិសាស្ត្រនេះគឺជាវិធីមួយដើម្បីទប់ស្កាត់បទឧក្រិដ្ឋស្រដៀងគ្នានេះ នាពេលអនាគត និងដើម្បីជំរុញឲ្យមានការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ការអាន ការនិយាយប្រាប់ និងការស្តាប់នូវរឿងរ៉ាវរបស់នរណាម្នាក់ពីប្រវត្តិសាស្ត្រខ្មែរក្រហមជាវិធីដ៏សំខាន់មួយដើម្បីរៀនសូត្រពីសម័យនោះ ។ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១១កន្លងទៅ គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិការសាធារណៈមួយដែលមានការចូលរួមពីសំណាក់សិស្សានុសិស្ស ឪពុកម្តាយ និងគ្រូបង្រៀនដែលមានចំនួនប្រមាណ១៥០នាក់ នៅឃុំអូរសំព័រ ខេត្តបន្ទាយមានជ័យ ។


គីម សុភ័ក្រ

អ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមទាំងអស់ ឈ្មោះ គីម សុភ័ក្រ អាយុ២៦ឆ្នាំ ជាគ្រូបង្រៀនជីវវិទ្យា ។ បន្ទាប់ពីបញ្ចប់ការសិក្សាពីសាលាគរុកោសល្យខេត្តបាត់ដំបង សុភ័ក្រ ក្លាយទៅជាគ្រូបង្រៀនម្នាក់នៅក្នុងឆ្នាំ២០០៦ ។ ពេលនោះ សុភ័ក្រ ត្រូវបានចាត់តាំងទៅបង្រៀននៅក្នុងសហគមន៍មួយដែលមានសិស្សមួយចំនួនជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមដោយរៀនជាមួយ និងកូនរបស់ជនរងគ្រោះដែរ ។ «សិស្សមួយចំនួនរបស់ខ្ញុំគឺជាកូនអតីតកម្មាភិបាលខ្មែរក្រហម» នេះ គឺជាអ្វីដែល សុភ័ក្រ បាននិយាយថានៅពេលដែលសួរពីស្ថានភាពសិស្សនៅក្នុងថ្នាក់របស់គាត់ ។ ឃុំអូរសំព័រ គឺជាឃុំមួយស្ថិតនៅក្នុងស្រុកម៉ាឡៃ តាមបណ្តោយព្រំដែនថៃ ។ មន្ទីរឃុំអូរសំព័រមានចម្ងាយពីប៉មយាមព្រំដែនប្រហែលជា៣០០ម ។ នេះគឺជាទីតាំងរបស់ខ្មែរក្រហមអស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ។ ហេតុដូច្នេះ ប្រជាជននៅក្នុងឃុំអូរសំព័រភាគច្រើនគឺជាអតីតកម្មាភិបាលខ្មែរក្រហម ។

សុភ័ក្រមិនបានដឹងច្រើនអំពីរបបខ្មែរក្រហមទេ ហើយសូម្បីតែកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមក៏ដឹងតិចតួចពីរបបនេះដែរ ។ អ្វីដែល សុភ័ក្រ បានដឹងទាក់ទងនិងរបបខ្មែរក្រហមគឺថាខ្មែរក្រហម គឺជាមនុស្សអាក្រក់ពីព្រោះខ្មែរក្រហមសម្លាប់មនុស្ស ។ ឪពុកម្តាយរបស់សុភ័ក្រក៏មានបទពិសោធន៍ឈឺចាប់កាលពីរបបខ្មែរក្រហមនេះដែរ ហើយគាត់តែងតែរៀបរាប់ប្រាប់ សុភ័ក្រ នៅពេលដែល សុភ័ក្រ នៅជាកុមារភាពអំពីជីវិតរបស់ពួកគាត់នៅក្នុងរបបខ្មែរក្រហម ។ ឥឡូវ សុភ័ក្រ បានធំដឹងក្តី ហើយអាចរស់នៅដោយខ្លួនឯងបាន ដូច្នេះ ឪពុកម្តាយរបស់គាត់ក៏លែងប្រាប់រឿងរ៉ាវពីរបបនោះដល់ សុភ័ក្រ ទៀតដែរ ។ សុភ័ក្រនិយាយថា «ឪពុកម្តាយរបស់ខ្ញុំមិនបានប្រាប់ខ្ញុំអំពីរបបខ្មែរក្រហមនេះទៀតទេ ពីព្រោះឥឡូវនេះខ្ញុំជាគ្រូបង្រៀន ហើយរំពឹងថា ខ្ញុំនិងដឹងអំពីរបបនេះដោយខ្លួនឯង» ។ សម្រាប់ សុភ័ក្រ គាត់នៅតែគិតថា ជារឿងចាំបាច់ត្រូវតែសិក្សាបន្ថែមនូវអ្វីដែលបានកើតឡើងនៅក្នុងរបបនោះ ។ ព័ត៌មានអំពីវេទិកាសាធារណៈបានទាក់ទាញគាត់ ហើយគាត់បានចូលរួមក្នុងវេទិកា ដោយយកចិត្តទុកដាក់ ។

នៅក្នុងថ្នាក់ សុភ័ក្រ ស្រលាញ់រាប់អានសិស្សរបស់គាត់ស្មើៗគ្នា ទោះបីជាឪពុកម្តាយរបស់សិស្សមួយចំនួនបានប្រព្រឹត្ត

អំពើអាក្រក់កាលពីរបបខ្មែរក្រហមក៏ដោយ ។ សុភ័ក្រ និយាយថា «កូនរបស់ជនរងគ្រោះ និងកូនរបស់អតីតកម្មាភិបាលខ្មែរក្រហម ចាំបាច់ត្រូវតែសិក្សាអំពីរបបខ្មែរក្រហម ។ របបខ្មែរក្រហមគឺជាទុក្ខសោករបស់មនុស្សគ្រប់គ្នា និងជាទុក្ខសោករបស់ប្រទេសជាតិទាំងមូល» ។ ក្រោយពីវេទិកាសាធារណៈចប់ សុភ័ក្រ បាននិយាយថា គាត់បានរៀនសូត្រយ៉ាងច្រើនតាមរយៈការអាន និងការចែករំលែកបទពិសោធន៍ រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា «នេះគឺជាលើកដំបូងហើយដែលខ្ញុំបានទទួលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំបានអានដោយសង្ខេបៗ ហើយខ្ញុំយល់ថា សៀវភៅនេះពិតជាធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍មែនទែន ។ ពេលទៅដល់ផ្ទះវិញ ខ្ញុំនិងអានសៀវភៅនេះឲ្យចប់» ។ អ្នករួចជីវិតពីរបបនោះបានសួរសំណួរល្អៗ ហើយខ្ញុំអាចរៀនបានច្រើនតាមរយៈសំណួរទាំងអស់នោះ» ។

វេទិកានេះក៏ជាឱកាសមួយដ៏ល្អសម្រាប់ សុភ័ក្រ ដើម្បីចែករំលែកបទពិសោធន៍ជាមួយអ្នកចូលរួមដទៃទៀតរួមទាំងសិស្សរបស់គាត់ទៀតផង ។ ក្នុងបរិវេណវត្តមួយជាកន្លែងដែលវេទិកាបានធ្វើឡើង សុភ័ក្រ បាននិយាយថាមុនឆ្នាំ១៩៧៥ ឪពុករបស់គាត់គឺជាព្រះសង្ឃមួយអង្គ ហើយឪពុករបស់គាត់ត្រូវបានផ្សឹកដោយខ្មែរក្រហម ។ សុភ័ក្រនិយាយថា «ឥឡូវនេះមនុស្សគ្រប់គ្នាមានសេរីភាព ហើយព្រះសង្ឃអាចនិមន្តទៅគ្រប់ទីកន្លែងនៅក្នុងភូមិ ប៉ុន្តែនៅក្នុងរបបខ្មែរក្រហមមនុស្សគ្រប់គ្នាគ្មានសិទ្ធិសេរីភាពបែបនេះទេ «ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមបង្ខំអោយសឹក» ។ សុភ័ក្រ បានយល់យ៉ាងច្បាស់ពីការលំបាក និងការឈឺចាប់របស់ឪពុកគាត់ ។ សុភ័ក្រ បានបន្ថែមទៀតថា ការបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះគឺពិតជាសំខាន់សំរាប់ក្មេងជំនាន់ក្រោយដើម្បីសិក្សាពីបទពិសោធន៍របស់ឪពុកម្តាយរបស់ខ្លួន ។ សុភ័ក្រ បន្ថែមទៀតថា «ការសិក្សានេះនឹងផ្តល់នូវចំណេះដឹងពិតប្រាកដពីរបបខ្មែរក្រហមដល់សិស្សដែលមិនដែលជឿថាមានរបបខ្មែរក្រហម» ។

ការរៀនពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមគឺពិតជាសំខាន់ ដូច្នេះក្មេងជំនាន់ក្រោយអាចទប់ស្កាត់របបនេះបាននាថ្ងៃអនាគត ។ សុភ័ក្រ បានបន្ថែមទៀតថា «មិនមែនតែប្រទេសកម្ពុជាទេ ប្រទេសដទៃទៀតក៏គេបង្រៀនកូនចៅរបស់គេពីប្រវត្តិសាស្ត្រដែរ ។ យើងមិនគួរមើលរំលងទេ ហើយគួរតែប្រមែប្រមូល និងចងក្រងរាល់ភស្តុតាងទាំងអស់ដែលកើតឡើងក្នុងអំឡុងពេលរបបខ្មែរក្រហម» ។ សុភ័ក្របានគាំទ្រយ៉ាងពេញទំហឹងដល់វេទិកាសាធារណនេះ ។ អ្វីដែលបានធ្វើឲ្យ សុភ័ក្រ មានការចាប់អារម្មណ៍បំផុតនោះគឺថា វេទិកាសាធារណៈនេះបានធ្វើនៅក្នុងទីជនបទដាច់ស្រយាល ។ គាត់បន្ថែមថាវេទិកាសាធារណៈនេះពិតជាជួយដល់ប្រជាជននៅតាមទីជនបទឲ្យបានរៀនពីប្រវត្តិសាស្ត្រ ។ សុភ័ក្រ និយាយថា «ឥឡូវសិស្សបានរៀនពីប្រវត្តិសាស្ត្រនៅក្នុងភូមិរបស់ខ្លួនផ្ទាល់ ដែលពីមុនសិស្សទាំងនោះបានឮតាមរយៈតែឪពុកម្តាយរបស់ខ្លួនប៉ុណ្ណោះ» ។


វេទិកាសាធារណៈនៅខេត្តបន្ទាយមានជ័យ

**លី សុខចំរើន**

# អតីតទាហានខ្មែរក្រហមតស៊ូក្នុងជំរំបឹងអំពិល

មានស្រុកកំណើតនៅសៀមរាប ហាស ខឿន បានចូលបម្រើបដិវត្តន៍ និងបម្រើចលនាតស៊ូមិនមែនកុម្មុយនីស្តដែលដឹកនាំដោយ សឺន សាន តាំងពីទសវត្សរ៍៨០ ។ ខឿន បានពិការភ្នែកម្ខាង និងជើងរបួសដោយសារការប្រយុទ្ធនៅសមរភូមិ ។

ហាស ខឿន សព្វថ្ងៃរស់នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ឪពុករបស់គាត់ឈ្មោះ ហាស សី ស្លាប់ និងម្ដាយឈ្មោះ សាន ។ ក្នុងឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ ខឿន ត្រូវបានជម្លៀសឲ្យទៅរស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នៅទីនោះ ខឿន ត្រូវបានអង្គការចាត់តាំងឲ្យកាប់ដីនិងធ្វើស្រែ ។ ប៉ុន្តែចំពោះការហូបចុកវិញគឺមិនគ្រប់គ្រាន់ទេ មួយរយៈក្រោយមកក៏បណ្ដាលឲ្យប្រជាជនមួយចំនួនធ្លាក់ខ្លួនឈឺនិងខ្លះទៀតស្លាប់តែម្ដង ។ ការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនទាំងអស់តែងតែមានការភ័យខ្លាចដោយ ខឿន តែងតែឃើញមនុស្សបាត់ខ្លួនជាបន្តបន្ទាប់ ។ ហេតុដូច្នេះហើយ ទោះបីជាធ្វើការអស់កម្លាំងឬឈឺយ៉ាងណាក៏ ដោយ ក៏ ខឿន មិនហ៊ានសុំច្បាប់ឈប់សម្រាកឡើយ ។

នៅពេលរដូវច្រូតបានចូលមកដល់ ដោយសារតែ ខឿន ឃ្លានខ្លាំងពេក ថ្ងៃមួយគាត់ក៏បានដើរសំដៅទៅវាលស្រែដើម្បីលួចស្រូវហូប ។ ខណៈពេលនោះ កងឈ្លបក៏បានដើរទៅវាលស្រែដើម្បីរក ខឿន ។ ខឿន មានការភ័យតក់ស្លុតជាខ្លាំង បន្ទាប់មកក៏រត់ទៅពួននៅក្នុងពំនូកចំបើង ពេលដែលស្ងាត់ទើបត្រឡប់ទៅកាន់សហករណ៍វិញ ។ ខឿន បានរៀបរាប់ថា ថ្ងៃមួយ វឿន ជាប្រធានកងចល័តស្រុកបានសួរទៅគាត់និងថាតើមាននរណាចង់ធ្វើជាយោធាទេ?» ខណៈពេលនោះ ខឿន ក៏បាននិយាយថាស្ម័គ្រចិត្តធ្វើជាយោធាព្រោះតែនឹកឃើញថាការរស់នៅប្រហែលជាស្រួលជាងប្រជាជនធម្មតា ។ បន្ទាប់មក ខឿន ក៏បានធ្វើដំណើរជាមួយ វឿន រហូតមកដល់កន្លែងមួយ អង្គការក៏បានសួរពីប្រវត្តិរូបរបស់គាត់ថា «មិត្តអ្នក! ជាពួកនាយទុន ឬកសិករ?» ក្រោយមក ខឿន ក៏បានប្រាប់ទៅកាន់អង្គការថា «ខ្ញុំជាកសិករទេ» ។ មិនយូរប៉ុន្មាន ខឿន ត្រូវបានអង្គការចាត់តាំងឲ្យគាត់ធ្វើជាយោធាស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈស្រុកឈ្មោះ អឿន ដោយមានតួនាទីជាអ្នកការពារនិងយាមចម្ការពោតដែលមានទំហំប្រហែល ១០ហិកតាជាមួយសមាជិក១៥នាក់ទៀត ។ ខឿន នៅចងចាំថា ថ្ងៃមួយដោយសារតែមានការធ្វេសប្រហែស ស្រាប់តែមានបុរសម្នាក់បានចូលមកលួចកាច់ពោតនៅក្នុងចម្ការ ។ ក្រោយពីចាប់ខ្លួនបុរសនោះបានហើយ អង្គការក៏យកគាត់ទៅសម្លាប់ចោលនៅក្នុងព្រៃបាត់ ។ ក្រោយហេតុការណ៍នេះ អង្គការបានផ្លាស់ ខឿន ឲ្យទៅរស់នៅភូមិវៀនភាគខាងជើងស្រុកវ៉ារិនខេត្តសៀមរាបវិញ ។

នៅទីនោះ ខឿន ត្រូវបានអង្គការចាត់តាំងឲ្យមើលការខុសត្រូវនៅកងចល័ត ។ ធ្វើការបានមួយរយៈ ខឿន ក៏បានជួបបងប្រុសរបស់គាត់ឈ្មោះ សាន់ ដោយគាត់មានតួនាទីជាអ្នកគ្រប់គ្រងសមាជិកកងចល័តមានសមាជិកចំនួន៥០០នាក់ ។ ថ្ងៃមួយដោយសារតែ ខឿន ឃើញមនុស្សជាច្រើននាក់មិនមានអាហារហូបគ្រប់គ្រាន់ គាត់ក៏បានយករបបអាហាររបស់គាត់ទៅចែកជូនប្រជាជននៅទីនោះ ។ ប៉ុន្តែក្រោយមក ដោយសារគណៈស្រុកដឹងពីដំណឹងនេះ គាត់ក៏បញ្ជូន ខឿន ឲ្យទៅរស់នៅ


ហាស ខឿន

ភូមិគោកដូងនៅស្រុកសៀមរាបវិញ ។ នៅទីនោះបានរយៈពេលបីថ្ងៃ ខឿន ក៏បានឃើញមនុស្សចំនួន៣០០នាក់ ត្រូវបានអង្គការដាក់ខ្នោះជើងនៅក្នុងបន្ទប់មួយ ។ មិនយូរប៉ុន្មាន ខឿន បានក្លាយជាអ្នកបើកឡានជូនប្រពន្ធរបស់គណៈស្រុកឈ្មោះ ស៊ន ទៅបាត់ដំបងដើម្បីចូលរួមប្រជុំ ។ ដោយឃើញអ្នកទោសទាំងនេះទទួលទុក្ខលំបាកខ្លាំងពេក ថ្ងៃមួយ ខឿន ក៏បានរៀបរាប់ប្រាប់ប្រពន្ធរបស់ ស៊ន អំពីអ្នកទោសដែលត្រូវបានជាប់ឃុំ ព្រមទាំងជូនគាត់ទៅមើលកន្លែងឃុំខ្លួនអ្នកទោសទៀតផង ។ ក្រោយពីគណៈស្រុកឈ្មោះ អឿន បានដឹងពីដំណឹងនេះហើយ គាត់ក៏បានស្តីបន្ទោសឲ្យ ខឿន ថា «ហេតុអ្វីបានជាហ៊ានទៅមើលអ្នកទោស?» ខឿន មិនត្រឹមតែមិនខ្លាច អឿន យកទៅសម្លាប់ទេថែមទាំងនិយាយប្រាប់ថាអាណិតអ្នកទោសទាំងនេះទៀតផង ។ ក្រោយពីទទួលការស្តីបន្ទោសហើយ អឿន បានផ្លាស់ ខឿន ឲ្យទៅធ្វើការនៅកងចល័តថ្មីមួយទៀត ។ នៅយប់មួយ ខឿន ត្រូវបានអង្គការចាត់តាំងជាអ្នករត់សំបុត្រនៅក្នុងភូមិគោកដូង ។ ទោះបីជា ខឿន ជាអ្នករត់សំបុត្របញ្ជូនទៅដល់គណៈស្រុកក៏ដោយ ក៏គាត់មិនហ៊ានបើកមើលដែរ ។ ក្រោយពីបានទទួលសំបុត្រ ខឿន ក៏បានជិះសេះយកសំបុត្រទៅជូនគណៈស្រុកភ្លាម ។ ពេលត្រឡប់មកវិញគាត់ក៏បានឃាត់ ខឿន នៅរង់ចាំហូបបាយឲ្យរួចសិនទើបត្រឡប់ទៅកាន់សហករណ៍វិញ ។ ពេលមកដល់សមាជិកកងនារីជាច្រើននាក់ក៏បាននាំគ្នាលួចខ្សឹបប្រាប់ថា «បន្តិចទៀតសភាពការណ៍មិនស្រួលទេ ត្រូវនាំគ្នារត់ចេញពីសហករណ៍» ។ ខឿន បានបន្ថែមថា «នៅពេលយប់មួយគាត់បានឃើញកម្មាភិបាលខ្មែរក្រហមបណ្តើរមនុស្សជាជួរៗយកទៅសម្លាប់ចោលនៅក្នុងអន្លង់ដ៏ធំមួយ ។ ពេលនោះ ខឿន មានការភ័យខ្លាចជាខ្លាំងព្រោះថាមិនដឹងថាពេលណាដល់វេនគាត់ដែរនោះទេ ។

ក្នុងឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមចូលមករំដោះ ខឿន ក៏បានសម្រេចចិត្តមកធ្វើទាហានប៉ារ៉ាដឹកនាំដោយ សឺន សាន វិញ ។ នៅទីនោះ ខឿន មានតួនាទីជាអ្នកដឹកនាំទាហានកងវរយនិងគ្រប់គ្រងទាហាននៅក្នុងជំរំបឹងអំពិល ក្រោមការគ្រប់គ្រងផ្ទាល់របស់មេដឹកនាំឈ្មោះ គ្រឹង ។ មួយរយៈក្រោយមក ខឿន និងទាហានជាច្រើននាក់ទៀតក៏បានប្រយុទ្ធនៅបន្ទាយឆ្មារស្រុកថ្មពួកហើយក៏ចាប់បានរថក្រោះពីរគ្រឿងនិងឡានដឹកទឹកពីរ ។ ប៉ុន្តែក្រោយមក ខឿន ក៏មានរបួសដោយសារត្រូវគ្រាប់កាំភ្លើងនៅត្រង់ភ្នែកខាងស្តាំនិងពោះ ។

ចាប់តាំងពីសង្គ្រាមបានបញ្ចប់ទៅ ខឿន ក៏បានសម្រេចចិត្តទៅរស់នៅខេត្តបន្ទាយមានជ័យនិងចាប់ផ្តើមកសាងជីវភាពថ្មីជាមួយនឹងប្រពន្ធរបស់គាត់ ដោយប្រកបមុខរបរធ្វើស្រែចម្ការរហូតមកសព្វថ្ងៃនេះ ។ **ស៊ិន សុធីតា**

# ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦.៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីសង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិសាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# ពិព័រណ៍ "រូបថតថ្ងៃ១៧មេសា"

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតាំងពិព័រណ៍រូបថតមួយដែលមានចំណងជើងថា «រូបថតថ្ងៃ១៧មេសា» នៅការិយាល័យព័ត៌មានសាធារណៈនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពិព័រណ៍នេះបានចាប់បើកជាសាធារណៈចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ នេះតទៅ ហើយគ្រោងនឹងបញ្ចប់នៅបំណាច់ខែកក្កដាខាងមុខនេះ ។

ពិព័រណ៍ «រូបថតថ្ងៃ១៧មេសា» នេះបានដាក់តាំងនូវរូបថតសខ្មៅចំនួន១៧សន្លឹកថតដោយអ្នកសារព័ត៌មានបារាំងឈ្មោះ រ៉ូឡង់ នីវើ (Roland Neveu) និងអ្នកសារព័ត៌មានអាមេរិកឈ្មោះ អាល់ រ៉កខហ្វ (Al Rockoff) និងរូបថតមួយចំនួននៅក្នុងប័ណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រូបថតទាំង១៧សន្លឹកនេះត្រូវបានជ្រើសរើសមកដាក់តាំងបង្ហាញដើម្បីឲ្យអ្នកទស្សនាអាចរំឭកទៅដល់ព្រឹត្តិការណ៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ និងជាថ្ងៃចាប់ផ្ដើមនៃការកាន់កាប់របស់ខ្មែរក្រហម ។

ថ្ងៃ១៧ មេសា ១៩៧៥ ជាថ្ងៃដែលប្រជាពលរដ្ឋខ្មែរចងចាំមិនអាចបំភ្លេចបានចំពោះភាពក្រឡាប់ចាក់នៃសភាពការណ៍នៅក្នុងប្រទេស ។ នៅពេលដែលប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញកំពុងសប្បាយរីករាយនឹងជ័យជម្នះរបស់ខ្មែរក្រហម ហើយសង្ឃឹមថាសង្គ្រាមរ៉ាំរ៉ៃដែលបន្តមកជាច្រើនឆ្នាំបានបញ្ចប់ទៅនោះ យោធាខ្មែរក្រហមចាប់ផ្ដើមប្រកាសតាមខ្សែសំឡេងឲ្យប្រជាជននៅក្នុងទីក្រុងទាំងអស់ចាកចេញពីលំនៅដ្ឋានទៅជនបទនានាទូទាំងប្រទេស ។ យោធាខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនឲ្យចាកចេញពីទីក្រុងដោយបន្ទាន់ដោយគ្មានយោគយល់ដល់អ្នកជំងឺ ចាស់ជរា ក្មេងកំព្រា ស្ត្រីទើបសម្រាលកូន ឬជនពិការឡើយ ដោយសម្អាងថា អាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅក្នុងទីក្រុង ។ ខ្មែរក្រហមបានបោកប្រាសប្រជាជនទីក្រុងជាងបីលាននាក់ថានឹងអនុញ្ញាតិឲ្យវិលត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ ផ្ទុយពីសេចក្ដីប្រកាសរបស់ខ្មែរក្រហម ប្រជាជនដែលបានចាកចេញពីទីក្រុងទាំងអស់ មិនដែលបានវិលត្រឡប់មកលំនៅដ្ឋានវិញ រហូតដល់របបនេះដួលរលំទៅនៅខែមករា ឆ្នាំ១៩៧៩ ។ មនុស្សជាច្រើននាក់មិនមានឱកាសត្រឡប់មកផ្ទះវិញទាល់តែសោះ ។ ក្រោមការកាន់កាប់របស់ខ្លួន ខ្មែរក្រហមបានបង្កឲ្យប្រជាជនកម្ពុជាប្រមាណ



រូបថត ៖ រ៉ូឡង់ នីវើ



ជិតពីរលាននាក់ស្លាប់ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ។

ពិព័រណ៌ «រូបថតថ្ងៃ១៧មេសា» នេះមានបំណងឆ្លុះបញ្ចាំងឲ្យឃើញនូវទិដ្ឋភាពទាំងអស់នេះ ។ ទន្ទឹមនឹងរូបថតដែលបង្ហាញពីការចូលមកដល់របស់យោធាខ្មែរក្រហម ការអបអរសាទរនៃជ័យជម្នះរបស់ខ្មែរក្រហម រូបថតខ្លះទៀតបានបង្ហាញពីការជម្លៀសមន្ត្រីស្ថានទូតសហរដ្ឋអាមេរិកតាមយន្តហោះ ការជម្លៀសប្រជាជនចេញពីទីក្រុងតាមមហាវិថីព្រះមុន្នីវង្ស រថយន្តកាកបាទក្រហមដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរចូលស្ថានទូតបារាំងដើម្បីស្វែងរកទីសុវត្ថិភាព ការទម្លាក់អាវុធរបស់កងទ័ព លន់ នល់ ក្រោមការត្រួតពិនិត្យរបស់យោធាខ្មែរក្រហម និងទិដ្ឋភាពផ្សេងៗដែលបង្ហាញពីសោកនាដកម្មរបស់ប្រជាជនកម្ពុជានៅថ្ងៃនោះ ។ លើសពីនេះទៅទៀត ពិព័រណ៌នេះក៏បានជ្រើសរើស និងដកស្រង់យកសាច់រឿងរបស់អ្នកដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហមម្នាក់ ហើយបានឆ្លងកាត់ព្រឹត្តិការណ៍ថ្ងៃ១៧ មេសា នេះ មកដាក់តាំងបង្ហាញដើម្បីឆ្លុះបញ្ចាំងពីរឿងរ៉ាវមួយក្នុងចំណោមរឿងរ៉ាវជាច្រើនទៀតដែលបានកើតឡើងនៅកំឡុងពេលនោះ ។

ពិព័រណ៌រូបថតនេះដាក់តាំងបង្ហាញ ដើម្បីឲ្យសិស្សានុសិស្ស អ្នកស្រាវជ្រាវ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់បានមកទស្សនា ធ្វើការពិចារណា រំឭកឡើងវិញ និងបង្កើតឲ្យមានការពិភាក្សាអំពីសោកនាដកម្មដែលមិនអាចបំភ្លេចបាននោះ ។ ដោយសារសោកនាដកម្មចាប់ពីថ្ងៃទី១៧ មេសា នេះហើយ ដែលបង្កឲ្យមានការនិរាសព្រាត់ប្រាសគ្រួសារ ការបាត់បង់អ្នកដែលជាទីស្រឡាញ់ និងបន្សល់ទុកនូវកុមារកំព្រារាប់សែននាក់នៅទូទាំងប្រទេស ។ **ស៊ឹរ សាវីណា**






រូបថត ៖ រ៉ូឡង់ នឺវើ

# សវនាការលើបណ្តឹងសាទុក្ខប្រឆាំងនឹងការកាត់ទោស កាំង ហ្គេចអ៊ាវ ហៅ ឌុច

## ១) ប្រវត្តិនៃការកាត់សេចក្តី និងបណ្តឹងសាទុក្ខ

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសបើកសវនការជំនុំជម្រះ កាំង ហ្គេចអ៊ាវ ហៅ «ឌុច» ។ ឌុច គឺជាអនុប្រធាន ហើយបន្ទាប់មកជាប្រធានមន្ទីរឃុំឃាំង ស-២១ នៅភ្នំពេញ ដែលនៅទីនោះមានអ្នកទោសជាង១២០០០នាក់ត្រូវបានធ្វើទារុណកម្ម និងសម្លាប់នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ។ ភាគច្រើននៃអ្នកទោសទាំងនោះគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួនក្នុងយុទ្ធនាការបោសសម្អាតផ្នែកនយោបាយ ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម (ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩) ហើយត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ និងដកប្រាំឆ្នាំសម្រាប់ការដែលសិទ្ធិរបស់គាត់ត្រូវបានរំលោភបំពានដោយសារគាត់ត្រូវបានតុលាការយោធាកម្ពុជាឃុំខ្លួនដោយខុសច្បាប់អស់រយៈពេលជាងប្រាំបីឆ្នាំមុនពេលគាត់ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់ពីដក១១ឆ្នាំដែល ឌុច ត្រូវបានឃុំឃាំងរួច គាត់ត្រូវជាប់ពន្ធនាគាររយៈពេលតិចជាង១៩ឆ្នាំប៉ុណ្ណោះ ។

អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសនៅពេលដែលកំណត់ការផ្តន្ទាទោស ។ ចំពោះស្ថានទម្ងន់ទោស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើភាពធ្ងន់ធ្ងរ ព្រៃផ្សៃនៃបទល្មើស និងមធ្យោបាយនៃការប្រព្រឹត្ត ការមិនអាចប្រឆាំងបានរបស់ជនរងគ្រោះ ការបំពានលើសិទ្ធិអំណាចរបស់ ឌុច និងការទទួលខុសត្រូវចំពោះបទល្មើសរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ ។ ចំពោះស្ថានសម្រាលទោស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើការសហការរបស់ ឌុច ការទទួលស្គាល់កំហុស ការបង្ហាញពីវិប្បដិសារី និន្នាការនៃការស្តារនីតិសម្បទារបស់គាត់ និងស្ថានភាពក្រោមការបង្ខិតបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នេះគឺជាតុលាការកាត់ទោសឧក្រិដ្ឋកម្មទីមួយដែលជនរងគ្រោះដែលបានទទួលរងការឈឺចាប់នៃអំពើឧក្រិដ្ឋកម្មទាំងនេះមានការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកសំណង «ឌុច សមូហភាព និងផ្លូវចិត្ត» ។ ក្នុងចំណោមជនរងគ្រោះ៩០រូប ដែលបានចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ការចេញសេចក្តីសម្រេច ជនរងគ្រោះ២៤រូបត្រូវបានដកសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថាអ្នកទាំងនោះមិនបានបញ្ជាក់យ៉ាងច្បាស់ថាខ្លួន ឬសមាជិកគ្រួសាររបស់ខ្លួនគឺជាជនរងគ្រោះនៅមន្ទីរឃុំឃាំងដែល


ប្រជាជនដើរចេញពីបន្ទប់សវនាការ

គ្រប់គ្រងដោយ ឌុច ឬ «មានទំនាក់ទំនងសាច់ញាតិ និងស្ថិតនៅក្រោមបន្ទុករបស់ជនរងគ្រោះ» នៅមន្ទីរស-២១ ។

ពីថ្ងៃទី២៨ដល់៣០ ខែមីនា អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនការ លើបណ្តឹងសាទុក្ខរបស់ភាគីទាំងបី ។ មេធាវីការពារក្តីបានអះអាងថា ដោយសារតែ ឌុច មិនមែនជា «មេដឹកនាំជាន់ខ្ពស់» នៃរបបខ្មែរក្រហមឬអ្នក «ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច មិនស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដូច្នេះគាត់ត្រូវតែទទួលការដោះលែង ។ សហព្រះរាជអាជ្ញាដែលបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការបង្កើនការផ្តន្ទាទោស បានស្នើឲ្យរួមបញ្ចូលការដាក់ជាទាសករទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងស្នើឲ្យសម្រាលទោសនៅពេលកំណត់ការផ្តន្ទាទោស ។

មេធាវីការពារក្តីបានស្នើឲ្យសម្រេចថាកូនក្តីរបស់ខ្លួនគ្មានទោស ត្រូវដោះលែងជាបន្ទាន់ និងស្នើឲ្យពិចារណាទៅលើពេលវេលាដែលកូនក្តីរបស់ខ្លួនត្រូវបានឃុំខ្លួនតាំងពីឆ្នាំ១៩៩៩ ។ ព្រះរាជអាជ្ញាបានស្នើឲ្យផ្តន្ទាទោសអស់មួយជីវិត គឺត្រូវឃុំខ្លួន ៤៥ឆ្នាំបន្ទាប់ពីកាត់ការឃុំខ្លួនខុសច្បាប់នៅតុលាការយោធាមុនពេលគាត់ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះតុលាការកំពូលជាអ្នកមានអំណាចសម្រេចថា ឌុច គ្មានទោស ឬកាត់បន្ថយទោសរបស់គាត់ ។ សេចក្តីសម្រេចត្រូវបានរំពឹងថានឹងចេញនៅខែមិថុនាខាងមុខនេះ ។

## ២) បញ្ហាអំពីបណ្តឹងសាទុក្ខ

### ២.១) អំណះអំណាងរបស់មេធាវីការពារក្តី

#### ២.១.១) ប្រវត្តិ

នៅគ្រប់សវនការ សហមេធាវីរបស់ ឌុច បានប្រើប្រាស់យុត្តិសាស្ត្រទទួលស្គាល់ការចោទប្រកាន់ ទទួលកំហុសចំពោះបទល្មើសមួយចំនួនធំបង្ហាញវិប្បដិសារី និងសហការជាមួយព្រះរាជអាជ្ញាដើម្បីទទួលការកាត់បន្ថយទោស ។ នៅអំឡុងពេលសវនការ ឌុច បាននិយាយថា គាត់នឹងទទួលការផ្តន្ទាទោសគ្រប់បែបយ៉ាងហើយគាត់នឹងមិនប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទេ ។

យុត្តិសាស្ត្រនេះត្រូវបានផ្លាស់ប្តូរនៅពេលដែល ការសាវុត្ត មេធាវីជាតិរបស់ ឌុច បានផ្លាស់ប្តូរយុត្តិសាស្ត្រដោយលើកឡើងពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើ ឌុច និងអះអាងថា កូនក្តីរបស់គាត់គួរតែគ្មានទោស ។ មុនពេលប្រកាសសាលក្រម ឌុច បានបណ្តេញ ហ្វ្រង់ស្វ័រ រូហ្វ ដែលជាមេធាវីអន្តរជាតិរបស់គាត់ និងជាអ្នកបង្កើតយុត្តិសាស្ត្រសម្រាប់ការពារក្តី និងជំនួសដោយមេធាវីជាតិទីពីរឈ្មោះ កង ប៊ុនឡាវី ។ ក្រុមមេធាវីការពារក្តីបានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដោយលើកពីភាពខ្វះខាតនៃយុត្តាធិការលើបុគ្គល ។

#### ២.១.២) យុត្តាធិកាលើបុគ្គល

##### ២.១.២.១) អំណះអំណាង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយុត្តាធិការលើ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជានៅក្នុងយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះ១៩៧៥-១៩៧៩) ។ នៅក្នុងបណ្តឹងសាទុក្ខ មេធាវីការពារក្តីបានអះអាងថា ឌុច មិនស្ថិតនៅក្នុងប្រភេទនៃក្រុមមនុស្សទាំងនេះទេ ពីព្រោះគាត់មិនមានតួនាទីខ្ពស់នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រឹមតែជាប្រធានមន្ទីរសន្តិសុខម្នាក់ក្នុងចំណោមប្រធានមន្ទីរសន្តិសុខទាំង២០០ដែលមិនមានអំណាចណែនាំបក្សកុម្មុយនីស្តកម្ពុជាអំពីបញ្ហាសន្តិសុខជាតិឬសម្រេចថាត្រូវចាប់អ្នកណា និងសម្លាប់អ្នកណាទេ ។ ក្រុមមេធាវីបានអះអាងថា ឌុច ស្ថិតនៅក្នុងថ្នាក់កណ្តាលនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា និងជាកម្មាភិបាលដែលធ្វើការក្រោមការគម្រាមកំហែង ។ មេធាវីការពារក្តីក៏បានលើកឡើងដែរថា ប្រសិនបើមិនកាត់ទោសប្រធានមន្ទីរសុខផ្សេងទៀត នោះក៏មិនគួរកាត់ទោស ឌុច ដែរ ។ ជាចុងក្រោយ មេធាវីបានស្នើឲ្យដោះលែង ឌុច ។ ឌុច បានគាំទ្រនឹងមេធាវីការពារក្តីរបស់ខ្លួនដែលបានបដិសេធនឹងយុត្តា

ធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់នៃបណ្តឹងសាទុក្ខ ។

ព្រះរាជអាជ្ញាបានឆ្លើយតបដោយផ្ដើកំណត់សម្គាល់ថា នៅក្នុងបរិវេណមន្ទីរស-២១ ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលមានកម្លាំង២៣០០នាក់នៅក្រោមការគ្រប់គ្រងរបស់គាត់ ហើយគាត់មានតួនាទីស្រដៀងនឹងប្រធានកងវរសេនាធំដែរ ។ ជាងនេះទៅទៀតស-២១ គឺជាមន្ទីរសំខាន់ជាងគេនៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដើម្បីសម្លាប់សត្រូវនយោបាយ និងជាមន្ទីរសន្តិសុខ តែមួយដែលមានតួនាទីចាប់កម្មាភិបាលថ្នាក់ខ្ពស់ខ្មែរក្រហម និងទទួលអ្នកទោសបរទេសរួមទាំងវៀតណាមនិងបរទេសមកពីបស្ចិមប្រទេស ។ ព្រះរាជអាជ្ញាក៏បានលើកឡើងពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឌុច មានអំណាចខ្លះក្នុងការសម្រេចអ្នកដែលត្រូវចាប់ខ្លួន សម្លាប់ និងមានតួនាទីដឹកនាំក្នុងការបង្កើនការសម្លាប់នៅប៉ុន្មានឆ្នាំក្រោយមកនៅក្នុងរបបនោះ និងអនុវត្តការងារដោយមានប្រសិទ្ធភាពនិងពេញចិត្ត ។ ចៅក្រមបានសួរថាតើ ឌុច កំពុងតែជំទាស់ថាបទដ្ឋានយុត្តាធិការលើបុគ្គលមានការបែកដាច់ពីគ្នាដែលមានន័យថានៅក្នុងច្បាប់ វាសំដៅទៅលើក្រុមមនុស្សពីរខុសគ្នា «មេដឹកនាំជាន់ខ្ពស់» និង «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ឬមានលក្ខណៈដូចគ្នា និងមានបំណងបង្ហាញពីប្រភេទមនុស្សមួយក្រុមមេដឹកនាំជាន់ខ្ពស់ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត? មេធាវីការពារក្តីឆ្លើយតបថាបទដ្ឋាន គឺមានលក្ខណៈតែមួយ ហើយបើតាមនិយមន័យអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតគឺមេដឹកនាំជាន់ខ្ពស់ ។ ព្រះរាជអាជ្ញាបានឆ្លើយតប ដោយបង្ហាញពីប្រវត្តិនៃកិច្ចព្រមព្រៀង និងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលរួមមានសេចក្តីថ្លែងការណ៍របស់អ្នកជំនាញអង្គការសហប្រជាជាតិដែលបានសរសេររបាយការណ៍ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់បង្កើតតុលាការ និងឧបនាយករដ្ឋមន្ត្រី សុខ អាន ។ មាត្រា២នៃច្បាប់នោះមានរួមបញ្ចូលមនុស្សពីរក្រុម ។

ទាក់ទងនឹងការចោទប្រកាន់ដោយជ្រើសរើស ឬការអះអាងរបស់មេធាវីការពារក្តី ព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថាខណៈពេលដែលរាល់មនុស្សទាំងអស់មានភាពស្មើគ្នានៅមុខច្បាប់ វាមិនអាចបញ្ជាក់ថានឹងមិនមាននរណាម្នាក់ត្រូវបានកាត់ទោសប្រសិនបើអ្នកដទៃទៀតដែលប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នាមិនត្រូវបានកាត់ទោសទេ ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ទៅលើចំណុចពិសេសរបស់ ស-២១ ថាជាផ្នែកមួយរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលធ្វើឲ្យមន្ទីរសន្តិសុខនេះខុសពីគេ និងមានសារៈសំខាន់ជាងគេក្នុងចំណោមមន្ទីរសន្តិសុខផ្សេងទៀត ទោះបីជាមានមនុស្សច្រើនជាងនេះស្លាប់នៅក្នុងមន្ទីរសន្តិសុខដទៃក៏ដោយ ។

នៅពេលជជែកតទល់ពីយុត្តាធិការ មេធាវីការពារក្តីហាក់ដូចជាអះអាងថានៅក្រោមច្បាប់កម្ពុជា មានតែអ្នកដែលបញ្ជាឧក្រិដ្ឋកម្មគឺជាអ្នកត្រូវទទួលខុសត្រូវ ។ ជាក់ស្តែង មេធាវីការពារក្តីបានលើកឡើងពីមាត្រា២៨នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលចែងថា «អ្នកបង្កហេតុ» គឺជាអ្នកដែលបញ្ជា ឬណែនាំដើម្បីបង្កឲ្យមានឧក្រិដ្ឋកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រមនេះមិនមានប្រសិទ្ធភាពនៅក្នុងយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។

### ២.១.២.២) ភាពដែលអាចទទួលយកបាន

ព្រះរាជអាជ្ញាបានអះអាងថាការអះអាងរបស់មេធាវីការពារក្តីអំពីយុត្តាធិការលើបុគ្គលមានសារៈសំខាន់ពីព្រោះវាមិនត្រូវបានលើកឡើងនៅក្នុងសវនាការបឋមដូចដែលវិធាន៨៩(១)របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវទេ ។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ចំណុចនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ ព្រះរាជអាជ្ញាបានលើកឡើងថានៅពេលដែលអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យមានការបញ្ជាក់បន្ថែមនៅពេលចាប់ផ្តើមសវនការ សហមេធាវីជាតិបាននិយាយថា «ខ្ញុំនឹងមិននិយាយពីយុត្តាធិការរបស់តុលាការទេ ពីព្រោះខ្ញុំយល់ហើយ ហើយប្រសិនបើខ្ញុំចង់លើកឡើងពីចំណុចនេះ ខ្ញុំនឹងលើកឡើងតាំងពីនៅក្នុងសវនការបឋមមកម្ល៉េះ» ។

មេធាវីការពារក្តីបានអះអាងថាខ្លួនបានលើកឡើងពីអំណះអំណាងទាក់ទងនឹងយុត្តាធិការ «នៅអំឡុងពេលដំណើរការនីតិវិធី ទោះបីជាខ្លួនមិនចាំថាបាននិយាយនៅពេលណាឲ្យ

ច្បាស់ក៏ដោយ ។ មេធាវីការពារក្តីក៏បានអះអាងថា វិធាន៨៩មិនអាចគ្រប់គ្រងទៅលើវិធាន៨៧ដែលទទួលស្គាល់ភាពដែលអាចទទួលយកបានរាល់ភស្តុតាងដាក់បន្ទុក ។ ព្រះរាជអាជ្ញាបានឆ្លើយតបថាអង្គជំនុំជម្រះសាលាដំបូងមិនបានខកខានពិចារណាទៅលើរាល់ភស្តុតាងដែលពាក់ព័ន្ធទេ ។

## ២.១.២.៣) ច្បាប់កាត់ទោស

នៅក្នុងសវនាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានស្នើថារាល់ភាគីគួរតែផ្តោតទៅលើអំណះអំណាងដែលថា «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត» នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងកិច្ចព្រមព្រៀង អាចបង្កើតជាសេចក្តីតម្រូវខាងយុត្តាធិការដែលតម្រូវឲ្យមានការពិនិត្យរបស់តុលាការឬជាការណែនាំមួយសម្រាប់ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេតដែលមិនតម្រូវឲ្យមានត្រួតពិនិត្យរបស់តុលាការ ។ ព្រះរាជអាជ្ញាបានប្រកាន់ជំហរថាសេចក្តីសម្រេចគឺជាបញ្ហាឆន្ទានុសិទ្ធិសម្រាប់កាត់ទោស ប៉ុន្តែវាមិនបានផ្តល់អំណាចអ្វីទេ ។

នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ជនត្រូវចោទបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ ហើយតាមពិត ដោយពាក្យ «តុលាការពិសេស គួរតែមានអំណាចចោទប្រកាន់មនុស្សដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត» មាត្រា១(១) នៃលក្ខន្តិកៈរបស់តុលាការ មិនមែនជាសេចក្តីតម្រូវខាងច្បាប់ទេ ។ បន្ទាប់ពីពិនិត្យទៅលើភាពឯករាជ្យស្របច្បាប់ និងមុខងាររបស់ព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនយល់ស្របនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការតម្រូវឲ្យមាន «ការទទួលខុសត្រូវខ្ពស់បំផុត» គឺជាការណែនាំសម្រាប់នាំទៅរកការប្រើប្រាស់ឆន្ទានុសិទ្ធចោទប្រកាន់ ប៉ុន្តែវាមិនមែនជាសេចក្តីតម្រូវខាងច្បាប់ដែលតម្រូវឲ្យមាននៅពេលចាប់ផ្តើមទេ ។

វាមិនគួរឲ្យជឿដែលថាបន្ទាប់ពីការកាត់ក្តីដែលចំណាយពេលដ៏យូរនិងថវិកាជាច្រើន អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានថាទោះបីជាការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរត្រូវបានបង្កើតឡើងលើសពីវិមតិសង្ស័យប្រឆាំងនឹងជនត្រូវចោទក៏ដោយ ក៏សេចក្តីសម្រេចត្រូវតែដំណើរការ ពីព្រោះមិនមានការបញ្ជាក់ថាជនត្រូវចោទមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ការបកស្រាយរបស់ជនត្រូវចោទទាក់ទងនឹងមាត្រា១ នៃលក្ខន្តិកៈគឺជាការប៉ុនប៉ងមួយដើម្បីបញ្ចៀសនូវការទទួលខុសត្រូវចំពោះបទល្មើសដែលតុលាការបានរកឃើញ ។

## ២.១.២.៤) គោលការណ៍ច្បាប់

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានស្នើឲ្យមេធាវីការពារក្តីបកស្រាយដោយសង្ខេបពី «ភាពគ្មានបទល្មើសគ្មានច្បាប់ចែង» នៅក្នុងបណ្តឹងឧទ្ធរណ៍ ។ ដោយអនុលោមទៅតាមគោលការណ៍ច្បាប់ អង្គជំនុំជម្រះអាចត្រឹមតែសម្រេចឲ្យបុគ្គលទទួលខុសត្រូវចំពោះបទល្មើសដែលកើតឡើងនៅពេលនោះទេ ។ មេធាវីការពារក្តី ឌុច បានលើកសម្អាងគោលការណ៍ជាច្រើននៅក្នុងសារណារបស់ខ្លួន ប៉ុន្តែការជជែកតទល់ហាក់ដូចជាមិនច្បាស់លាស់ ហើយមេធាវីការពារក្តីក៏មិនបានបញ្ជាក់ម្តងទៀតនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ដែរ ។ វាមិនមានភាពច្បាស់លាស់ដែលថាមេធាវីការពារក្តីកំពុងតែលើកអំណះអំណាងពីភាពគ្មានបទល្មើសគ្មានច្បាប់ចែង ។ ពេលខ្លះ មេធាវីការពារក្តីហាក់ដូចជាកំពុងតែជំទាស់ពីភាពទូទៅដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានឬធ្វើការហួសពីអំណាចដែលបានផ្តល់នៅក្នុងមាត្រា១និង២នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ឧទាហរណ៍ មេធាវីការពារក្តីបានលើកឡើងថាបទបញ្ញត្តិមួយចំនួនរបស់ច្បាប់កម្ពុជាបានការពារ ឌុច ពីការចោទប្រកាន់ ប៉ុន្តែវាមិនត្រូវបានយកមកពិចារណាទេ ។ ច្បាប់ទាំងនោះរួមមានច្បាប់ស្តីពីការដាក់ឲ្យនៅក្រៅច្បាប់នូវក្រុមកម្ពុជាប្រជាធិបតេយ្យខែកក្កដា១៩៩៤ ដែលលើកលែងការកាត់ទោសកម្មាភិបាលខ្មែរក្រហមដែលចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា នៅអំឡុងពេលប្រាំមួយខែនៃពេលអនុវត្តច្បាប់ និងសន្ធិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលបាន «លើកលែងទោស» ឲ្យគ្រប់ខ្មែរក្រហមនិងបញ្ជាក់ថា «អ្នកទាំងនោះមិនត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មផ្សេងទៀតទេ» ។ ជាងនេះទៅទៀត មេធាវីការពារក្តីបានអះអាង

ថាសហចៅក្រមស៊ើបអង្កេតបានរកឃើញគោលការណ៍ «៥០ លើ ៥០» ដែលថា ឌុច ស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ពីព្រោះសហចៅក្រមស៊ើបអង្កេតបាននិយាយថា «ឌុច ប្រហែលជាត្រូវបានចាត់ទុកនៅក្នុងក្រុមនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត» ហើយការនិយាយបែបនេះបង្ហាញពីការរំលោភទៅលើសេចក្តីតម្រូវក្នុងការដោះស្រាយសំណុំរឿងដែលជាប្រយោជន៍របស់ជនត្រូវចោទ ។ មេធាវីការពារក្តីក៏បានលើកឡើងថា ខណៈពេលដែលតុលាការក្នុងស្រុកប្រើប្រាស់ច្បាប់ស៊ីវិល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចសម្អាងយ៉ាងសមរម្យទៅលើលិខិតុបករណ៍អន្តរជាតិ នៅពេលដែលច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចដោះស្រាយបញ្ហា ហើយមានតែលិខិតុបករណ៍បែបនេះមានលក្ខណៈ «ស្របនឹងប្រព័ន្ធជាតិ» ។ ជាងនេះទៅទៀត មេធាវីការពារក្តីបានសង្កត់ធ្ងន់ថា វាមានលក្ខណៈមិនសមស្របដែលអង្គជំនុំជម្រះសាលាដំបូង «បកស្រាយច្បាប់» ដោយប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលទាញចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ឬប្រើប្រាស់ផ្នែកខ្លះនៃប្រព័ន្ធច្បាប់ខមិនឡ ។ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានសម្អាងទៅលើច្បាប់សំណុំរឿងអន្តរជាតិមុននឹងពិចារណាជាដំបូងទៅលើច្បាប់កម្ពុជាគឺក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នៅក្នុងទស្សនៈរបស់មេធាវីការពារក្តីគឺអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់អំណាចហួសនៅក្រោមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងរដ្ឋធម្មនុញ្ញកម្ពុជា ។

## ២.២) ព្រះរាជអាជ្ញា

### ២.២.១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

#### ២.២.១.១) បទល្មើសបន្ថែម

នៅក្នុងសេចក្តីសម្រេច អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ឌុច មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិសម្រាប់អំពើមនុស្សឃាត និងការសម្លាប់រង្គាល ការដាក់ជាទាសករ ការឃុំឃាំង ឧក្រិដ្ឋកម្មប្រឆាំងមនុសជាតិផ្សេងទៀត និងការធ្វើទុក្ខបុកម្នេញ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ឌុច បានប្រព្រឹត្តបទល្មើសនីមួយៗទៅលើជនរងគ្រោះដោយចេតនាដោយមូលហេតុនយោបាយដែលត្រូវបានចោទប្រកាន់ថាក្បត់បក្សកុម្មុយនីស្តកម្ពុជា ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្មតថាគ្រប់បទល្មើសប្រឆាំងមនុស្សជាតិ ស្ថិតនៅក្រោមបទល្មើសនៃការធ្វើទុក្ខបុកម្នេញ ហើយត្រូវរួមបញ្ចូលជាការចោទប្រកាន់តែមួយ ។

ព្រះរាជអាជ្ញាបានអះអាងថា នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសច្បាប់ដោយមិន



ទិដ្ឋភាពក្នុងសវនាការបណ្តឹងសាទុក្ខនៃសំណុំរឿង០០១ (រូបថត អ.វ.ត.ក)

បានចោទប្រកាន់ ឌុច ពីបទល្មើសនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានបង្កើតឡើង ប៉ុន្តែបែរជារួមបញ្ចូលទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិសម្រាប់ការធ្វើទុកបុកម្នេញតែមួយ ។ ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសប្រឆាំងនឹងយុត្តិសាស្ត្រអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលបានបង្កើតឡើងយ៉ាងល្អ ដូចដែលបង្កើតឡើងនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងករណី សេលីប៊ីស៊ី ។ នៅក្នុងសំណុំរឿងនេះ ៖

ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌជាច្រើនដែលស្ថិត

នៅក្រោមបទបញ្ញត្តិច្បាប់ផ្សេងគ្នា ប៉ុន្តែផ្អែកទៅតាមការប្រព្រឹត្តដូចគ្នាអាចត្រូវទទួលយកបាននៅពេលដែលរាល់បទបញ្ញត្តិដែលជាប់ពាក់ព័ន្ធមានធាតុផ្សំដាច់ពីគ្នាគឺមិនមាននៅក្នុងធាតុផ្សំដទៃ ។ ធាតុផ្សំមួយមានភាពខុសពីគេនៅពេលដែលវាតម្រូវឲ្យមានភស្តុតាងដាច់ដោយឡែក ។

ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ថាមានធាតុផ្សំដាច់ពីគ្នានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលរកឃើញដោយអង្គជំនុំជម្រះសាលាដំបូង និងស្នើឲ្យអង្គជំនុំជម្រះតុលាការ



កំពូលកាត់ទោសបទល្មើសនីមួយៗផ្សេងពីគ្នា ។ នៅក្នុងទស្សនៈរបស់ព្រះរាជអាជ្ញា មានតែការកាត់ទោសដាច់ពីគ្នាទើបអាចឆ្លុះបញ្ចាំងបទល្មើសរបស់ ឌុច និងផ្តល់កំណត់ត្រាប្រវត្តិសាស្ត្រត្រឹមត្រូវសម្រាប់ការផ្សះផ្សាជាតិ ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រមដែលថាតើយុត្តិសាស្ត្រនោះអាចជះឥទ្ធិពលដល់ការផ្តន្ទាទោសដោយរបៀបណា? ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលអាចឲ្យផ្តល់ការផ្តន្ទាទោសជាពិភពលោក ឬអាចផ្តន្ទាទោសប៉ុន្មានឆ្នាំបន្ថែមចំពោះរាល់បទល្មើស ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់បន្ថែមថា នៅក្រោមយុត្តិសាស្ត្រអន្តរជាតិ ចេតនារើសអើងគឺជាស្ថានទម្ងន់ទោសដែលអង្គជំនុំជម្រះគួរតែពិចារណានៅពេលសម្រេចផ្តន្ទាទោស ។

ក្រុមមេធាវីការពារក្តីបានអះអាងថា កូនក្តីរបស់គាត់បានណែនាំគាត់មិនឲ្យឆ្លើយតបនឹងការលើកឡើងរបស់ព្រះរាជអាជ្ញាពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែក្រុមមេធាវីការពារក្តីបានធ្វើសេចក្តីឆ្លើយតបដោយសង្ខេប ។ ជាទូទៅ មេធាវីការពារក្តីតែងតែធ្វើកំណត់សម្គាល់ថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ មានរួមបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូច្នេះអង្គជំនុំជម្រះមិនគួរប្រើប្រាស់ការបកស្រាយដោយផ្អែកលើខមិនឡដែលដើរតាមយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិទេ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចប្រើប្រាស់ក្រម២០០៩ដោយផ្ទាល់ទេ ពីព្រោះវាត្រូវបានអនុម័តក្រោយពេលយុត្តាធិការបណ្តោះអាសន្នរបស់តុលាការ១៩៧៥-១៩៧៩) ។ ជាងនេះទៅទៀត ក្រមនេះក៏មិនបានផ្តល់សេចក្តីណែនាំស្តីពីបញ្ហានៃការបន្ថែមបទល្មើស ហើយក៏មិនមាននរណាម្នាក់ធ្លាប់ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយមាត្រា១៨៨នៃក្រមនេះដែរ ។ ជាទូទៅ មេធាវីការពារក្តីតែងតែអះអាងថា ច្បាប់អន្តរជាតិមិនអាចយកមកប្រើប្រាស់ចំពោះបុគ្គលទេ គឺអាចយកមកប្រើប្រាស់ចំពោះតែរដ្ឋនៅក្នុងយុត្តាធិការបណ្តោះអាសន្នរបស់តុលាការទេ ដូច្នេះមានតែមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលជាអ្នកតំណាងរដ្ឋាភិបាលទេដែលអាចត្រូវបានកាត់ទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការអះអាងនេះ មានភាពផ្ទុយពីច្បាប់ក្រោយសង្គ្រាមលោកលើកទី២ ដែលត្រូវបានតាក់តែងឡើងយ៉ាងល្អ ។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងត្រូវបានយកមករៀបរាប់នៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ចាប់តាំងពីមានធម្មនុញ្ញនូរឹមបឺក មិនសូវជាមានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងការហាមឃាត់អំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវរបស់បុគ្គលលើបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត ។

### ២.២.១.២) ការរំលោភគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្ម

ទោះបីជានៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់អន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការរំលោភគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ពីគ្នាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងសម្រេចថាករណីរំលោកនៅមន្ទីរស-២១ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្ម ។ ព្រះរាជអាជ្ញាបានអះអាងថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភគួរតែយកមកកាត់ទោសដាច់ដោយឡែកពីគេ ។ ព្រះរាជអាជ្ញាបានអះអាងថាការធ្វើបែបនេះមិនអាចរំលោភទៅលើភាពគ្មានបទល្មើសគ្មានច្បាប់ចែងទេ ពីព្រោះ គោលការណ៍នេះមិនតម្រូវថាសកម្មភាពមួយត្រូវតែប្រព្រឹត្តឡើងនៅពេលតែមួយ នៅពេលដែលឧក្រិដ្ឋភាពនៃបទល្មើសអាចត្រូវបានរំពឹងទុកឃើញ និងមានច្បាប់ដែលអាចដាក់ទោសព្រហ្មទណ្ឌដល់ជនត្រូវចោទ ។ បន្ទាប់មក ព្រះរាជអាជ្ញាបានបង្ហាញពីប្រវត្តិដ៏វែងទាក់ទងនឹងការរំលោភនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់ ព្រមបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភដែលជាបទល្មើសដាច់ដោយឡែកនៅក្នុងច្បាប់ដោយយោងទៅតាមការចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ។ ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ថា ភាពអសីលធម៌នៃសកម្មភាពនេះអាចគាំទ្រដល់ការរកឃើញដែលថាបទឧក្រិដ្ឋរបស់សកម្មភាពនោះអាចរំពឹងឃើញមុនបាន ។ នៅទីបញ្ចប់ ព្រះរាជអាជ្ញាបានបង្ហាញពីយុត្តិសាស្ត្រអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដាដែលរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភគឺជាឧក្រិដ្ឋកម្មស្វ័យតដែលយ៉ាងហោចណាស់កើតឡើងអំឡុងទសវត្សរ៍៩០ ។

មេធាវីការពារក្តីមិនបានឆ្លើយតបនឹងចំណុចនេះទេ ប៉ុន្តែបែរជាលើកឡើងថា ឌុច មិនត្រូវទទួលខុសត្រូវចំពោះករណីរំលោភតែមួយករណីឡើយ ពីព្រោះ ឌុច មិនមានអំណាចចាប់ខ្លួនអ្នកនៅក្រោមបង្គាប់ ហើយគាត់អាចត្រឹមតែរាយការណ៍ទៅថ្នាក់លើប៉ុណ្ណោះ ។ បន្ថែមពីលើនេះទៅទៀត ដោយសារតែមាត្រា១៨៨នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមាន «ការវាយប្រហារជាប្រព័ន្ធ» ដូច្នេះការរំលោភមួយករណី មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។ ប៉ុន្តែដូចដែលបានលើកឡើងដោយព្រះរាជអាជ្ញា ច្បាប់អន្តរជាតិបានបង្កើតថាមានតែ «ការវាយប្រហារ» ទេដែលត្រូវតែធ្វើឡើងជាលក្ខណៈរាលដាល និងជាប្រព័ន្ធគឺមិនមែនសកម្មភាពរបស់បុគ្គលទេ ។ ច្បាប់កម្ពុជាមិនអាចដោះស្រាយបញ្ហានេះទេ ប៉ុន្តែក្រមថ្មីដែលដកស្រង់ចេញពីច្បាប់បារាំងហាក់ដូចជាស្របទៅនឹងយុត្តិសាស្ត្រអន្តរជាតិ ។

សេចក្តីសម្រេចលើបញ្ហានេះមានសារៈសំខាន់ណាស់ចំពោះសំណុំរឿងទីពីរ ពីព្រោះអង្គបុរេជំនុំជម្រះបានទទួលយកអំណះអំណាងរបស់មេធាវីការពារក្តីដែលថាការរំលោភមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកនៅក្នុងយុត្តាធិការបណ្តោះអាសន្នរបស់តុលាការ(១៩៧៥-១៩៧៩) និងកែដីកាចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួនទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ «សកម្មភាពអមនុស្សធម៌ផ្សេងទៀត» ។

### ២.២.១.៣) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ជាទាសករ

ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសច្បាប់ដោយមិនបានចោទប្រកាន់ ឌុច ពីការដាក់ជាទាសករនូវអ្នកទោសមន្ទីរស-២១ ប៉ុន្តែមានតែអ្នកទោស «មួយចំនួនតូចប៉ុណ្ណោះត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងមន្ទីរស-២១» និងនៅមន្ទីរស-២៤ ។ ព្រះរាជអាជ្ញាក៏បានអះអាងពីការចោទប្រកាន់ពីការដាក់ជាទាសករថា វាមិនមានសារៈសំខាន់ដែលត្រូវបង្ហាញថាមានការបង្ខំឲ្យធ្វើការធ្ងន់ គ្រាន់តែបង្ហាញថាជនត្រូវចោទ «ប្រើប្រាស់អំណាចរបស់ខ្លួនខ្លះឬទាំងអស់ទៅលើបុគ្គលណាមួយ» ដូចដែលបង្ហាញតាមរូបភាពមួយចំនួនដូចជាគ្រប់គ្រងទៅលើចលនានិងបរិយាកាសរូបរាងកាយរបស់អ្នកនោះ និងដកហូតសិទ្ធិសេរីភាពរបស់អ្នកទាំងនោះ ។

មេធាវីការពារក្តីមិនបានអះអាងប្រឆាំងនឹងការបង្ហាញពីធាតុផ្សំនៃបទល្មើសរបស់ព្រះរាជអាជ្ញាទេ តែបែរជានិយាយថាអង្គជំនុំជម្រះគួរតែសម្អាងទៅលើមាត្រា១៨៨នៃក្រមព្រហ្មទណ្ឌ

កម្ពុជាឆ្នាំ២០០៩ដែលផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ជាទាសករ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រមនេះមិនបានឲ្យនិយមន័យទៅលើការដាក់ជាទាសករទេ ហើយក៏មិនមានអ្នកណាម្នាក់ត្រូវបានចោទប្រកាន់ពីបទល្មើសនេះនៅក្រោមក្រមនេះដែរ ។ ដោយមិនបានផ្តល់និយមន័យផ្សេងទាក់ទងនឹងការដាក់ជាទាសករ មេធាវីការពារក្តីអះអាងថា មិនមានអ្នកទោសនៅមន្ទីរស-២៤ ណាម្នាក់ត្រូវបានដាក់ជាទាសករទេ ហើយអ្នកទាំងនោះអាចដើរហើរសេរី និងត្រូវបានធ្វើទៅលើស្មើគ្នានឹងកម្មាភិបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងដ៏តឹងរ៉ឹង ។ មេធាវីការពារក្តីក៏បានអះអាងថា មិនមានឧក្រិដ្ឋកម្មកើតមាននៅមន្ទីរស-២១ ទេ អ្នកទោសដែលត្រូវបានបញ្ជូនចូលត្រូវបានសួរចម្លើយ និងសម្លាប់ ។

### ២.២.១.៤) ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងជម្លោះប្រដាប់អាវុធ

នៅក្នុងសេចក្តីសម្រេចលើករណី ឌុច អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាមិនមានសេចក្តីតម្រូវឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ មិនមានភាគីណាលើកឡើងពីចំណុចនេះនៅក្នុងដំណើរការនីតិវិធីកាត់ទោស ឬនៅក្នុងបណ្តឹងឧទ្ធរណ៍ទេ ។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលបានស្នើឲ្យភាគី «ស្វែងរកថាតើនៅអំឡុងពេលយុត្តាធិការបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ច្បាប់អន្តរជាតិតម្រូវឲ្យមានទំនាក់ទំនងរវាងសកម្មភាពឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ» ឬទេ ។ ព្រះរាជអាជ្ញាមិនបានពិភាក្សាពីបញ្ហានេះទេ ។ មេធាវីការពារក្តីបានអះអាងថាទាំងច្បាប់អន្តរជាតិ និងមាត្រា១៨៨នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩មានរួមបញ្ចូលសេចក្តីតម្រូវនេះ ។ មេធាវីការពារក្តីមិនបានគាំទ្រនឹងច្បាប់អន្តរជាតិទេ ។ មាត្រា១៨៨នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ដែលមិនត្រូវបានយកមកប្រើប្រាស់ដោយផ្ទាល់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងតុលាការកម្ពុជាទេ ហើយក៏មិនបានរួមបញ្ចូលសេចក្តីតម្រូវនេះដោយត្រង់ដែរ ។ មេធាវីការពារក្តីមិនបានពន្យល់ថាហេតុអ្វីបានជាមាត្រានេះគួរតែត្រូវបានបកស្រាយដើម្បីរួមបញ្ចូលសេចក្តីតម្រូវនៃទំនាក់ទំនងនេះទេ ។

នេះគឺជាបញ្ហាដ៏សំខាន់បំផុតនៅក្នុងសំណុំរឿងទីពីរ ពីព្រោះអង្គបុរេជំនុំជម្រះបានកែប្រែការចោទប្រកាន់ដោយតម្រូវឲ្យមាន «វត្តមាននៃទំនាក់ទំនងរវាងសកម្មភាពនៃការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ» ។ វត្តមាននៃសេចក្តីតម្រូវនេះតម្រូវឲ្យមានទំនាក់ទំនងរវាងកន្លែងកើតហេតុនិងជម្លោះប្រដាប់អាវុធប្រឆាំងនឹងវៀតណាម ដែលទំនងជាមិនអាចដំណើរការទៅបានប្រសិនបើមិនមានការពង្រីកនិយមន័យ «ទំនាក់ទំនង» ឲ្យហួសពីអត្ថន័យរបស់វា ។ អាស្រ័យហេតុនេះ ប្រសិនបើសេចក្តីតម្រូវនេះមានវត្តមានជនត្រូវចោទនៅក្នុងសំណុំរឿងទីពីរទំនងជាមិនត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិច្រើនប្រភេទទេ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមិនតម្រូវឲ្យធ្វើតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយអង្គជំនុំជម្រះសាលាដំបូងប្រហែលជាមិនតម្រូវឲ្យមានទំនាក់ទំនងនេះទេ ។ វានៅតែមិនមានភាពច្បាស់លាស់ថាតើអង្គជំនុំជម្រះតុលាការកំពូលអាចដោះស្រាយបញ្ហានេះនៅពេលនេះ ពីព្រោះបញ្ហានេះមិនទាន់ត្រូវបានលើកឡើងដោយភាគីនៅពេលប្តឹងឧទ្ធរណ៍ ។

## ២.២.២) ការផ្តន្ទាទោស

### ២.២.២.១) ស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស

ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោសស្រាលពេក ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានដាក់ស្ថានទម្ងន់ទោសស្រាលពេកទៅលើបទល្មើសរបស់ ឌុច ស្ថានភាពរបស់បុគ្គល និងស្ថានទម្ងន់ទោសដែលរួមមានតួនាទីខ្ពស់របស់គាត់ និងការរំលោភទៅលើអំណាចរបស់គាត់ ភាពសាហាវដែលគាត់បានប្រព្រឹត្តការមិនអាចគបគបានរបស់ជនរងគ្រោះ និងចេតនារើសអើងប្រឆាំងនឹងជនរងគ្រោះដោយផ្អែកលើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។

ព្រះរាជអាជ្ញាក៏បានអះអាងថាអង្គជំនុំជម្រះសាលាដំបូងផ្តល់ស្ថានសម្រាលទោសច្រើនពេកដោយធ្វើការបកស្រាយមិន

ស្របទៅនឹងអ្វីដែលបានរកឃើញដែលទាក់ទងនឹងស្ថានភាពបន្ធូរ ដែល ឌុច ធ្វើការសហការរបស់គាត់ជាមួយនឹងតុលាការ ការយល់ស្របទទួលខុសត្រូវនិងការសម្តែងវិប្បដិសារី ការរួមចំណែកក្នុងការផ្សះផ្សាជាតិ និងនិន្នាការនៃការស្តារនីតិសម្បទា និងការចូលរួមជាមួយសង្គមម្តងទៀត ។ ព្រះរាជអាជ្ញាបានធ្វើកំណត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធនឹងអ្វីដែល ឌុច ថាគាត់ធ្វើតាមបញ្ជាថ្នាក់លើ និងអំណះអំណាងដ៏វែងរបស់គាត់ ហើយបានរកឃើញថាគាត់ដឹងថាបញ្ជាដែលគាត់ទទួល គឺមិនស្របច្បាប់ ប៉ុន្តែគាត់ចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មនោះដោយសកម្ម និងពេញចិត្តអនុវត្តការងារដោយមានប្រសិទ្ធភាព និងពេញចិត្ត និងនៅបន្តបម្រើបក្សនៅក្រោយឆ្នាំ១៩៧៩ ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាបានបង្ហាញពីការបដិសេធរបស់ ឌុច ចំពោះគ្រប់ភ័ស្តុតាងដែលបង្ហាញថាគាត់បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ ហើយក៏បានលើកឡើងពីពេលខ្លះដែលគាត់ផ្តល់សក្ខីកម្មមិនពេញលេញ មិនចំ ឬមិនត្រឹមត្រូវ ។ ជាក់ស្តែង ព្រះរាជអាជ្ញាបានអះអាងថាការដែល ឌុច ស្នើសុំឲ្យដោះលែងគាត់ នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលបានបង្កើតជាចម្ងល់ចំពោះការសហការ និងវិប្បដិសារីរបស់គាត់ ។

នៅទីបញ្ចប់ ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាទៅលើច្បាប់ពាក់ព័ន្ធដែលចែងថា នៅពេលដែលរកឃើញថាមាន «ប្រភេទ ឬបទល្មើសធ្ងន់ធ្ងរបំផុត» នោះ ត្រូវតែមានការពិចារណាទៅស្ថានទម្ងន់ជាចម្បងចំពោះការផ្តន្ទាទោស ។ ព្រះរាជអាជ្ញាបានអះអាងទៀតថា ទោះបីជាករណីនេះត្រូវមានស្ថានសម្រាលទោសខ្លះក៏ដោយ ដោយយោងទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស វាមិនត្រូវមានការកាត់បន្ថយទោសទេ ។

មេធាវីការពារក្តីបានអះអាងថា គួរតែកាត់បន្ថយការផ្តន្ទាទោស ឌុច ពីព្រោះគាត់បានទទួលស្គាល់នូវវត្តមានស-២១ នៅពេលដែល តាម៉ុក និងមេដឹកនាំខ្មែរក្រហមផ្សេងទៀតបានអះអាងថា ស-២១ គឺជាការបង្កើតរបស់វៀតណាម គាត់ត្រូវនួន ជា គំរាមកំហែងដោយសារតែការសហការរបស់គាត់ គាត់បានសារភាពពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនៅ ស-២១ គាត់នៅក្រោមបញ្ជា គាត់មិនបានប្រព្រឹត្តដោយចិត្តឯងទេ គាត់អាចចូលរួមជាមួយសង្គមម្តងទៀត គាត់មិនមានអំណាចធ្វើអន្តរាគមន៍ឲ្យបញ្ឈប់ឧក្រិដ្ឋកម្មទេ គាត់បានព្យាយាមធ្វើអន្តរាគមន៍ចំពោះករណីរំលោភ គាត់បានព្យាយាមដោះលែងអ្នកទោស គាត់មិនមានជម្រើសក្នុងការអនុវត្តការងារពីព្រោះគាត់អាចស្លាប់ គាត់បានបង្ហាញពីវិប្បដិសារី ហើយគាត់មិនបានទទួលប្រយោជន៍ពីសកម្មភាពរបស់គាត់ទេ ។

### ២.២.២.២) សំណើសុំឲ្យផ្តន្ទាទោសឲ្យយូរជាងនេះ

ព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលបំបែករាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរកឃើញ ទទួលស្គាល់ជនរងគ្រោះដែលទទួលរងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ជាទាសករដែលភាគច្រើនជាអ្នកទោស ស-២១ និងបង្កើនការផ្តន្ទាទោសរហូតដល់ឃុំខ្លួនអស់មួយជីវិត គឺថាកាត់បន្ថយមកត្រឹម៤៥ឆ្នាំបន្ទាប់ពីពិចារណាទៅលើទទួលរងការរំលោភសិទ្ធិមនុស្សដែលគាត់បានទទួលនៅពេលដែលគាត់ត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅតុលាការយោធា ។ ព្រះរាជអាជ្ញាក៏បានស្នើមិនឲ្យមានការពិចារណាទៅលើស្ថានសម្រាលទោសពីព្រោះ ឌុច បានស្នើឲ្យដោះលែងគាត់ ។

### ២.២.២.៣) ភាពដែលប្រើបាននូវក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩

ចៅក្រម កុណ្ឌវីកការ មីឡាត បានលើកឡើងពីបញ្ហានៃការដែលអាចប្រើប្រាស់បាននូវក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលចែងថា «ប្រសិនបើបទល្មើសត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត នោះចៅក្រមដែលផ្តល់ស្ថានសម្រាលទោសអាចផ្តន្ទាទោសមកត្រឹមចន្លោះ១៥ទៅ៣០ឆ្នាំ» ។ តាមមាត្រា១០នៃក្រម និងគោលការណ៍ lex mitior ច្បាប់ព្រហ្មទណ្ឌនឹងត្រូវបានយកមកប្រើប្រាស់នៅពេលដែលវាចូលជាធរមាន និងប្រសិនបើវាផ្តល់ផលប្រយោជន៍ច្រើនដល់ជនត្រូវចោទ ។ ដូច្នេះ ប្រសិនបើក្រមព្រហ្មទណ្ឌកម្ពុជាអាចត្រូវបានយកមកប្រើប្រាស់នៅក្នុងករណីនេះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយមានការរកឃើញស្ថានសម្រាលទោស នោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាត្រូវដាក់ទោស ឌុច

ច្រើនបំផុតត្រឹម៣០ឆ្នាំ ។

អង្គជំនុំជម្រះសាលាដំបូងរកឃើញថាមាត្រា៩៥មិនអាចយកមកប្រើប្រាស់បានទេ ហើយបានធ្វើកំណត់សម្គាល់ថា វា «មានចម្ងល់ចំពោះថាតើអង្គជំនុំជម្រះអាចដើរតាមបញ្ញត្តិច្បាប់ជាតិ ដែលយោងទៅតាមកិច្ចព្រមព្រៀងដែរឬទេ ។ ការបកស្រាយពន្យល់បែបនេះអាចមានន័យថាសកម្មភាពស្របច្បាប់ជាតិនៅថ្ងៃខាងមុខទាក់ទងនឹងការផ្តន្ទាទោសអាចប៉ះពាល់ដល់កិច្ចព្រមព្រៀង ។ ចៅក្រម ឡាវែ៉ញ មិនយល់ស្របនឹងចំណុចមួយនៃសេចក្តីសម្រេចនេះ ដោយរកឃើញថាទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ប្រហែលជាមានលក្ខណៈពិសេស វានៅតែមានការលំបាកក្នុងការប្រើប្រាស់ច្បាប់ក្នុងស្រុកទាំងស្រុង» ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺ ចៅក្រម ឡាវែ៉ញ មិនបានប្រឆាំងថាច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈស្វយ័ត ជាពិសេសនៅពេលដែលពិចារណាជាមួយមាត្រា៧៧(១) នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការអន្តរជាតិ ដែលកែសម្រួលទោសធ្ងន់បំផុតមកត្រឹមការដាក់ពន្ធនាគារអស់មួយជីវិត ។

ព្រះរាជអាជ្ញារអះអាងថា ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈពិសេស អង្គជំនុំជម្រះមិនគួរប្រើប្រាស់ច្បាប់ក្នុងស្រុកទេពីព្រោះ «ការផ្តោតរបស់អង្គជំនុំជម្រះគឺខុសពីដំណើរការទូទៅរបស់តុលាការព្រហ្មទណ្ឌកម្ពុជា» ។ ជាងនេះទៅទៀត អ្នកព្រាងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានស្នើឲ្យអង្គជំនុំជម្រះពិចារណាទៅលើបទដ្ឋានផ្តន្ទាទោសជាតិនោះគឺដូចនឹងការតម្រូវរបស់លក្ខន្តិកៈរបស់តុលាការផ្សេងដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសនៅសេរ៉ាឡេអូន ។ ប៉ុន្តែ វិធាន៩៨(៥) តម្រូវថាការផ្តន្ទាទោសត្រូវតែ «ស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុង» ។ បន្ថែមពីលើនេះទៅទៀត អ្នកទាំងនោះបានបង្ហាញថាមាត្រា៦៦៨នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ បានចែងថាក្រមនោះមិនសក្តិសមនឹងប្រើប្រាស់ក្នុងករណីព្រហ្មទណ្ឌពិសេសដែលមានន័យថាវាគួរតែត្រូវបានបកស្រាយពន្យល់ដើម្បីយកមករួមបញ្ចូលទៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាទីបញ្ចប់ អ្នកទាំងនោះក៏បានជំរុញឲ្យចៅក្រមកុំពិចារណាទៅលើស្ថានសម្រាលទោសដែលធ្វើឲ្យមាត្រា៩៥មិនមានការជាប់ពាក់ព័ន្ធ ។

មេធាវីការពារក្តីមិនបានធ្វើអំណះអំណាងប្រឆាំងបន្ថែមទេ គឺគ្រាន់តែបញ្ជាក់ថាមាត្រា៩៥គួរតែត្រូវបានយកទៅប្រើប្រាស់ និងនិយាយថា ឌុច គួរតែទទួលការផ្តន្ទាទោសត្រឹមតែ ១៥ឆ្នាំ មុននឹងកាត់បន្ថយចំពោះការឃុំខ្លួនខុសច្បាប់ដែលគាត់បានទទួល និងពេលវេលារបស់គាត់ ។

ចៅក្រម ក្លូឌីកកា មីឡាត បាននិយាយថា គាត់យល់ឃើញថាអំណះអំណាងរបស់ព្រះរាជអាជ្ញាទាក់ទងនឹងមាត្រា៩៥មានលក្ខណៈមិនត្រឹមត្រូវពីព្រោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាផ្នែកមួយនៃប្រព័ន្ធជាតិ ហើយវាក៏មិនមានទំនាស់ផ្ទាល់រវាងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងមាត្រា៣៩ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចប្រកាសការផ្តន្ទាទោសពីប្រាំឆ្នាំរហូតដល់មួយជីវិត ។ វាមិនមានភាពច្បាស់លាស់ថាតើចៅក្រមផ្សេងទៀតយល់ស្របនឹងទស្សនៈរបស់ចៅក្រម ក្លូឌីកា មីឡាត ដែរឬទេ ប៉ុន្តែវាគឺចំណុចតែមួយនៅក្នុងដំណើរការនីតិវិធីដែលហាក់ដូចជាបញ្ជាក់ថា ឌុច អាចត្រូវទទួលការផ្តន្ទាទោសស្រាលជាងនេះ ទោះបីជាមេធាវីការពារក្តីរបស់ ឌុច ខកខានមិនបានផ្តល់អំណះអំណាងច្បាប់ទាក់ទងនឹងចំណុចនេះឬចំណុចផ្សេងក៏ដោយ ។

## ២.៣) ដើមបណ្តឹងរដ្ឋប្បវេណី

### ២.៣.១) ការបដិសេធដើមបណ្តឹងរដ្ឋប្បវេណី

នៅពេលចាប់ផ្តើមដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបឋម ដែលវាយតម្លៃថាដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈវិន្និច្ឆ័យគ្រប់គ្រាន់សម្រាប់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែនៅក្នុងសេចក្តីសម្រេច ដើមបណ្តឹងរដ្ឋប្បវេណី២៤រូប ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី៩០រូបមិនត្រូវបានគេទទួលស្គាល់ទៅវិញ ។ ហេតុផលនៃការ

បដិសេធនេះ រួមមានការខ្វះខាតឯកសារភស្តុតាងទាក់ទងនឹងឋានៈរបស់អ្នកទាំងនោះដែលជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ ឬភស្តុតាងបង្ហាញពីចំណងនៃសេចក្ដីស្រឡាញ់ ឬ «ទំនាក់ទំនងពិសេស» ជាមួយជនរងគ្រោះដោយផ្ទាល់ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ក្នុងចំណោមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនក្រុម បានធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងការបដិសេធមិនទទួលស្គាល់កូនក្ដីរបស់ខ្លួន ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានធ្វើការហួសពីអំណាចរបស់ខ្លួនដោយបានដើរតាមដំណើរការពីរដំណាក់ដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ នៅពេលចាប់ផ្ដើមដំណើរនីតិវិធី ចៅក្រមបានពិនិត្យទៅលើឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយដើរតាមគោលការណ៍វិធាន៨៣(១) នៃវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៣) ដែលចែងដោយផ្នែកថា «នៅក្នុងសវនការបឋម អង្គជំនុំជម្រះគួរតែពិចារណាទៅលើរាល់ពាក្យបណ្ដឹងដែលដាក់ដោយជនរងគ្រោះដើម្បីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដូចដែលមានចែងនៅក្នុងវិធាន២៣(៤)» ។ នៅពេលត្រួតពិនិត្យទៅលើឋានៈរបស់អ្នកទាំងនោះជាលើកទីពីរនៅពេលបញ្ចប់ដំណើរការនីតិវិធី ចៅក្រមបានសម្អាងទៅលើវិធាន១០០(១)វិសោធនកម្មលើកទី៣) ដែលចែងថា ៖

*អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសាលក្រម ។ អង្គជំនុំជម្រះត្រូវសម្រេចលើភាពដែលអាចទទួលយកបាន និងខ្លឹមសារចំពោះការទាមទារប្រឆាំងនឹងជនជាប់ចោទ ។ នៅពេលដែលសមស្រប អង្គជំនុំជម្រះអាចសម្រេចអំពីផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការដោយឡែកមួយទៀតបាន ។*

យោងទៅតាមមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានឲ្យដឹងថា ការពិនិត្យលើកទីពីរគឺមិនបានផ្អែកទៅលើការអនុវត្តរបស់អន្តរជាតិ ឬមិនត្រូវបានគាំទ្រដោយវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយពីព្រោះវិធាន១០០ទាំងមូលបានសម្អាងតែពីឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការផ្ដល់សំណង ប៉ុន្តែមិនមែនទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានបកស្រាយទៅលើចំណុចនេះដោយធ្វើកំណត់សម្គាល់ថាវិធាន២៣(៤)គឺមានលក្ខណៈមិនច្បាស់លាស់ចំពោះការតម្រូវឲ្យអង្គជំនុំជម្រះកំណត់ពីភាពអាចទទួលយកបាននូវពាក្យបណ្ដឹងនៅពេលចាប់ផ្ដើមដំណើរការនីតិវិធី និងនិយាយថានេះគឺជាគោលការណ៍តែមួយដែលអង្គជំនុំជម្រះអាចពិចារណាទៅលើភាពដែលអាចទទួលយកបាន ។ ទោះបីជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមិនបានអះអាងថា អង្គជំនុំជម្រះមិនមានសិទ្ធិបដិសេធឋានៈដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលបញ្ចប់ការជំនុំជម្រះទេ គឺគ្រាន់តែអះអាងប្រឆាំងថាការធ្វើបែបនេះ គឺមិនត្រឹមត្រូវ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើកំណត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ បានប្រើប្រាស់សិទ្ធិដែលថាខ្លួនជាដើមណ្ដឹងរដ្ឋប្បវេណីនៅអំឡុងពេលសវនាការ ហើយរំពឹងថាឋានៈរបស់ខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនឹងបន្ត ។ ជាងនេះទៅទៀត ការទទួលស្គាល់អ្នកទាំងនោះនៅក្នុងសេចក្ដីសម្រេចគឺមិនអាចជះឥទ្ធិពលអាក្រក់ដល់ជនជាប់ចោទសព្វថ្ងៃនេះទេ ប៉ុន្តែវាអាចធ្វើឲ្យជនរងគ្រោះដែលត្រូវបានគេបដិសេធទទួលការប៉ះទង្គិចខ្លាំង ។

ទីពីរ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថាអង្គជំនុំជម្រះមិនបានជូនដំណឹងឲ្យទាន់ពេលដល់ភាគីថា ខ្លួននឹងពិចារណាទៅលើឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្ដងទៀតនៅពេលបញ្ចប់នីតិវិធី ឬជូនដំណឹងឲ្យដឹងពីលក្ខណៈវិនិច្ឆ័យបន្ថែមដែលខ្លួនត្រូវការនិងមិនមាននៅក្នុងវិធាន ។ ការធ្វើបែបនេះប៉ះពាល់ដល់លទ្ធភាពនៃការផ្ដល់ភស្តុតាងបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ទីបី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថាបើទោះជាការវាយតម្លៃម្ដងទៀតរបស់អង្គជំនុំជម្រះមានលក្ខណៈសមស្របក៏ដោយ ក៏អង្គជំនុំជម្រះបានប្រើប្រាស់បទដ្ឋានពិនិត្យទៅលើភស្តុតាងសម្រាប់វាយតម្លៃដើមបណ្ដឹងរដ្ឋប្បវេណីខ្ពស់ពេក ។ ជាក់ស្ដែង មេធាវីការពារក្ដីបាននិយាយថាអង្គជំនុំជម្រះបានប្រើប្រាស់និយមន័យដ៏តឹងរឹងនិងមិនសមរម្យក្នុងការតម្រូវឲ្យបង្ហាញពីចំណងគ្រួសារ និងលើកឡើងពីភាពខ្វះខាតនៃភាពដែលអាចបត់បែនបានដ៏ចាំបាច់ទាក់ទងនឹងឯកសារ ដោយពិចារណាទៅ

លើការអនុវត្តរបស់តុលាការអន្តរជាតិនិងឯកសារមួយចំនួនដែលត្រូវបានបំផ្លិចបំផ្លាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានអះអាងថា ដោយផ្អែកទៅលើភស្តុតាងដែលមានស្រាប់ មានភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញពីឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវជាជនរងគ្រោះផ្ទាល់ ប៉ុន្តែត្រូវបានតុលាការបដិសេធ ។ ជាងនេះទៅទៀត ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ឯកសារបន្ថែមមួយចំនួនទៅតុលាការកំពូលសម្រាប់ពិចារណារួចទៅហើយ ។

បន្ថែមពីលើនេះទៅទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានបង្ហាញថាប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធនៅក្នុងសេចក្តីសម្រេចចុងក្រោយទៅលើឋានៈរបស់អ្នកទាំងនោះដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូលអាចត្រូវបានប្រព្រឹត្តឡើងនៅក្រោយថ្ងៃផុតកំណត់ធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការមិនផ្តល់សំណងដែលនេះគឺជាការដកហូតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យធ្វើបណ្តឹងសាទុក្ខទាមទារសំណង ។

ទាក់ទងនឹងភាពដែលអាចរំពឹងទុកបាន ចៅក្រម ក្លូវីកកា មីឡាត បានលើកឡើងពីមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលតម្រូវនីតិវិធីរបស់តុលាការត្រូវតែស្របទៅនឹងច្បាប់កម្ពុជា ។ ដោយប្រកាន់លើចំណុចនេះ ចៅក្រម ក្លូវីកកា មីឡាត បានលើកឡើងថាមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលបានផ្តល់ឲ្យមានដំណើរការសម្រេចទៅលើភាពដែលអាចទទួលយកបានពីរដំណាក់កាលស្របនឹងការអនុវត្តច្បាប់ស៊ីវិលរបស់ប្រទេសដទៃ ។

ចៅក្រម ក្លូវីកកា មីឡាត ក៏បានធ្វើកំណត់សម្គាល់ថា មាត្រា១៣នៃក្រមព្រហ្មទណ្ឌកម្ពុជាក៏បានផ្តល់បទដ្ឋានបង្ហាញភស្តុតាងដែលស្របនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ ។ ដើម្បីជាការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានធ្វើកំណត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានលើកសម្អាងពីបទបញ្ញត្តិទាំងនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទេ គឺគ្រាន់តែសម្អាងទៅលើមាត្រា១០០(១) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ ។ ជាងនេះទៅទៀត ដោយខុសពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការក្នុងស្រុកមិនមានសវនាការបឋមដែលតម្រូវឲ្យមានការពិចារណាទៅលើភាពដែលអាចទទួលយកបានទេ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានអានការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅឆ្នាំ២០០៨ដែលក្រុមរបស់ខ្លួនបានបដិសេធមិនយល់ស្របប៉ុន្តែក្រុមដទៃទៀតបានផ្អែកទៅលើ ។ ការរកឃើញនោះរៀបរាប់ថា ៖

វិធានផ្ទៃក្នុងបង្កើតជាស្ថានភាពច្បាប់នីតិវិធីមួយទាក់ទងកាលៈទេសៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវអនុម័តនិងមានការយល់ស្របដោយកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វិធានទាំងនោះមិនមានលក្ខណៈផ្ទុយពីក្រមព្រហ្មទណ្ឌកម្ពុជាទេ ប៉ុន្តែការផ្តោតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺខុសពីដំណើរការទូទៅរបស់តុលាការព្រហ្មទណ្ឌកម្ពុជាដែលតម្រូវឲ្យអង្គជំនុំជម្រះមានប្រព័ន្ធឯកទេសមួយ ។ អាស្រ័យហេតុនេះ វិធានផ្ទៃក្នុងបានបង្កើតជាលិខិតុបករណ៍ចំបងសម្រាប់សម្អាងនៅពេលកំណត់នីតិវិធីពីព្រោះវាមានភាពខុសគ្នារវាងវិធានផ្ទៃក្នុងនិងក្រមព្រហ្មទណ្ឌកម្ពុជា ។ បទបញ្ញត្តិរបស់ក្រមព្រហ្មទណ្ឌកម្ពុជាអាចត្រូវបានយកមកប្រើប្រាស់នៅពេលដែលមានវិធានផ្ទៃក្នុងមិនអាចដោះស្រាយបញ្ហាបាន ។

### ២.៣.២) សំណើទាមទារសំណង

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទាមទារ «សំណងផ្លូវចិត្តនិងជាសមូហភាពប្រឆាំងនឹងជនជាប់ចោទ» ។ វិធានផ្ទៃក្នុងបានចែងថា «ការផ្តល់សំណងត្រូវធ្វើឡើងប្រឆាំងនឹងជនជាប់ចោទហើយជាបន្ទុករបស់ជនជាប់ចោទ» ។ ឌុច បានប្រកាសថាគាត់មានជីវភាពក្រីក្រ ហើយអង្គជំនុំជម្រះបានរកឃើញថាខ្លួនមិនអាចចេញដីកា ដែលជនជាប់ចោទមិនមានលទ្ធភាពអនុវត្តបានឡើយ ។ នៅក្នុងសេចក្តីសម្រេច អង្គជំនុំជម្រះសាលាដំបូងបានបដិសេធរាល់សំណើទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកលែងសំណើពីរដោយសារតម្រូវការថវិកា តម្រូវការដែលត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ការមិនមានអ្វីមួយសម្រាប់តំណាង ឬភាព «ខ្វះខាតភាពជាក់លាក់» ។ សំណងពីរដែលផ្តល់ឲ្យនោះគឺការរួមបញ្ចូលឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះ ដោយផ្ទាល់នៅក្នុងសេចក្តីសម្រេចចុង

ក្រោយ ការចងក្រង និងបោះពុម្ពផ្សាយពាក្យសុំអភ័យទោសរបស់ ឌុច ដែលបាននិយាយនៅក្នុងសវនាការ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរបានស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលផ្តល់សំណង៩ប្រភេទដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង ។ សំណើនោះរួមមាន ការស្នើឲ្យបោះពុម្ពពាក្យសម្តីរបស់ ឌុច រួមជាមួយសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសុំអភ័យទោសរបស់ ឌុច ហើយត្រូវសរសេរសំបុត្រទៅរាជរដ្ឋាភិបាលកម្ពុជាស្នើឲ្យមានការសុំអភ័យទោសដែលធ្វើឡើងដោយរដ្ឋ, ចំណូលមួយផ្នែកនៃការចូលទស្សនាមន្ទីរស-២១ និងជើងឯកត្រូវទុកជាសំណង, ការសាងសង់បូជនីយដ្ឋាននៅមន្ទីរស-២១ ជើងឯក និងការកែប្រែព្រៃសឲ្យទៅជាបូជនីយដ្ឋានមួយ, ផ្តល់មូលនិធិដល់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ទស្សនាបូជនីយដ្ឋានទាំងនោះ, ការផ្តល់ការព្យាបាលផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី, ការចែកចាយឯកសារជាសំឡេងនិងវីដេអូអំពីដំណើរការកាត់សេចក្តី ការធ្វើពិធីនិងចារឈ្មោះជនរងគ្រោះនៅលើអគារសាធារណៈទាំង១៧រូប ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានសង្កត់ធ្ងន់ថា ភាពក្រីក្រដែលត្រូវបានសន្មតមិនមានឥទ្ធិពលអ្វីទៅលើដីកាផ្តល់សំណងទេ ពីព្រោះ ឌុច អាចត្រូវបានគេរកឃើញថាមានទ្រព្យសម្បត្តិលួចលាក់ ឬគាត់អាចមានទ្រព្យសម្បត្តិនៅពេលអនាគត ។ ជាងនេះទៅទៀតសំណើរដ្ឋបាលនិងមិនទាក់ទងនឹងថវិកាដែលស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយនូវការរំលោភបំពានលើសិទ្ធិមនុស្សមិនមែនជាការដាក់ទណ្ឌកម្មទេ ប៉ុន្តែវាគឺជាការទទួលខុសត្រូវរបស់រដ្ឋ ។

## ៣) សេចក្តីសន្និដ្ឋានចុងក្រោយដែលធ្វើឡើងដោយ កាំង ហ្គេកអ៊ាវ «ឌុច»

ឌុច បានសន្និដ្ឋានបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន បន្តពីមេធាវីការពារក្តីរបស់ខ្លួនថា គាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងមិនស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះឡើយ ។ គាត់បាននិយាយថា «មេដឹកនាំជាន់ខ្ពស់គឺជាអ្នកដទៃ មិនមែនខ្ញុំទេ ។ អ្នកដែលមានអំណាចបង្កើត និងអនុវត្តមាគ៌ា មិនមែនខ្ញុំ គឺអ្នកដទៃ» ។ គាត់បាននិយាយថា គាត់អាចនៅរស់ដោយសារតែគាត់បានធ្វើតាមបញ្ជាដោយហ្មត់ចត់ពីឆ្នាំ១៩៧១-១៩៧៩ ហើយគាត់ធ្វើសកម្មភាពនៅក្រោមការគាបសង្កត់ ។ គាត់បានអះអាងថាគាត់បានសហការយ៉ាងស្មោះត្រង់តាំងពីគាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៩៩ ហើយគាត់បានបកស្រាយថា មន្ទីរស-២១ គឺជាការពិត ខណៈពេលដែលអ្នកដទៃបានស្តីបន្ទោសថាវាជារបស់រដ្ឋាភិបាលវៀតណាម ។ គោលជំហររបស់ ឌុច ចំពោះប្រជាជនកម្ពុជាគឺគាត់ទទួលខុសត្រូវចំពោះអ្វីដែលអ្នកទោសនៅមន្ទីរ-២១បានទទួលរង និងទទួលខុសត្រូវខាងផ្លូវច្បាប់ចំពោះការខូចខាតខាងផ្លូវចិត្តរបស់ជនរងគ្រោះ ហើយគាត់ក៏ស្វែងរកការអភ័យទោសដែរ ។ គាត់បានសង្កត់ធ្ងន់ថា អតីតកម្មាភិបាលនិងកម្មាភិបាលជាន់ខ្ពស់នឹងរក្សាជំហររឹងដែលថាខ្លួនចូលរួមជាមួយខ្មែរក្រហមគឺដើម្បីរំដោះប្រទេសជាតិ ប៉ុន្តែមាគ៌ាបក្សជាមាគ៌ាមហាឧក្រិដ្ឋដែលត្រូវបានចម្លងចេញពីក្រុមពាលទាំងបួននៅប្រទេសចិន ។ កម្មាភិបាលម្នាក់ៗដែលបានហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីប្រទេសជាតិគឺស្ថិតនៅក្រោមការគាបសង្កត់អនុវត្តតាមមាគ៌ាបក្ស ។ គាត់បាននិយាយថា គាត់ជឿជាក់ថាអង្គជំនុំជម្រះតុលាការកំពូលកំពុងតែស្វែងរកការពិតសម្រាប់ប្រជាជនកម្ពុជា ជនរងគ្រោះ អតីតកម្មាភិបាល និងទាហានសម្រាប់ការរស់នៅដ៏សន្តិភាពរបស់ប្រជាជនកម្ពុជា ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះគួររកឃើញថាគាត់មិនស្ថិតនៅក្នុងយុត្តាធិការលើបុគ្គលនោះទេ ។

## ៤) ការអះអាងរបស់មេធាវីការពារក្តីដែលអាចជាជំនួយមិនមានប្រសិទ្ធភាព

អំណះអំណាងរបស់មេធាវីការពារក្តីនៅពេលធ្វើបណ្តឹងសាទុក្ខដែលមានលក្ខណៈច្របូកច្របល់ មិនមានមូលដ្ឋានច្បាស់លាស់ដដែលៗ និងមិនមានការគាំទ្រពីផ្នែកច្បាប់ណា រួមមានការប្រើប្រាស់គោលការណ៍ច្បាប់មកធ្វើអំណះអំណាងផ្សេងៗគ្នាដ៏ចម្លែក ។ ជាឧទាហរណ៍ នៅក្នុងចំណុចពីរ មេធាវីការពារក្តីបានអះអាងថាដោយសារតែមិនមានច្បាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច មិនគួរត្រូវបានចោទប្រកាន់ពីការរំលោភច្បាប់ទេ ។ មេធាវីការពារក្តីក៏ហាក់ដូចជាមិនយល់ ឬមានបំណងបកស្រាយដោយមិនត្រឹមត្រូវទៅលើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ជាក់ស្តែងដូចជាការអះអាងថា ចៅក្រម ឡាវីញ បានរក

ឃើញថា តុលាការមិនមានយុត្តាធិការទៅលើ ឌុច ប៉ុន្តែតាមការពិតគឺ ចៅក្រម ឡាវីញ គ្រាន់តែមិនយល់ស្របទៅលើថេរវេលានៃការផ្តន្ទាទោសប៉ុណ្ណោះ ។ មេធាវីការពារក្តីក៏បានអះអាងថា ព្រះរាជអាជ្ញាបាននិយាយថា វា «មិនមានច្បាប់» ក្នុងការចោទប្រកាន់ប្រធានគុកផ្សេង តាមការពិតព្រះរាជអាជ្ញាបាននិយាយថាខ្លួនមិនមានកាតព្វកិច្ចតាមផ្លូវច្បាប់ទៅចោទប្រកាន់អ្នកទាំងនោះដោយសារតែខ្លួនបានចោទប្រកាន់ ឌុច នោះទេ ។



ឌុច ក្នុងសវនាការថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ (រូបថត អ.វ.ត.ក)

ភាពខ្វះខាតឯកទេសទាក់ទងនឹងច្បាប់អន្តរជាតិរបស់មេធាវីការពារក្តី និងការខកខានមិនបានឆ្លើយតបនឹងព្រះរាជអាជ្ញាដែលស្នើឲ្យមានការឃុំខ្លួនច្រើនជាងនេះបានធ្វើឲ្យអង្គភាពគាំពារការពារក្តីជួលអ្នកជំនាញពីខាងក្រៅដើម្បីជួយក្រុមរបស់ខ្លួន និងដើម្បីធ្វើបណ្តឹងសាទុក្ខពីរដងទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីអនុញ្ញាតឲ្យខ្លួនឯងនិងអ្នកជំនាញពីខាងក្រៅដាក់សារណាសង្ខេបដើម្បីជាការឆ្លើយតប ។ ប៉ុន្តែ មេធាវីការពារក្តីបានបដិសេធជំនួយពីអ្នកជំនាញ ហើយអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា ខ្លួនត្រូវតែគោរពយុត្តិសាស្រ្តដែលសហមេធាវីជាតិជ្រើសរើសដែលរួមមានសេចក្តីសម្រេចមិនឆ្លើយតបនឹងអំណះអំណាងរបស់ព្រះរាជអាជ្ញា ។

នៅក្នុងសវនាការបណ្តឹងសាទុក្ខ អ្នកអង្កេតការណ៍ខ្លះបានឆ្ងល់ថាតើ ឌុច អាចនឹងទទួលជំនួយមិនមានប្រសិទ្ធភាពពីមេធាវីការពារក្តីដែរឬទេ ។ មិនមានបទបញ្ញត្តិទាក់ទងនឹងបញ្ហានេះនៅក្នុងវិធានផ្ទៃក្នុងទេ ហើយវាមិនមានភាពច្បាស់លាស់ថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចប្រើប្រាស់ការអនុវត្តអ្វីជាក់ស្តែងដូចចៅក្រម ក្លូវីកកា មីឡាត បានលើកឡើងនៅក្នុងសវនាការបណ្តឹងសាទុក្ខ ។ ជាងនេះទៅទៀត នៅទីបញ្ចប់នៃការអះអាងបែបនេះស្ទើរតែក្លាយទៅជាភាពមិនអាចទៅរួចបន្ទាប់ពី ឌុច ជាបុគ្គលដែលមានការអប់រំខ្ពស់និងឆ្លាត យល់ស្របនឹងអំណះអំណាងទាក់ទងនឹងយុត្តាធិការរបស់មេធាវីការពារក្តីទាំងនៅពេលចាប់ផ្តើម និងពេលបញ្ចប់ដំណើរការនីតិវិធី ។

### ៤) ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ទោះបីជាអំណះអំណាងរបស់មេធាវីការពារក្តីមិនសូវជាមានប្រសិទ្ធភាពតាមផ្លូវច្បាប់ អ្នកទាំងនោះហាក់ដូចជាធ្វើឲ្យសាធារណជនកម្ពុជាដែលចូលរួមក្នុងដំណើរការនីតិវិធីជឿ ។ វាហាក់ដូចជាថា ការ សាវុត្ថ ដែលត្រូវបានចាត់ទុកថាជាអ្នកដែលមានជំនាញនិយាយបញ្ចុះបញ្ចូលជាភាសាខ្មែរកំពុងតែយកឈ្នះទៅលើសាធារណជនកម្ពុជា គឺមិនមែនចៅក្រមទេ ។ ឧទាហរណ៍ដោយប្រៀបធៀបនឹងអ្វីដែលគាត់បាននិយាយ គាត់បានលើកឡើងពីឥរិយាបថរបស់ប្រទេសថៃនៅក្នុងជម្លោះព្រះវិហារ ដែលជាបញ្ហាជាតិសំខាន់ ។ អ្វីដែលជាបញ្ហាគឺ ប្រជាជនរាប់រយនាក់ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានដឹកមកចូលរួមក្នុងដំណើរនីតិវិធីនៅពេលព្រឹកត្រូវបានដឹកត្រឡប់ទៅផ្ទះវិញនៅពេលបាយថ្ងៃត្រង់ ទើបក្រុមថ្មីអាចចូលរួមក្នុងសវនាការពេលថ្ងៃត្រង់បាន ។ ការធ្វើបែបនេះអាចធ្វើឲ្យក្រុមនីមួយៗស្តាប់ពុំតែអំណះអំណាងរបស់តែមេធាវីការពារក្តី ឬព្រះរាជអាជ្ញាទាក់ទងនឹងយុត្តាធិការប៉ុណ្ណោះ ។ ការធ្វើបែបនេះមិនសូវជាបណ្តាលឲ្យមានការព្រួយបារម្ភប៉ុន្មាននៅថ្ងៃបន្ទាប់ទេ ពីព្រោះមានភាគីច្រើនបាននិយាយនៅក្នុងសវនាការពេលព្រឹក និងពេលថ្ងៃ ។ ខាងក្រោមនេះគឺជាប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីខ្លះនៅក្នុងករណី០០១ និង០០២ ដែលបានចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ទាំងបីថ្ងៃ ។

### ម៉ាន ស៊ីត ភេទប្រុស អាយុ ៧៦ ឆ្នាំ មកពីខេត្តកំពង់ធំ

ខ្ញុំបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ដោយសារតែកូនប្រុសរបស់

ខ្ញុំដែលជាអតីតយោធាខ្មែរក្រហមត្រូវបានចាប់ខ្លួន និងដាក់ឃុំក្នុងគុកព្រៃស (ស-២៤) ។ ចំពោះសាលក្រម ខ្ញុំមានការពេញចិត្តដែរ ដែលតុលាការបានកាត់ទោសគាត់ឲ្យជាប់គុករយៈពេល ១៨ឆ្នាំទៀតបន្ទាប់ពីកាត់បន្ថយអស់ ។ ប៉ុន្តែ នៅក្នុងសវនាការបណ្ដឹងសាទុក្ខ ខ្ញុំខឹងនឹងមេធាវី ឌុច ដែលស្នើឲ្យ ឌុច រួចខ្លួន។ ខ្ញុំឈឺក្បាលខ្លាំងណាស់ ហើយសំពាធឈាមរបស់ខ្ញុំកើនឡើងនៅពេលដែលខ្ញុំឮមេធាវីការពារក្ដីអះអាងនៅក្នុងសវនាការ ។ ខ្ញុំខឹងខ្លាំងណាស់ ពីព្រោះប្រជាជនស្លូតត្រង់រាប់ពាន់នាក់បានស្លាប់នៅស-២១ ។ ប្រសិនបើខ្ញុំជាចៅក្រមវិញ ខ្ញុំនឹងដាក់ទោស ឌុច តាមសំណើរបស់ព្រះរាជអាជ្ញា ។ ខ្ញុំមិនដែលជឿពាក្យដែល ឌុច និយាយក្នុងសវនាការទេ ពីព្រោះគាត់តែងតែទម្លាក់កំហុសទៅលើមេដឹកនាំដែលស្លាប់ ហើយមិនទទួលខុសត្រូវ ។

## ហាវ សោភា ភេទស្រី អាយុ ៣៩ ឆ្នាំ មកពីខេត្តកំពង់ធំ

ខ្ញុំគឺជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងករណី០០១ពីព្រោះឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់នៅក្នុងមន្ទីរស-២១ ។ នៅពេលដែលខ្ញុំបានឃើញ ឌុច ត្រូវបានគេយកមកកាត់ទោសនៅក្នុងតុលាការកូនកាត់មួយនោះ ខ្ញុំមានអារម្មណ៍ធូរស្រាលពីការឈឺចាប់បានមួយចំណែកដែរ ពីព្រោះខ្ញុំគិតថាគាត់នឹងត្រូវទទួលទោសតាមផ្លូវច្បាប់ ។ ចំពោះពាក្យចុងក្រោយរបស់ ឌុច វិញ ខ្ញុំគិតថាវាគ្រាន់តែជាការតវ៉ាដើម្បីចង់រួចខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែរឿងគាត់រួច ឬមិនរួច គឺអាស្រ័យទៅតាមលោកប្រធានចៅក្រមគាត់ជាអ្នកសម្រេចដោយត្រឹមត្រូវ ។ ពាក្យដែលគាត់និយាយ ខ្ញុំមិនជឿទេ ពីព្រោះកាលពីសវនាការលើកមុន គាត់និយាយថាគាត់ជាអ្នកទទួលខុសត្រូវគ្រប់ឧក្រិដ្ឋកម្ម? ដែលកើតមានឡើងនៅទួលស្លែង ។ ប៉ុន្តែ ដល់ថ្ងៃចុងក្រោយ គាត់បែរជានិយាយផ្សេងដើម្បីសុំឲ្យតុលាការដោះលែងគាត់ ។ ខ្ញុំមិនមានឱកាសតាមដានរាល់សវនាការផ្ទាល់មាត់នៅឆ្នាំមុនទេ ខ្ញុំគ្រាន់តែឮពីអង្គជំនុំជម្រះតុលាការកំពូលគាត់សុំឲ្យដោះលែងគាត់ពីព្រោះគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ។ ថ្វីត្បិតតែខ្ញុំមិនសូវយល់នូវពាក្យពេចន៍តាមផ្លូវច្បាប់ក៏ពិតមែន តែខ្ញុំគិតថាវាគ្រាន់តែជាអំណះអំណាងដែលលើកឡើងដោយមេធាវីការពារក្ដីគឺដើម្បីឲ្យកូនក្ដីរបស់ខ្លួនរួចទោសប៉ុណ្ណោះ ។ ផ្អែកទៅតាមឯកសារ រូបថត និងការវាយតម្លៃទៅលើអត្តចរិតរបស់គាត់ ខ្ញុំគិតថាទង្វើដែលគាត់ធ្វើគឺ ធ្វើដោយការពេញចិត្ត ។ តែដោយសារឧក្រិដ្ឋកម្មដែលគាត់ធ្វើនៅស-២១ មានភាពសាហាវយោរយៅខ្លាំងពេក គាត់ត្រូវចេញមកទទួលខុសត្រូវ ។ ចំពោះមេគុកទាំង១៩៥ ផ្សេងទៀត ខ្ញុំគិតថាវានៅក្រៅវង់ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតដែលធ្វើឲ្យតុលាការមិនកាត់ទោសមេដឹកនាំទាំងនោះ ។ ប៉ុន្តែឧក្រិដ្ឋកម្មនៅក្នុងគុកផ្សេង ក៏មិនគួរមិនអើពើដែរ ។ ខ្ញុំជឿថាតុលាការនឹងពិភាក្សាពីបញ្ហានេះនៅពេលការកាត់ទោសនៅក្នុងសំណុំរឿង ០០២ចាប់ផ្ដើម ។ ខ្ញុំគិតថាសហព្រះរាជអាជ្ញាធ្វើត្រូវដែលស្នើឲ្យផ្ដន្ទាទោសអស់មួយជីវិតហើយដោយបូកនឹងស្ថានសម្រាលទោសនៅសល់យ៉ាងហោចណាស់ត្រឹម៤៥ឆ្នាំ ។ ចំពោះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីវិញ ខ្ញុំគិតថាចៅក្រមបានឲ្យពេលវេលាគាត់មិនគ្រប់គ្រាន់ ។ មេធាវីមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើអំណះអំណាងទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំពេញចិត្តនឹងកិច្ចខំប្រឹងប្រែងរបស់មេធាវីដែលតំណាងឲ្យយើង និងការពារផលប្រយោជន៍របស់យើង ។ ខ្ញុំមានការរីករាយណាស់ ដោយសារតែតុលាការបានទទួលស្គាល់ថាខ្ញុំពិត ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ។ ខ្ញុំគិតថាតុលាការបានឲ្យតម្លៃខ្ញុំនិងជីវិតរបស់ឪពុកខ្ញុំ មិនមែនស្លាប់ទៅដោយឥតន័យនោះទេ ។ យ៉ាងហោចណាស់ ក៏មានពិភពលោកទទួលស្គាល់ការឈឺចាប់របស់គ្រួសារខ្ញុំនិងគ្រួសារដទៃដែលបានបាត់បង់អ្នកជាទីស្រឡាញ់របស់ខ្លួននៅស-២១ ។

## អ៊ុំ ពិសិដ្ឋ អាយុ ៦០ឆ្នាំ មកពីខេត្តស្វាយរៀង

ខ្ញុំបានបាត់បង់បងថ្លៃស្រីនៅក្នុងគុកទួលស្លែង យោងទៅតាមឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់មកឲ្យខ្ញុំ ។ តាមទស្សនៈរបស់ខ្ញុំ ខ្ញុំគិតថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅគុកទួលស្លែង ។ នៅពេលកាន់អំណាច គាត់បានគ្រប់គ្រង និង-ចាត់ចែងទាំងស្រុងរាល់កិច្ចការទាំងឡាយនៅទួលស្លែង ។ ខ្ញុំបានចូលរួមក្នុងសវនាការនៅពេលដែលចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម ។ ខ្ញុំយល់ស្របនឹងសាលក្រម ទោះបីជាខ្ញុំយល់ថាការផ្ដន្ទាទោសគួរតែធ្ងន់ជាងនេះក៏ដោយ ពីព្រោះវាគឺជាសេចក្ដីសម្រេចរបស់ចៅក្រម ។ ខ្ញុំចង់ឲ្យចៅក្រម

*ផ្តន្ទាទោសដាក់គុកគាត់៣៥ឆ្នាំ ដោយមិនមានការកាត់បន្ថយ ។ ខ្ញុំមិនពេញចិត្តនឹងមេធាវីការពារក្តីរបស់ ឌុច ដែលអះអាងថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវបំផុតដែរ ។ ឌុច មិនមែនធ្វើតាមបញ្ជារហូតទេ ។ គាត់បានគ្រប់គ្រង និងចាត់ចែងទៅលើការងារ និងជនរងគ្រោះចំនួនជាង១៤០០០ នាក់ផង ។ ហេតុដូច្នេះហើយ ខ្ញុំពិតជាមិនពេញចិត្តនឹងការលើកឡើងរបស់មេធាវី ឌុច ទេ ។*

### *កែ ខុន អាយុ ៥១ឆ្នាំ មកពីខេត្តកំពង់ធំ*

*បងប្រុសច្បងរបស់ខ្ញុំឈ្មោះ កែ កេងស៊ី ។ នៅពេលដែលគាត់បាត់ខ្លួននៅក្នុងឆ្នាំ១៩៧៧ ។ ខ្ញុំមិនបានដឹងថាគាត់មានអាយុប៉ុន្មាននោះទេ ។ ខ្ញុំបានដឹង (កែ កេងស៊ី បានស្លាប់នៅក្នុងគុកទួលស្លែង) ពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឌុច គឺជាប្រធានគុកទួលស្លែង ហើយការកាប់សម្លាប់បានកើតឡើងនៅទីនោះ ។ ខ្ញុំបានដឹងពីអ្វីដែលឌុចបាននិយាយ ដោយចាប់ផ្តើមពីសវនាការបឋម ។ ខ្ញុំដឹងថា ការផ្តន្ទាទោសរយៈពេល៣៥ឆ្នាំនៅក្នុងគុកនេះ ត្រូវបានបន្ថយមកត្រឹមរយៈពេល១៩ឆ្នាំ ហើយខ្ញុំមិនពេញចិត្តចំពោះសាលក្រមនេះទេ ។ ខ្ញុំចង់ឲ្យមានការផ្តន្ទាទោសដាក់គុកអស់មួយជីវិតដូចដែលសហព្រះរាជអាជ្ញាបានស្នើ ។ ប៉ុន្តែនេះជាការអនុវត្តច្បាប់ ដូច្នេះតុលាការអាចបន្ថយ (ការផ្តន្ទាទោស) ។ ក្រោយពីសវនាការថ្ងៃនេះ អារម្មណ៍របស់ខ្ញុំមានភាពល្អប្រសើរ ពីព្រោះខ្ញុំគិតថា គាត់នឹងទទួលទោសនៅក្នុងគុកយ៉ាងហោចណាស់រយៈពេលពី៣០ ទៅ៤០ឆ្នាំ ។ ឥឡូវនិយាយពីការសងសឹក វាបានថយចុះបន្តិចម្តងៗហើយ ។ ខ្ញុំបានឮថា ឌុច និយាយពីរបីម៉ាត់ដែរ ប៉ុន្តែ ខ្ញុំឮមិនច្បាស់ទេ ដោយសារមនុស្សនៅជុំវិញខ្ញុំគេជជែកគ្នាច្រើនពេក ។ នៅថ្ងៃដំបូងខ្ញុំមានអារម្មណ៍ខឹងបន្តិចដែរ ក្រោយពីបានឮសម្តីដែលលើកឡើងដោយមេធាវីការពារក្តីសុំឲ្យដោះលែង ឌុច ។ តាមការរំពឹងទុករបស់ខ្ញុំ គឺថា ឌុច នឹងត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាព ។ ចំពោះបញ្ហាប្រធានគុកទាំង១៩៥រូបផ្សេងទៀត សម្រាប់ខ្ញុំប្រសិនបើប្រធានគុកទាំង១៩៥ នោះត្រូវបាននាំយកមកសវនាការកាត់ទោស ខ្ញុំបារម្ភថាអ្វីដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយអំពីសង្គ្រាមស៊ីវិលអាចជាការពិត ។*

### *ហ៊ឹម មុំ អាយុ ៥៣ឆ្នាំ មកពីខេត្តតាកែវ*

*ខ្ញុំមិនសប្បាយចិត្តទាល់តែសោះដោយសារពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានច្រានចោល ។ ការស្លាប់របស់បងប្រុសខ្ញុំគឺជាការពិត តែខ្ញុំត្រូវបដិសេធទៅវិញ ។ ខ្ញុំបានរកឃើញរូបថតបងប្រុសខ្ញុំ (នៅគុកទួលស្លែង) ។ ខ្ញុំមិនសប្បាយចិត្តនឹងមេធាវីរបស់ ឌុច ទេ ។ ខ្ញុំខឹងណាស់ដែលធ្វើឲ្យឈាមខ្ញុំឡើងខ្ពស់ ។ ប្រសិនបើខ្ញុំត្រូវបានគេច្រានចោលម្តងទៀត ខ្ញុំពិតជាមិនអាចទទួលយកបានទេ ។ ខ្ញុំមានរូបថតបងប្រុសខ្ញុំដែលស្លាប់ទៅ ។ ខ្ញុំពិតជាមិនសប្បាយចិត្តទេ ។*

### *លឹម យុន មកពីខេត្តកំពង់ធំ*

*ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានច្រានចោល ដោយសារខ្ញុំមិនមានភ័ស្តុតាង ។ ខ្ញុំមិនខឹងនឹងតុលាការចំពោះការច្រានចោលនោះទេ ពីព្រោះខ្ញុំមិនមានភ័ស្តុតាងគ្រប់គ្រាន់ ។ មេធាវីរបស់ខ្ញុំបានព្យាយាមជួយខ្ញុំ ប៉ុន្តែខ្ញុំមិនអាចស្វែងរកភ័ស្តុតាងដើម្បីយកមក ធ្វើជាអំណះអំណាងបានឡើយ ។ ខ្ញុំនៅតែបន្តចូលរួមនៅក្នុងដំណើរការសវនាការ ទោះបីជាពាក្យបណ្តឹងរបស់ខ្ញុំនៅតែត្រូវគេច្រានចោលក៏ដោយ ។ ខ្ញុំជឿជាក់ថាបងប្រុសរបស់ខ្ញុំពិតជាបានស្លាប់នៅទីនោះ ។*

### *ឆង សារ៉ាត អាយុ ៥៤ មកពីខេត្តសៀមរាប*

*ខ្ញុំចង់ឲ្យ ឌុច ត្រូវគេផ្តន្ទាទោសដាក់គុកច្រើនជាង៤០ឆ្នាំ ទោះបីជាមិនបានមួយជីវិតក៏ដោយ ។ ខ្ញុំគិតថា ឌុច មិនបានលាតត្រដាងការពិតទាំងអស់នោះទេ ។ ឌុច បានទទួលបញ្ជាដោយផ្ទាល់ពី សុន សេន និង នួន ជា ដែលអ្នកទាំងពីរនាក់នេះគឺជាមេដឹកនាំជាន់ខ្ពស់ ។ តួនាទីរបស់គាត់មានលក្ខណៈពិសេស និងមិនអាចយកមកប្រៀបធៀបនឹងប្រធានគុកដទៃទៀតបានទេ ។ គាត់អាចចាប់ខ្លួនជនទាំងឡាយនៅក្នុងបក្ស ភូមិភាគ តំបន់ និង ស្រុក ។ ឌុច មានសិទ្ធិចាប់បានទាំងអស់ ។ តែទោះជាយ៉ាងណា ការសម្រេចចិត្តចុងក្រោយគឺអាស្រ័យទៅលើតុលាការ ។ ប៉ុន្តែប្រសិនបើខ្ញុំជាតុលាការវិញ ឌុច ត្រូវតែមានទោសយ៉ាងហោចណាស់ក៏ត្រូវជាប់គុកទាបបំផុតក៏បាន៤០ឆ្នាំដែរ ។ បើយើងមើលនៅក្នុងច្បាប់បច្ចុប្បន្ន ប្រសិនបើជាអ្នកសម្លាប់មនុស្សម្នាក់ក៏មានទោសដាក់គុកមួយជីវិតដែរ ហើយចុះនេះរាប់ម៉ឺននាក់ ។ តុលាការនេះត្រូវបាន*

បង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជីវិតមនុស្សរាប់លាននាក់ដែលបានបាត់បង់ទឹកភ្នែករាប់លានដំណក់ដែលបានស្រក់ចុះ ហើយប្រសិនបើ ឌុច ត្រូវបានដោះលែង អ្វីៗទាំងអស់នឹងក្លាយទៅជាគ្មានន័យ ។ ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានគេច្រានចោល ហើយខ្ញុំមិនប្រាកដថា ខ្ញុំនឹងត្រូវបានគេទទួលស្គាល់នៅពេលនេះទេ ។ ខ្ញុំប្រាកដជាមានអារម្មណ៍ឈឺចាប់ប្រសិនបើតុលាការមិនទទួលស្គាល់ខ្ញុំ ។ ឯកសារខ្លះនៅទួលស្លែងមិនមានទាំងអស់ទេ ឯកសារខ្លះបានបាត់ទៅហើយ ។ មានរបាយការណ៍ថា ឯកសារខ្លះត្រូវបានគេយកទៅខ្ចប់ចេកចៀន ។ រូបថតខ្លះនៅមានពិតមែន ប៉ុន្តែវាមិនមានឈ្មោះ ។ វាពិបាកនឹងចាំពីព្រោះវាកន្លងផុតទៅ៤០ឆ្នាំទៅហើយ ។ ខ្ញុំត្រូវបានគេបដិសេធនៅពេលចុងបញ្ចប់នៃដំណើរការនីតិវិធី ។ បើប្រាប់ខ្ញុំតាំងពីដំបូងខ្ញុំមិនសូវតូចចិត្តប៉ុន្មានទេ ។ ប៉ុន្តែដល់ពេលចេញសាលក្រមហើយទើបបាននិយាយថាឈ្មោះខ្ញុំត្រូវបដិសេធមិនទទួលស្គាល់ ។ បើសិនជាគេបដិសេធខ្ញុំនៅលើកក្រោយនេះ វាបានន័យថាអត់មានយុត្តិធម៌អ្វីទាំងអស់ ។

### លី ហ៊ា អាយុ ៥៧ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ

ឌុច គឺជាប្រធានមន្ទីរស-២១ ហើយនៅពេលនោះគាត់បានធ្វើទារុណកម្មអ្នកទោសយ៉ាងខ្លាំង ។ ខ្ញុំបានដឹងពីអ្វីៗទាំងអស់ពីព្រោះខ្ញុំក៏នៅក្នុងគុកនោះដែរ ។ ឌុច មិនដែលធ្វើបាបខ្ញុំដោយផ្ទាល់ទេ ប៉ុន្តែគាត់បានចាត់តាំងឲ្យអ្នកដទៃធ្វើបាបអ្នកទោសនៅគុកទួលស្លែង ។ ខ្ញុំត្រូវបានបង្អត់អាហារ វាយធ្វើបាប និងមិនឲ្យគេង, ហូបបាយនិងបត់ជើងនៅកន្លែងតែមួយ ។ ខ្ញុំមិនយល់ស្របនឹងសាលក្រមដែលបានផ្តល់ស្ថានសម្រាលទោសដល់ ឌុច នោះទេ ពីព្រោះគាត់បានធ្វើទារុណកម្មខ្ញុំ និងប្រជាជនដទៃទៀតនៅទូទាំងប្រទេស ។ ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានគេច្រានចោលដោយសារតែការភ័ន្តច្រឡំ ។ ខ្ញុំបានផ្លាស់ប្តូរត្រកូលរបស់ខ្ញុំក្រោយពីរបបខ្មែរក្រហម ។ ខ្ញុំសង្ឃឹមថា ឌុច នឹង ទទួលស្គាល់ខ្ញុំនៅពេលបញ្ចប់ ។ ទោះបីជាតុលាការមិនទទួលស្គាល់ខ្ញុំក៏ដោយក៏មិនអីដែរ ពីព្រោះខ្ញុំបានចូលរួមគ្រប់ដំណើរការនីតិវិធី និងបានចូលរួមធ្វើជាសាក្សី ។ ខ្ញុំនឹងបន្តគាំទ្រតុលាការនេះ ។ ខ្ញុំខ្លួនឯងផ្ទាល់ចង់ឲ្យ ឌុច ត្រូវបានគេដាក់ទោសក្នុងគុកអស់មួយជីវិត ។ ខ្ញុំមិនសប្បាយចិត្តជាមួយនឹងការលើកឡើងរបស់មេធាវីការពារក្តីរបស់ ឌុច នោះទេ ប៉ុន្តែខ្ញុំយល់ថាអ្នកទាំងនោះធ្វើទៅតាមច្បាប់ប៉ុណ្ណោះ ។

### អ៊ឹម វណ្ណៈ ភេទស្រី អាយុ ៤៥ឆ្នាំ មកពីខេត្តតាកែវ

ខ្ញុំស្គាល់ ឌុច តាមរយៈការចូលរួមនៅក្នុងកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងប្អូនស្រីរបស់ខ្ញុំ ។ យើងបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ។ ទាក់ទងនឹងសវនាការបណ្តឹងសាទុក ខ្ញុំកំពុងឆ្ងល់ថាតើក្រុមមេធាវីការពារក្តីរបស់ ឌុច ធ្លាប់បានរស់នៅក្នុងសម័យខ្មែរក្រហមដែរឬទេ ។ ហេតុអ្វីបានជាអ្នកទាំងនោះព្យាយាមការពារ និងស្វែងរកការដោះលែង ឌុច ទៅវិញ? នៅពេលដែលខ្ញុំបានឃើញ ឌុច លើកដំបូង ខ្ញុំពិតជាខឹងខ្លាំងណាស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំទុកឲ្យច្បាប់ជាអ្នកកាត់ក្តីគាត់ទៅចុះ ។ ខ្ញុំក៏មានអារម្មណ៍ធូរស្បើយ ពីព្រោះខ្ញុំជឿទៅលើរឿងកម្មផល ។ យ៉ាងហោចណាស់ គាត់គួរតែត្រូវបានផ្តន្ទាទោស១៩ឆ្នាំ ដូចសាលក្រមកាលពីពេលមុនដែរ ។ ប្រសិនបើ ឌុច អាចដើរហើរសេរីមែននោះ វានឹងមិនមានយុត្តិធម៌សម្រាប់ខ្ញុំនោះទេ ហើយវានឹងក្លាយទៅជាគំរូអាក្រក់មួយសម្រាប់ក្មេងៗជំនាន់ក្រោយ ។ ចំពោះក្រុមមេធាវីការពារក្តីរបស់ ឌុច ដែលបានស្វែងរកការដោះលែងគាត់ឲ្យមានសេរីភាពនោះ គឺជារឿងដែលខ្ញុំមិនអាចទទួលយកបានទេ ប៉ុន្តែខ្ញុំរីករាយជាមួយនឹងសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាដែលព្យាយាមជួយការពារផលប្រយោជន៍ជនរងគ្រោះ និងប្រជាជនកម្ពុជាទូទៅ ។ ទាក់ទងទៅសំណង យើងដែលជាជនរងគ្រោះមិនដែលចង់បានសំណងជាលក្ខណៈបុគ្គលឡើយ ។ យើងចង់បានសំណងដែលមានជាលក្ខណៈជានិមិត្តរូបដើម្បីរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិត ។ យើងអាចសាងសង់ជាស្តូបរំលឹកការចងចាំមួយដើម្បីគោរពទៅដល់ជនរងគ្រោះដែលនៅរស់រានមានជីវិតនិងរំលឹកអ្នកទាំងនោះ ។ យើងក៏អាចឆ្លាក់ឈ្មោះរបស់ជនរងគ្រោះនៅលើថ្មដើម្បីជាការចងចាំមួយសម្រាប់អ្នកទាំងនោះ ។ ខ្ញុំសង្ឃឹមថា តុលាការនឹងស្វែងរកយុត្តិធម៌ឲ្យយើង ហើយ ឌុច នឹងត្រូវបានផ្តន្ទាទោសដាក់ក្នុងពន្ធនាគារ ។ **អាន ហាញឌុល**

# បណ្តឹងឧទ្ធរណ៍របស់ កាំង ហ្កេកអ៊ាវ

## ថ្ងៃទី២៨ ខែមីនា : «ឌុច គឺគ្រាន់តែជាឧបករណ៍មួយតែប៉ុណ្ណោះ»

តុលាការថ្ងៃដំបូងនៃបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្កេកអ៊ាវ ហៅ (ឌុច) នៅចំពោះមុខតុលាការកំពូលមានភាពចង្អៀតបន្តិច ដោយសារមានប្រជាជនខ្មែរជាច្រើននាក់បានមកតាមដានដំណើរការកាត់ទោសនេះ ។

ដំណើរការនីតិវិធីបានចាប់ផ្តើមដោយការអានសេចក្តីសង្ខេបនៃសាលក្រមរបស់អង្គបុរេជំនុំជម្រះសាលាដំបូងដោយលោក គង់ ស្រ៊ឹម ប្រធានអង្គជំនុំជម្រះតុលាការកំពូលដែលក្នុងនោះរួមមាន បទឧក្រិដ្ឋកម្មដែល ឌុច ត្រូវបានចោទប្រកាន់ សាលក្រមកាត់ទោស៣៥ឆ្នាំនិងដំណើរការសមស្របនៃការរំលោភបំពានដែលត្រូវបានកាត់បន្ថយទោសប្រាំឆ្នាំ ។ បន្ទាប់មកទៀត លោកប្រធានបានសង្ខេបដំណាក់កាលនៃដំណើរការនីតិវិធីសម្រាប់អង្គជំនុំជម្រះតុលាការកំពូល រួចហើយក៏ផ្តល់ភារកិច្ចឲ្យមេធាវីការពារក្តីដើម្បីលើកឡើងពីអង្គហេតុរបស់ខ្លួនដែលអះអាងថាសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គួរតែចាត់ទុកជាមោឃៈហើយ ឌុច ត្រូវតែដោះលែងឲ្យមានសេរីភាព ។

ឌុច បាននិយាយមុនគេ ដោយគ្រាន់តែគូសបញ្ជាក់ពីការជឿជាក់របស់ខ្លួនថាអង្គបុរេជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងនៅក្នុងសេចក្តីសម្រេចលើយុត្តាធិការផ្នែកបុគ្គលមកលើ ឌុច ដូច្នេះ មេធាវីរបស់ ឌុច មានសិទ្ធិអំណាចធ្វើជាតំណាងឲ្យ ឌុច នៅចំពោះមុខអង្គបុរេជំនុំជម្រះរបស់តុលាការកំពូល ។

### បណ្តឹងឧទ្ធរណ៍របស់ ឌុច

សហមេធាវីការពារក្តីជាតិរបស់ ឌុច លោក ការ សាវុត្ថ បានលើកឡើងពីអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី ។ អស់រយៈពេលជាងមួយម៉ោងហាសិបនាទី លោក សាវុត្ថ ហាក់ដូចជាបានប្រើប្រាស់វិធីសាស្ត្រអំណះអំណាងគ្រង់ៗដោយធ្វើការលើកឡើងពីអំណះអំណាងមួយទៅអំណះអំណាងមួយទៀត ដោយសង្ឃឹមថាអត្ថន័យខ្លះនៃអំណះអំណាងទាំងអស់នោះនឹងជាប់ពាក់ព័ន្ធគ្នា ។ ក្នុងនោះមានអត្ថន័យសំខាន់មួយ នៅពេលដែលលោក សាវុត្ថ បានប្រៀបធៀបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅនឹងការរំលោភបំពានព្រំដែនពីថៃមកលើប្រទេសកម្ពុជា ហើយប្រៀបធៀប ឌុច ទៅនឹងយន្តហោះដែលទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាតាមបញ្ជារបស់អតីតប្រធានាធិបតី រីឆាត និចសុន ។ អត្ថន័យនៃការប្រៀបធៀបសាលាក្តីខ្មែរក្រហមទៅនឹងការរំលោភបំពានពីថៃមកលើប្រទេសកម្ពុជាត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពីគោលជំហររបស់មេធាវីការពារក្តីដែលថាតុលាការបានពង្រីកដែនយុត្តាធិការបស់ខ្លួនក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមដោយខុសច្បាប់ ។ ហើយអត្ថន័យចុងក្រោយដែលប្រៀបធៀប ឌុច ទៅនឹងយន្តហោះទម្លាក់គ្រាប់បែករបស់អាមេរិក ក៏ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីអំណះអំណាងរបស់មេធាវីការពារក្តីដែលថា ឌុច គ្រាន់តែធ្វើតាមបញ្ជារបស់ថ្នាក់លើតែប៉ុណ្ណោះ ដូច្នេះ ឌុច មិនត្រូវ



ការ សាវុត្ថ (រូបថត អ.វ.ត.ក)

នាំខ្លួនមកកាត់ទោសឲ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់នេះឡើយ ។

បើសរុបសេចក្តីអំណះអំណាងរបស់មេធាវីការពារក្តី យើងឃើញថាអំណះអំណាងសំខាន់របស់មេធាវីការពារក្តីគឺថា ១) អង្គបុរេជំនុំជម្រះសាលាដំបូងបានមានកំហុសឆ្គងនៅក្នុងការបកស្រាយមាត្រា២នៃច្បាប់សាលាក្តីខ្មែរក្រហម និងមាត្រា២នៃកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិដែលបានផ្តល់យុត្តាធិការឲ្យតុលាការធ្វើការកាត់ទោស "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងអ្នកដែលមានការទទួលខុសត្រូវខ្ពស់លើឧក្រិដ្ឋកម្ម" របស់របបនោះ និង ២) អង្គបុរេជំនុំជម្រះសាលាដំបូងមិនបានធ្វើការពិចារណាលើវិធានផ្ទៃក្នុង៨៧ នៅពេលដែលអង្គជំនុំជម្រះបានសម្រេចថាការចោទប្រកាន់របស់មេធាវីការពារក្តីពីបញ្ហាយុត្តាធិការមិនអាចទទួលយកបានយោងតាមមាត្រា៨៩នៃវិធានផ្ទៃក្នុង ។

## យុត្តាធិការផ្នែកបុគ្គល

លោកមេធាវីការពារក្តី ការ សាវុត្ថ បានចំណាយពេលវេលាយ៉ាងច្រើនសង្កត់ធ្ងន់លើចំណុច ដែលថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ដូច្នេះ ឌុច មិនមែនជាបុគ្គលដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មនៅរបបនោះឡើយ ។ លោក សាវុត្ថ បានរំឭកតុលាការថា យោងតាមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គោលបំណងរបស់សាលាក្តីខ្មែរក្រហម គឺដើម្បីស្វែងរកសន្តិភាព និងការផ្សះផ្សាដល់ប្រជាជនកម្ពុជាដោយគោរពទៅតាមអធិបតេយ្យភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដើម្បីសម្រេចដូច្នេះបាន លោក សាវុត្ថ បានអះអាងថា តុលាការត្រូវតែគោរពតាមគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលអនុញ្ញាតឲ្យមានការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលជនទាំងនោះមានសិទ្ធិអំណាចចេញបញ្ជានិងបង្គាប់ ។ លោក សាវុត្ថ បាននិយាយថា "ឌុច គ្រាន់តែជាប្រធានគុកម្នាក់តែប៉ុណ្ណោះ ដូច្នេះ តើ ឌុច ឬក៏មេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវខ្ពស់"? ឌុច គឺគ្រាន់តែជា "អាយ៉ង" ម្នាក់តែប៉ុណ្ណោះ ។

លោក សាវុត្ថ បានអះអាងថា ដោយសារតែ ឌុច មិនមែនជាសមាជិករបស់គណៈកម្មការអចិន្ត្រៃយ៍នោះ ឌុច មិនអាចចាត់ទុកថាជាមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានកាត់ទោសនៅក្រោមយុត្តាធិការរបស់សាលាក្តីខ្មែរក្រហមឡើយ ។ អំណះអំណាងនេះបានបញ្ជាក់ពីអត្ថន័យរួមគ្នានៃមាត្រា២នៃច្បាប់សាលាក្តីខ្មែរក្រហម និងមាត្រា២នៃកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដែលយោងតាមលោក សាវុត្ថ ថែងថា មានតែមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះដែលត្រូវបានចាត់ទុកថាជាជនដែលមានការទទួលខុសត្រូវខ្ពស់ ។ យ៉ាងណាមិញ អំណះអំណាងនេះមិនមែនជាសេចក្តីដកស្រង់ចេញពីមាត្រាទាំងពីរខាងលើទេ ពីព្រោះ នៅពេលដែលចៅក្រម ចាន់ជ្រា នីហល ចាយ៉ាស៊ីងហេ ថា តើអំណះអំណាងនេះគឺជាការអះអាងរបស់ភាគីមេធាវីការពារក្តីរបស់ ឌុច នោះ សហមេធាវីការពារក្តីរបស់ ឌុច លោក កង ឫទ្ធារី បានបញ្ជាក់ថានេះគឺជាអំណះអំណាងរបស់ភាគីមេធាវីការពារក្តី ។ បន្ទាប់ពីបានអះអាងថាមានតែមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះដែលអាចត្រូវបានកាត់ទោសនៅចំពោះមុខសាលាក្តីខ្មែរក្រហមមក លោក សាវុត្ថ បានចោទសួរសំណួរមួយថាតើ ឌុច អាចចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បានយ៉ាងដូចម្តេចទៅ? លោកបានដកស្រង់ពាក្យសម្តីរបស់លោកស្រីចៅក្រម ខាត់វ៉ាយ ដែលបាននិយាយថាបក្សកុម្មុយនីស្តកម្ពុជាបានធ្វើសេចក្តីសម្រេចលើបញ្ហាទាំងអស់ រួមទាំងបញ្ហាអ្នកដែលត្រូវឃុំឃាំងនៅមន្ទីរសន្តិសុខនិងអ្នកដែលត្រូវកម្ទេចចោល ។ ជាមួយគ្នានេះ លោកក៏បានលើកឡើងពីឯកសារដែលបញ្ជាក់ថា ឌុច មិនមែនជាសមាជិករបស់គណៈកម្មការអចិន្ត្រៃយ៍នោះទេ ។ លោកបានបញ្ជាក់អស់ជាច្រើនលើកថា ឌុច គឺជាលេខាថ្នាក់ទាបដែលគ្មានសិទ្ធិអំណាចអ្វីឡើយ ។ ដូច្នេះទោសកំហុសទាំងអស់គឺឋិតនៅលើ ប៉ុល ពត, សុន សេន, និង នួន ជា នោះវិញទេ ។ "ឌុច គ្រាន់តែជាឧបករណ៍សម្រាប់ប្រើប្រាស់តែប៉ុណ្ណោះ" ។

ជាចុងបញ្ចប់ លោក សាវុត្ថ បានចំណាយពេលបញ្ជាក់ថាក្នុងរបបខ្មែរក្រហមមន្ទីរសន្តិសុខចំនួន១៩៥ ត្រូវបានបង្កើតឡើង ហើយនៅតាមមន្ទីរសន្តិសុខនីមួយៗមានប្រធានគុកម្នាក់

ប៉ុន្តែ ហេតុអ្វីមានតែ ឌុច ម្នាក់ដែលត្រូវនាំមកកាត់ទោស ។ ដោយផ្តោតលើការកាត់ទោសរួម លោក សាវុត្ថ បានសួរថា «តើការសម្លាប់នៅគុកផ្សេងទៀតមិនមែនធ្វើឡើងដោយចេតនាយ៉ាងដូចម្តេច? តើអ្នកទោសនៅតាមមន្ទីរសន្តិសុខផ្សេងទៀតនោះត្រូវបានឃុំខ្លួនដោយស្របច្បាប់ឬ? តើនៅគុកទាំងនោះមិនមានការធ្វើទារុណកម្មឬ? តើអ្នកទោសទាំងនោះត្រូវឃុំខ្លួនទុកនៅសណ្ឋាគារឬ?

ក្រោយពីធ្វើការសុំខមាទោសដល់ជនរងគ្រោះ និងប្រាប់អ្នកតាមដានដំណើរការតុលាការថា ខ្លួនក៏មានសាច់ញាតិដែលបានស្លាប់ដោយសារឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមរួចមក លោកមេធាវី ឫទ្ធារី បានបន្តលើកឡើងពីអំណះអំណាងផ្នែកយុត្តាធិការរបស់លោក ការ សាវុត្ថ ដោយផ្តោតលើចំនុចយ៉ាងច្រើន ។ លោកបានបញ្ជាក់ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឌុច ឋិតនៅក្រោមយុត្តាធិការផ្នែកបុគ្គលបានក្លាយជាការពង្រីកដែនសមត្ថកិច្ចផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងទៅវិញទេ ដែលនេះគឺជាការរំលោភលើទ្រឹស្តីច្បាប់ខមិនឡ ។ លោកបាននិយាយថា «ជនដែលមិនឋិតនៅក្រោមយុត្តាធិការរបស់តុលាការទេ មានតែជនមេគំនិតទេ» ។

## មាត្រា៨៩នៃវិធានផ្ទៃក្នុង ៖ សេចក្តីជំទាស់បឋម

សេចក្តីអំណះអំណាងលើកទីពីររបស់មេធាវីការពារក្តី ឌុច បានផ្តោតលើសំណួរដែលតើការសួរដេញដោលពីយុត្តាធិការត្រូវតែក្លាយជាសេចក្តីជំទាស់បឋមដើម្បីឲ្យចាត់ទុកជាបណ្តឹងឧទ្ធរណ៍យោងតាមមាត្រា៨៩នៃវិធានផ្ទៃក្នុង ឬក៏ការសួរដេញដោលនេះអាចនឹងធ្វើឡើងក្នុងអំឡុងពេលនៃអង្គជំនុំជម្រះនៅពេលដែលភស្តុតាងថ្មីត្រូវបានដាក់បន្ថែមយោងតាមមាត្រា៨៧នៃវិធានផ្ទៃក្នុង ។ យ៉ាងណាមិញ សេចក្តីអំណះអំណាងតែឯកឯងរបស់មេធាវីការពារក្តីមិនបានបង្ហាញពីគោលបំណងច្បាស់លាស់របស់ខ្លួន ហើយបែរជាចំណាយពេលធ្វើការចោទប្រកាន់ថាសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងអាក់ខានមិនបានពិចារណាលើភស្តុតាងដាក់បន្ទុកដែលបង្ហាញថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជនដែលមានការទទួលខុសត្រូវខ្ពស់លើឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យឡើយ ។

មេធាវីការពារក្តីក៏បានលើកឡើងថាការឃុំខ្លួន ឌុច គួរតែចាត់ទុកថាជា «ការការពារសាក្សី» ពីព្រោះការឃុំខ្លួននេះគឺខុសច្បាប់ ហើយដោយសារតែ ឌុច បានធ្វើការសហការជាមួយតុលាការជាដរាប ដោយភ្ជាប់មកជាមួយនឹងភស្តុតាងស្តីពីរចនាសម្ព័ន្ធរបស់គណៈកម្មការអចិន្ត្រៃយ៍ និងតួនាទីរបស់មន្ទីរស-២១សម្រាប់របបកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងនៃអំណះអំណាងនេះមានលក្ខណៈមិនច្បាស់លាស់ប៉ុន្មានទេ ហើយការអះអាងនេះបានធ្វើឲ្យចៅក្រមសួរសំណួរមួយចំនួន ហើយនៅតែទទួលបានចម្លើយមិនសូវច្បាស់ដដែល ។

## ការឆ្លើយតបរបស់ព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញា ជា លាង បានធ្វើបទបង្ហាញពីការឆ្លើយតបរបស់ភាគីព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ឌុច ហើយបានផ្តោតទៅលើឥទ្ធិពល ឌុច មានលើការធ្វើសេចក្តីសម្រេចចិត្ត និងតួនាទីដាច់ដោយឡែកមួយរបស់មន្ទីរស-២១ ។ លោកស្រីបានលើកឡើងពីភស្តុតាងដែលថា ឌុច បានរាយការណ៍ផ្ទាល់ទៅដល់គណៈកម្មការអចិន្ត្រៃយ៍ ហើយកំណត់ត្រារបស់ ឌុច នៅលើចម្លើយសារភាពរបស់អ្នកទោសបានបង្ហាញយ៉ាងច្បាស់ថា ឌុច មានអំណាច



សហព្រះរាជអាជ្ញាជាតិ ជា លាង (រូបថត អ.វ.ត.ក)

ក្នុងការសម្រេច «កម្មុច» ជនណាម្នាក់ ។ ជាមួយគ្នានេះ លោកស្រីក៏បានគូសបញ្ជាក់ថាខុសពីប្រធានគុកផ្សេងទៀត ឌុច មានអំណាចក្នុងការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់កម្មាភិបាលខ្មែរក្រហមថ្នាក់ខ្ពស់ទាំងអស់នៅក្នុងប្រទេស ។ ហេតុដូច្នេះ លោកស្រីបានអះអាងថា មន្ទីរស-២១គឺជាផ្នែកមួយដ៏សំខាន់នៃរបបខ្មែរក្រហម ដូច្នេះក្នុងនាមជាប្រធានគុកនេះ ឌុច ពិតជាសមនឹងត្រូវបានចាត់ទុកជាជនដែលមាន «ការទទួលខុសត្រូវខ្ពស់បំផុត» ។ លោកស្រីបានសម្រេចថាអង្គជំនុំជម្រះសាលាដំបូងពិតជាមានយុត្តាធិការត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការកាត់ទោស ឌុច ។

ដូចគ្នានឹងក្រុមមេធាវីការពារក្តី ចៅក្រមបានសួរព្រះរាជអាជ្ញាថាតើអត្ថន័យនៃ «ជនដែលទទួលខុសត្រូវខ្ពស់» និង «មេដឹកនាំជាន់ខ្ពស់» គួរតែអានភ្ជាប់គ្នានោះ លោកសហព្រះរាជអាជ្ញាអន្តរជាតិ អេនទ្រូ ខេលៃ បានក្រោកឈរឡើងបង្ហាញអង្គជំនុំជម្រះនូវភស្តុតាងដែលគណៈកម្មការក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិ និងរដ្ឋសភាជាតិកម្ពុជាមានគោលដៅធ្វើឲ្យអត្ថន័យនៃឃ្លាទាំងពីរនេះបែកដាច់ដោយឡែកពីគ្នា នៅពេលដែលក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ និងរដ្ឋសភាជាតិកំណត់ដែនសមត្ថកិច្ចយុត្តាធិការរបស់សាលាក្តីខ្មែរក្រហមមុននឹងការបង្កើតឡើងតុលាការកាត់ទោសនេះ ។

## សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

មាត្រា២ នៃច្បាប់ និងមាត្រា២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាត្រូវបានចាត់ទុកជាបញ្ហាចម្បងនៅក្នុងអង្គសវនាការនាថ្ងៃនេះ ប៉ុន្តែសំណួរដែលសួរថាតើមាត្រាទាំងពីរនេះគួរតែធ្វើការពិនិត្យផ្ទៀងផ្ទាត់ផ្នែកច្បាប់ឡើងវិញនោះ បែរជាមិនសូវទទួលបានការផ្តោតនិងយកចិត្តទុកដាក់ទៅវិញ ។ ក្រោយពេលដែលភាគីមេធាវីការពារក្តី និងព្រះរាជអាជ្ញាបានបង្ហាញអំណះអំណាងរបស់ខ្លួន ក្រោយមកចៅក្រម ម៉ូតូ ណូហ្គូឈិ បានសួរសំណួរទៅកាន់ព្រះរាជអាជ្ញាថា តើឃ្លា «មេដឹកនាំជាន់ខ្ពស់និងជនដែលមានការទទួលខុសត្រូវខ្ពស់» ត្រូវបានប្រើប្រាស់ធ្វើជាគោលការណ៍ណែនាំផ្លូវច្បាប់ដោយសហព្រះរាជអាជ្ញា ឬនៅពេលដែលព្រះរាជអាជ្ញាអនុវត្តសិទ្ធិអំណាចរបស់ខ្លួន បើដូច្នេះតើឃ្លាទាំងពីរនេះគួរតែត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ឬមួយក៏ឃ្លាទាំងនេះគឺជាលក្ខន្តិកៈផ្នែកយុត្តាធិការ ដែលត្រូវតែពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ។ ព្រះរាជអាជ្ញាបានឆ្លើយតបថា ឃ្លានេះគួរតែត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ប៉ុន្តែភាគីព្រះរាជអាជ្ញាអាក់ខានមិនអាចផ្តល់មូលដ្ឋានផ្លូវច្បាប់សម្រាប់មតិរបស់ខ្លួន ។ មេធាវីការពារក្តីមិនបានលើកឡើងពីមតិរបស់ខ្លួនទាក់ទងនឹងបញ្ហានេះទេ បើទោះបីជាការសួរដេញដោលពីយុត្តាធិការរបស់តុលាការនិងសំណូមពរឲ្យដោះលែងជនជាប់ចោទឆ្លុះបញ្ចាំងពីជំនឿដែលថាឃ្លានេះតម្រូវឲ្យមានការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញក៏ដោយ ។

## សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះថ្ងៃនេះបានបញ្ចប់ទៅដោយការថ្លែងសេចក្តីសន្និដ្ឋានអស់ពេលសាមសិបនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ម៉ាទីន ហ្សាកាំង ។ បើទោះបីជាសេចក្តីសន្និដ្ឋាននេះមានលក្ខណៈលម្អិត និងលំដាប់លំដោយក៏ដោយ ក៏វាគ្រាន់តែជាសេចក្តីសង្ខេបឡើងវិញនូវការអះអាងរបស់មេធាវី របស់ ឌុច និងការសង្កត់ធ្ងន់ឡើងវិញលើចំនុចរបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។ មេធាវីការពារក្តីបានមានមតិយោបល់ជាចុងក្រោយដោយនិយាយថាដើមបណ្តឹងរដ្ឋប្បវេណីគួរតែដោះស្រាយគ្រោះថ្នាក់ ដែលបានប្រព្រឹត្តមកលើជនរងគ្រោះ និងសំណងសមរម្យ


មេធាវីដើមបណ្តឹងរដ្ឋប្បវេណី (រូបថត អ.វ.ត.ក)

មួយដែលតុលាការគួរតែផ្តល់ឲ្យជនរងគ្រោះ ។

## ថ្ងៃទី២៩ មីនា: តុលាការអន្តរជាតិ ឬតុលាការជាតិ?

ថ្ងៃទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ (ឌុច) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលបានផ្តោតលើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានផ្អែកច្បាប់ថាអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិខុស ហើយសម្រេចកាត់ទោសស្រាលពេកដល់ជនជាប់ចោទ ។ ស្របពេលដែលមានការផ្លាស់ប្តូរប្រធានបទដេញដោលនេះ ក៏មានការផ្លាស់ប្តូរវិធីសាស្ត្រដោយសហព្រះរាជអាជ្ញា អេនទ្រូ ខេលៃ បានប្រើប្រាស់វិធីសាស្ត្រស្ងប់ស្ងៀមដែលខុសពីវិធីសាស្ត្រកាលពីម្សិលមិញរបស់មេធាវីការពារក្តី ការ សាវុត្ថ ដែលបានធ្វើបទបង្ហាញដោយប្រើវោហាស័ព្ទធ្ងន់ៗ ។

ចៅក្រម អេកញ៉ើស្កា កូណូរីកកា មីឡាត បានចាប់ផ្តើមដំណើរនីតិវិធីដោយអានបណ្តឹងឧទ្ធរណ៍របស់ភាគីព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណីលើសាលក្រម ។ ព្រះរាជអាជ្ញាបានសំណូមពរឲ្យមានការវិនិច្ឆ័យទោសពីបទចោទប្រកាន់លើនិងបន្ថែមទោសឲ្យ ឌុច ម្តងទៀត ចំណែកឯមេធាវីការពារក្តីទាមទារឲ្យមានការបន្ធូរបន្ថយទោស ។

ការលើកឡើងពីអំណះអំណាងផ្អែកច្បាប់ឲ្យជាក់លាក់គឺជាវិធីសាស្ត្រខុសប្លែកគ្នាដែលព្រះរាជអាជ្ញានិងមេធាវីការពារក្តីបានប្រើប្រាស់ ។ ជាក់ស្តែង លោកព្រះរាជអាជ្ញា អេនទ្រូ ខេលៃ បានលើកឡើងពីអំណះអំណាងដោយសំណូមពរឲ្យអង្គជំនុំជម្រះតុលាការកំពូលឈរលើគោលជំហររបស់ខ្លួនក្នុងនាមជាតុលាការអន្តរជាតិដែលមានប្រព័ន្ធច្បាប់ខុសគ្នាពីច្បាប់កម្ពុជា ។ លោកបានស្នើសុំឲ្យតុលាការចាប់យកឱកាសដ៏សំខាន់នេះដើម្បីលើកកម្ពស់យុត្តិសាស្ត្រអន្តរជាតិផ្អែកច្បាប់ដោយសម្លឹងមើលវិធីសាស្ត្រគំរូរបស់តុលាការផ្សេងទៀត ។ គោលការណ៍នេះពិតជាមានសារៈសំខាន់ដោយសារការអះអាងនីមួយៗរបស់ព្រះរាជអាជ្ញាមានសេចក្តីអំណះអំណាងពីច្បាប់ករណីអន្តរជាតិ ។ ចំណែកឯមេធាវីការពារក៏បានរំឭកអង្គជំនុំជម្រះភ្លាមៗពេញមួយពេលថាសាលាក្តីខ្មែរក្រហមកើតឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដូច្នេះអង្គជំនុំជម្រះគួរតែត្រូវគោរពទៅតាមច្បាប់កម្ពុជាដែរ ។

## ការចោទប្រកាន់បន្ថែមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

មូលដ្ឋានផ្អែកច្បាប់ដំបូងសម្រាប់បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាគឺទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីរាប់បញ្ចូលបទចោទប្រកាន់ទាំងអស់ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលក្នុងនោះរួមមាន អំពើឃាតកម្ម ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងការធ្វើពលកម្មទាំងបង្ខំដែលទាំងអស់នេះស្ថិតនៅក្រោមឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ។ ដោយបង្ហាញពីការព្រួយបារម្ភសម្រាប់ការផ្សះផ្សាជាតិនិងកំណត់ត្រាជាប្រវត្តិសាស្ត្រដោយសាលាក្តីខ្មែរក្រហម លោក អេនទ្រូ ខេលៃ បានជំរុញឲ្យអង្គជំនុំជម្រះតុលាការកំពូលបែងចែកបទល្មើសនីមួយៗនេះជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នា ។ លោកបានបញ្ជាក់ថា ការមិនបែងចែកឧក្រិដ្ឋកម្មនេះអាចនឹងធ្វើឲ្យទម្ងន់នៃបទឧក្រិដ្ឋរបស់ ឌុច មានកម្រិតស្រាល ហើយអាចនឹងធ្វើឲ្យក្មេងជំនាន់ក្រោយ យល់ខុសចំពោះអ្វីដែល ឌុច បានធ្វើមកលើប្រជាជនកម្ពុជា ។

លោក អេនទ្រូ ខេលៃ បានគាំទ្រអំណះអំណាងគោលការណ៍របស់ខ្លួនដោយដកស្រង់ច្បាប់ករណីពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងសម្រាប់រ៉ាន់ដា ។ លោកបានអះអាងថាយុត្តិសាស្ត្រអន្តរជាតិផ្តល់ជាបទចោទប្រកាន់ព្រហ្មទណ្ឌទ្វេដងសម្រាប់ឧក្រិដ្ឋកម្មដូចគ្នាឲ្យតែបទល្មើសនីមួយៗមានឯកសារដែលទាមទារឲ្យមានភស្តុតាងបញ្ជាក់លើបទល្មើសនោះមិនមែនបទល្មើសផ្សេងទៀតនោះ ។ លោកបានពន្យល់បកស្រាយពីហេតុផលដែលករណីនេះមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មរបស់ ឌុច ជាឧទាហរណ៍ ដោយធ្វើការប្រៀបធៀប ពីការធ្វើទុក្ខបុកម្នេញ និង អំពើមនុស្សឃាត ។ អំពើមនុស្សឃាតតម្រូវឲ្យមានភស្តុតាងដែលថា ជនជាប់ចោទបានបង្កឲ្យមានការសម្លាប់មនុស្សខុសពីការធ្វើទុក្ខបុកម្នេញដែលមិនតម្រូវឲ្យមានភស្តុតាងដូច្នេះទេ ។ ចំណែកការធ្វើទុក្ខបុកម្នេញ តម្រូវឲ្យមានកាបង្ហាញឲ្យឃើញពីចេតនារើសអើងដែលផ្ទុយពីអំពើឃាតកម្ម ។ មេធាវីការពារក្តីមិនបានធ្វើការឆ្លើយតបអ្វីឡើយ ។

## ការរំលោភផ្លូវភេទជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានលើកឡើងពីអំណះអំណាងរបស់ខ្លួនស្តីពីមូលហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ខុសដោយចាត់ទុកការរំលោភផ្លូវភេទជាផ្នែកមួយនៃការធ្វើទារុណកម្ម ដោយមិនទទួលស្គាល់ថាការរំលោភផ្លូវភេទនេះគឺជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅវិញ ។ លោកសហព្រះរាជអាជ្ញា អេនទ្រូ ខេលៃ បានរៀបរាប់ពីប្រវត្តិនៃការរំលោភផ្លូវភេទ ថាជាបទល្មើសដែលទទួលស្គាល់ដោយប្រទេសស៊ីវិលដូចជាក្រម លីប៊ី ឆ្នាំ១៩៦៣ ស្តីពីសង្គ្រាមស៊ីវិលរបស់អាមេរិក ហើយរួមមានការដកស្រង់ចេញពីរដ្ឋធម្មនុញ្ញទីក្រុងឡាអេ, រដ្ឋធម្មនុញ្ញទីក្រុងហ្សឺណែវ និងច្បាប់លេខ១០ នៃច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងឆ្នាំ១៩៤៥ ។ លោកបានបញ្ជាក់ថាចាប់តាំងពីឆ្នាំ១៩៤៥មក ការរំលោភផ្លូវភេទត្រូវចាត់ទុកយ៉ាងច្បាស់លាស់ថាជាឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូច្នេះការចោទប្រកាន់ ឌុច ពីបទរំលោភផ្លូវភេទថាជាបទល្មើសមួយដែលខុសពីការធ្វើទារុណកម្មមិនបានរំលោភបំពានលើគោលការណ៍ច្បាប់ឡើយ ។ លោកបានលើកអំណះអំណាងមកគាំទ្រសេចក្តីអះអាងរបស់ព្រះរាជអាជ្ញាដោយដកស្រង់ជាឯកសារយោងជាច្រើនចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ដែលតុលាការទាំងអស់នេះបានចាត់ទុកការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។


សហព្រះរាជអាជ្ញាអន្តរជាតិ អេនទ្រូ ខេលៃ (រូបថត អ.វ.ត.ក)

លោក អេនទ្រូ ខេលៃ បានបកស្រាយថា គោលការណ៍ផ្នែកច្បាប់ មិនតម្រូវឲ្យបទល្មើសចងក្រងជាច្បាប់មុនពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនេះឡើយ ។ ផ្ទុយទៅវិញ គោលការណ៍ផ្នែកច្បាប់ត្រូវបានបំពេញលក្ខខណ្ឌរបស់ខ្លួន នៅពេលដែលជនដៃដល់បានដឹងជាមុនថាការប្រព្រឹត្តរបស់ខ្លួនគឺមានទោស ។ លោក អេនទ្រូ ខេលៃ បានអះអាងថាភ័ស្តុតាងនិងកំណត់ត្រាជាប្រវត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់លាស់ថា ឌុច បានដឹងថាការរំលោភផ្លូវភេទនៅមន្ទីរស-២១គឺជាបទល្មើស ។

លោក កង ឫទ្ធារី សហមេធាវីការពារក្តីបានឆ្លើយតបទៅនឹងការអះអាងរបស់ព្រះរាជអាជ្ញាវិញដោយក្រើនរំឭកតុលាការថាតុលាការមិនមានយុត្តាធិការក្នុងការកាត់ទោស ឌុច ទេ ។ លោកបានជំទាស់ថា ឌុច មិនគួរត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវសម្រាប់អំពើរំលោភផ្លូវភេទដែលបានកើតឡើងនៅមន្ទីរស-២១ទេ ពីព្រោះថា ឌុច បានដាក់ទណ្ឌកម្មជនដៃដល់ ហើយបានចាត់វិធានការភ្លាមៗ ដើម្បីការពារកុំឲ្យមានករណីរំលោភផ្លូវភេទនេះកើតឡើងនាពេលអនាគត ។ បន្ទាប់មកលោក ការ សាវុត្ថ បានធ្វើសេចក្តីសន្និដ្ឋានដ៏សង្ខេបថា ដោយសារតែការខ្វះខាតនូវមូលដ្ឋានផ្នែកច្បាប់ ការរំលោភផ្លូវភេទនៅមន្ទីរស-២១ មិនអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានទេ ពីព្រោះករណីនេះបានកើតឡើងតែម្តងគត់ ដូច្នេះវាមិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មជាលក្ខណៈប្រព័ន្ធនិងទ្រង់ទ្រាយធំបានឡើយ ។

## ការដាក់ជាទាសករ និងការធ្វើពលកម្មទាំងបង្ខំ

ចុងក្រោយបង្អស់ ព្រះរាជអាជ្ញាបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានមានកំហុសឆ្គង ដោយដាក់បញ្ចូលការធ្វើពលកម្មទាំងបង្ខំទៅក្នុងនិយមន័យនៃការដាក់ជាទាសករ ។ លោក អេនទ្រូ ខេលៃ បានបញ្ជាក់ថាកំហុសឆ្គងនេះបានបណ្តាលឲ្យអង្គជំនុំជម្រះសាលាដំបូងមិនធ្វើការចោទប្រកាន់ ឌុច ពីបទប្រព្រឹត្ត

ជាច្រើនទៀតនៃការដាក់ជាទាសករនៅឯមន្ទីរស-២១ ។ នៅក្នុងសាលក្រមសំណុំរឿង០០១អង្គជំនុំជម្រះសាលាដំបូងបានចោទប្រកាន់ ឌុច ពីបទការដាក់ជាទាសករលើអ្នកទោសទាំងអស់នៅមន្ទីរស-២៤ (ទីកន្លែងធ្វើពលកម្មរបស់មន្ទីរស២១) និងអ្នកទោសនៅមន្ទីរស-២១ ទាំងអស់ដែលត្រូវបានបង្ខំឲ្យធ្វើពលកម្ម ។ លោក អេនទ្រូ ខេលៃ បានជំរុញឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការ កំណត់ឡើងវិញលើនិយមន័យ និងការចោទប្រកាន់ ឌុច របស់អង្គជំនុំជម្រះសាលាដំបូងពីបទការដាក់ជាទាសករមកលើអ្នកទោសទាំងអស់នៅមន្ទីរស-២១ ។

លោក ឫទ្ធារី មេធាវីការពារក្ដីបានឆ្លើយតបយ៉ាងសង្ខេបទៅវិញដោយបដិសេធនឹងការអះអាងខាងលើដែលថាការដាក់ជាទាសករ និងការធ្វើពលកម្មទាំងបង្ខំបានកើតឡើង ។ លោកបាននិយាយថាអ្នកទោសអាច «ដើរដោយសេរី» និងត្រូវបានទទួលរងការប្រព្រឹត្តដោយស្មើភាពគ្នាទៅនឹងកម្មាភិបាលខ្មែរក្រហម ។ «បើទោះបីជាអ្នកទោសមន្ទីរស-២១ និងស-២៤ ត្រូវបានឃុំខ្លួនក៏ដោយ ក៏អ្នកទោសនោះអាចទៅធ្វើការងារបាន ។ សូម្បីតែកម្មាភិបាលខ្មែរក្រហមក៏ទទួលរងការបង្ខិតបង្ខំខ្លះៗដែរ» ។

## ការស្នើទោស

សហព្រះរាជអាជ្ញាបានអះអាងថាកំហុសឆ្គងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបណ្ដាលឲ្យមានការផ្ដន្ទាទោសដែល «មានកម្រិតមិនធ្ងន់ធ្ងរគ្រប់គ្រាន់» ដូច្នេះព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាកំពូលបង្កើនទោសនេះពី៣៥ឆ្នាំមកការជាប់ទោសអស់មួយជីវិត ។ យ៉ាងណាមិញ ព្រះរាជអាជ្ញាក៏បានទទួលស្គាល់ថាការរំលោភបំពានផ្លូវច្បាប់លើរយៈពេលឃុំខ្លួន ឌុច នៅមន្ទីរឃុំឃាំងយោធាដោយខុសច្បាប់ពិតជាតម្រូវឲ្យមានការកាត់បន្ថយទោសរយៈពេល៥ឆ្នាំ ។ ដូច្នេះ ការស្នើសុំចុងក្រោយពីសំណាក់ការិយាល័យសហព្រះរាជអាជ្ញាគឺការដាក់ទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៤៥ឆ្នាំដោយគ្មានការដោះលែងមុនកាលកំណត់ឡើយ ។

មេធាវីការពារក្ដីបានបញ្ចេញទស្សនៈខុសពីនេះដោយជំរុញឲ្យអង្គជំនុំជម្រះសាលាកំពូលឲ្យសម្រេចថាអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើកត្តាសម្រាលទោសឲ្យបានគ្រប់គ្រាន់នៅឡើយទេដែលក្នុងនោះរួមមានការសហការ និងការសម្ដែងវិប្បដិសារីរបស់ ឌុច ។ សហមេធាវីការពារក្ដី កង ឫទ្ធារី បាននិយាយយ៉ាងក្បោះក្បាយថា ឌុច ជាបុរសម្នាក់ដែលហ៊ានធ្វើអ្វីៗគ្រប់យ៉ាងដែលខ្លួនអាចធ្វើបានដើម្បីទប់ស្កាត់គ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រព្រឹត្តដែល ឌុច ត្រូវបានបង្ខំឲ្យធ្វើដោយការខ្លាចស្លាប់ ។ លោក ឫទ្ធារី បានជំរុញឲ្យចៅក្រមធ្វើការពិចារណាថា តើចៅក្រមធ្វើយ៉ាងដូចម្ដេចដែលប្រសិនបើជីវិតរបស់ចៅក្រមត្រូវបានខ្មែរក្រហមគំរាមកំហែង ហើយលោកបានឆ្លើយប្រាប់ចៅក្រមទៅវិញថា «អ្នកទាំងអស់គ្នាអាចនឹងអង្គុយនៅកន្លែងដែល ឌុច កំពុងតែអង្គុយថ្ងៃនេះ» ។

មេធាវីការពារក្ដីបានស្នើសុំថាប្រសិនបើអង្គជំនុំជម្រះសាលាកំពូលមិនសម្រេចដោះលែង ឌុច ពីព្រោះអង្គជំនុំជម្រះមិនមានយុត្តាធិការគ្រប់គ្រាន់សម្រាប់កាត់ទោស ឌុច ទេនោះយ៉ាងហោចណាស់ ចៅក្រមសាលាកំពូលគួរតែកាត់បន្ថយទោសឲ្យ ឌុច ត្រឹម១៥ឆ្នាំ ។ បើពិចារណាលើកត្តាសម្រាល ទោសសម្រាប់ការរំលោភផ្លូវច្បាប់ និងរយៈពេលឃុំខ្លួន ឌុច ដោយខុសច្បាប់នោះ ជាសរុបទោសជាប់ពន្ធធានាគាររយៈពេល១៥ឆ្នាំនេះអាចដោះលែង ឌុច ចេញពីមន្ទីរឃុំឃាំងភ្លាមតែម្ដង ។

## តុលាការជាតិ ឬ អន្តរជាតិ?

ការពឹងផ្អែកយ៉ាងខ្លាំងក្លារបស់ព្រះរាជអាជ្ញាលើច្បាប់អន្តរជាតិ និងគោលជំហររបស់មេធាវីការពារក្ដីដែលថាសាលាក្ដីខ្មែរក្រហមគឺជាតុលាការជាតិនោះបានបណ្ដាលឲ្យមានការជជែកដេញដោលគ្នាយ៉ាងគានតឹងនាពេលរសៀលនេះខណៈពេលដែលភាគីទាំងពីរបានជជែកដេញដោលគ្នាថាតើអង្គជំនុំជម្រះសាលាកំពូលគួរតែពិចារណាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នៅពេលដែលចៅក្រមសម្រេចទោសដ៏សមរម្យឲ្យ ឌុច ។ មាត្រា៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ចែងថាប្រសិនបើការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតត្រូវបានសម្រាលទោសដោយសារកត្តាសម្រាលទោសនោះចៅក្រម «អាចនឹងដាក់ទោសជនជាប់ចោទឲ្យជាប់ទោសក្នុងចន្លោះពេលពី១៥ឆ្នាំទៅ៣០ឆ្នាំ» ។ ប៉ុន្តែមាត្រា៦៦៨នៃក្រមព្រហ្មទណ្ឌដដែលនេះក៏ចែងថាក្រមនេះនឹងមិនត្រូវបានយកមកអនុវត្តនោះទេប្រសិនបើក្រមព្រហ្មទណ្ឌនេះ

មានលក្ខណៈចម្រូងចម្រាសជាមួយនឹង «ច្បាប់ព្រហ្មទណ្ឌពិសេស» ផ្សេងទៀត ។

មេធាវីការពារក្តីបានតវ៉ាថាក្នុងសមាសធាតុជាតុលាការជាតិសាលាក្តីខ្មែរក្រហមត្រូវតែគោរពទៅតាមមាត្រា៩៥ ដូច្នេះសាលាក្តីខ្មែរក្រហមគួរតែផ្តន្ទាទោសជនជាប់ចោទខ្ពស់បំផុតគឺរយៈពេល៣០ឆ្នាំដែលអាចប្រឆាំងតវ៉ាបានយោងតាមកត្តាសម្រាលទោសសម្រាប់សំណុំរឿងរបស់ ឌុច ។ មេធាវីការពារក្តីបានអះអាងថា បើទោះបីជាការរៀបរៀងលក្ខន្តិកៈរបស់សាលាក្តីខ្មែរក្រហមត្រូវបានព្រាងមុននឹងសាលាក្តីខ្មែរក្រហមបានកកើតឡើងក៏ដោយការរៀបរៀងលក្ខន្តិកៈនេះតម្រូវឲ្យជនជាប់ចោទទទួលបានប្រយោជន៍ពីច្បាប់ព្រហ្មទណ្ឌដែលត្រូវបានតាក់តែងឡើងក្រោយពីការប្រព្រឹត្តនៃឧក្រិដ្ឋកម្មដដែល ។

ប៉ុន្តែ ព្រះរាជអាជ្ញាបានអះអាងថា ច្បាប់សាលាក្តីខ្មែរក្រហមមានលក្ខណៈស្របទៅនឹង «ច្បាប់ព្រហ្មទណ្ឌពិសេស» ផ្សេងទៀតដូច្នេះសាលាក្តីខ្មែរក្រហមមិនតម្រូវឲ្យគោរពតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ឡើយ ។ ផ្ទុយទៅវិញ សាលាក្តីខ្មែរក្រហមត្រូវតែគោរពតាមមាត្រា៣៩នៃច្បាប់បង្កើតសាលាក្តីខ្មែរក្រហមដែលអនុញ្ញាតឲ្យចៅក្រមពង្រីកសិទ្ធិអំណាចរបស់ខ្លួនដែលអាចដាក់ទោសជនជាប់ចោទក្នុងចន្លោះរយៈពេលពីប្រាំឆ្នាំទៅជាប់ទោសអស់មួយជីវិត ។

ចៅក្រម ក្លូវីកកា មីឡាត បានធ្វើឲ្យអ្នកតាមដានអង្គសវនាការមានភាពច្របូកច្របល់នៅពេលដែលលោកស្រីចៅក្រមបានបដិសេធចោលគោលជំហររបស់ព្រះរាជអាជ្ញាដែលចាត់ទុកសាលាក្តីខ្មែរក្រហមជាតុលាការប្លែកដោយឡែកមួយដែលមិនតម្រូវឲ្យគោរពតាមគោលការណ៍ច្បាប់ក្នុងស្រុក ។ លោកស្រីចៅក្រមក៏បានបង្ហាញពីចម្ងល់របស់លោកស្រីថា តើមាត្រា៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩មានភាពចម្រូងចម្រាសនឹងច្បាប់សាលាក្តីខ្មែរក្រហមមែនដែរឬទេ ដោយបង្ហាញការជឿជាក់របស់លោកស្រីថាមាត្រា៦៦៨នៃច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩មានជាប់ពាក់ព័ន្ធអ្វីឡើយ ។ បន្ទាប់មកទៀត លោកស្រីចៅក្រមបានចោទសួរភាគីព្រះរាជអាជ្ញាថាក្នុងសមាសធាតុជាតុលាការជាតិ ប្រសិនបើតុលាការយកក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ដែលជាច្បាប់កម្ពុជាមកពិចារណានោះតើតុលាការនឹងមិនបម្រើប្រយោជន៍ដល់ប្រជាជនកម្ពុជាយ៉ាងដូចម្តេចខ្លះ ។ ព្រះរាជអាជ្ញាបានគូសបញ្ជាក់ពីគោលជំហររបស់ខ្លួនម្តងទៀតថា តុលាការនេះគឺជាតុលាការប្លែកពីគេ ហើយបើទោះបីជាតុលាការនេះត្រូវបានចាត់ទុកជាតុលាការជាតិក៏ដោយក៏តុលាការនេះនឹងនៅតែឋិតនៅក្រោមអញ្ញត្តកម្មមាត្រា៦៦៨ ដដែល ។ ចៅក្រមក្លូវីកកា មីឡាត ទំនងជាមិនជឿជាក់លើសម្តីរបស់ព្រះរាជអាជ្ញាប៉ុន្មានទេ ។ ជាលទ្ធផល ដោយដឹងពីផលប៉ះពាល់នៃការសួរដេញដោលពីចៅក្រមតុលាការកំពូលលើការដាក់ទោស ឌុច អ្នកតាមដានម្នាក់បាន


ដើមបណ្តឹងរដ្ឋប្បវេណីថតជុំគ្នាក្រោយពេលបណ្តឹងសាទុក្ខរបស់ ឌុច បានបញ្ចប់

ដើរចេញពីបន្ទប់សវនាការទាំងទឹកភ្នែក ។

## ថ្ងៃទី៣០ មីនា : សម្តីចុងក្រោយ

នេះជាថ្ងៃចុងបញ្ចប់នៃបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ (ឌុច) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ។ សាលអង្គសវនាការសាធារណៈពោរពេញទៅដោយអ្នកចូលរួមជាច្រើនដែលនេះបានឆ្លុះបញ្ចាំងពីប្រធានបទដដែលដេញដោលក្នុងឆ្នាំនេះស្តីពីបណ្តឹងឧទ្ធរណ៍របស់មេធាវី

ការពារដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តោតទៅលើបណ្តឹងដែលថា អង្គបុរេជំនុំជម្រះសាលាដំបូងមិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្តល់ការសងថ្លៃខូចខាតឲ្យបានគ្រប់គ្រាន់ដល់ជនរងគ្រោះរបបខ្មែរក្រហម ។ យ៉ាងណាមិញ អ្វីដែលគួរឲ្យចងចាំជាងគេបំផុតនោះនៅក្នុងថ្ងៃនេះគឺការនិយាយចុងក្រោយ របស់ ឌុច ដែលជាការស្នើសុំដ៏ឈ្លាសវៃ និងមានរបៀបដើម្បីសុំដោះលែងខ្លួនដែលបណ្តាលឲ្យសំណុំរឿង០០១មកឡើងដោះស្រាយរឿងក្តីម្តងទៀតនៅថ្ងៃនេះ ។

**បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី**



ថ្ងៃនេះក្រុមដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗមានឱកាសឡើងនិយាយនៅក្នុងអង្គសវនាការនិងលើកបង្ហាញបណ្តឹងឧទ្ធរណ៍របស់ខ្លួនទាក់ទងទៅនឹងការចូលរួម និងសំណងថ្លៃខូចខាតរបស់ជនរងគ្រោះ ។ មាតិកាសំខាន់បីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថាអង្គជំនុំជម្រះសាលាដំបូង ១) យល់ខុសលើវិធានផ្ទៃក្នុងដោយបង្កើតឲ្យមានការពិនិត្យមើលឡើងវិញលើការទទួលយកពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណី ២) មានកំហុសឆ្គងដោយអនុវត្តបទដ្ឋានទទួលយកពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានកម្រិតខ្ពស់ហួសហេតុ និង ៣) អាក់ខានមិនបានផ្តល់សំណងថ្លៃខូចខាតឲ្យបានគ្រប់គ្រាន់ដល់ជន រងគ្រោះ ។

លោក ការីម ខាន់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយបានចាប់ផ្តើមលើអំណះអំណាងរបស់ក្រុមខ្លួន ដោយស្នើសុំឲ្យអង្គជំនុំជម្រះសាលាកំពូលទទួលស្គាល់ផលប៉ះពាល់នៃរោគតានតឹងផ្លូវចិត្តដែលមានមកលើជនរងគ្រោះ ដែលបណ្តាលមកពីការសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានច្រានចោលពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃអានសាលក្រម ។ «បន្ទាប់ពីរងទុក្ខអស់រយៈពេលជាច្រើនខែក្នុងអំឡុងពេលវិនិច្ឆ័យទោស ឌុច បន្ទាប់ពីបានធ្វើអ្វីៗគ្រប់យ៉ាងដែលពួកគេតម្រូវឲ្យធ្វើមកនៅថ្ងៃប្រកាសសាលក្រមជាលើកដំបូងដើមបណ្តឹងរដ្ឋប្បវេណីបែរជាត្រូវបានបដិសេធមិនទទួលស្គាល់ជាឋានៈដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវការទៅវិញ» ។ លោកបានតវ៉ាថា គ្មានវិធានណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលបញ្ជាក់ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តការពិនិត្យមើលឡើងវិញលើលក្ខន្តិកៈធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ។ បទដ្ឋាននេះត្រូវបាន «ប្រឌិតឡើង» ដោយអង្គជំនុំជម្រះសាលាដំបូងតែម្តង ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតបានគាំទ្រអំណះអំណាងនេះ ហើយបានអះអាងថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឲ្យមានការដកហូតសិទ្ធិរបស់កូនក្តីរបស់ខ្លួន ។ ជាក់ស្តែង កូនក្តីទាំងអស់បានពឹងផ្អែកលើការទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងអំឡុងអង្គវិនិច្ឆ័យទោសរបស់ ឌុច នេះ ។ ចៅក្រម ក្លូឌូវីកកា មីឡាត បានសម្តែងភាពអាណិតអាសូរដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូងប៉ុន្តែបានចោទជាចម្ងល់ថាតើការបំពេញទៅតាមការរំពឹងទុករបស់ដើមបណ្តឹងរដ្ឋប្បវេណីជាការទទួលខុសត្រូវរបស់អ្នកណា ។ លោកស្រីចៅក្រមក៏បានគូសបញ្ជាក់ថានីតិវិធីដើមបណ្តឹងរដ្ឋប្បវេណីរបស់ក្រមកម្ពុជាក៏មានបញ្ចូលការពិនិត្យមើលឡើងវិញលើកទីពីរលើពាក្យស្នើសុំធ្វើជាដើមបណ្តឹង

រដ្ឋប្បវេណីដែរដោយធ្វើការគាំទ្រលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

ទាក់ទងនឹងកំហុសឆ្គងផ្លូវច្បាប់វិញ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តភ័ស្តុតាង-ដាក់បន្ទុកដែលមានកម្រិតខ្ពស់ហួសហេតុនៅពេលដែលសម្រេចថាដើមបណ្តឹងរដ្ឋប្បវេណីខ្លះមិនបានបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាខ្លួនជាសាច់ញាតិរបស់អ្នកទោសដែលបានសម្លាប់នៅមន្ទីរស-២១ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងបីក៏បានលើកឡើងពីបញ្ហាទាក់ទងនឹងសំណងថ្លៃខូចខាតរបស់អង្គជំនុំជម្រះសាលាដំបូងដែលនៅមានកម្រិតមិនសមរម្យក្នុងការសម្រេចដាក់បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម និងលើគេហទំព័ររបស់តុលាការ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការស្នើសុំជាច្រើនដូចជា ការសាងសង់បូជនីយដ្ឋាន ការបោះពុម្ពនិងការផ្សព្វផ្សាយការសម្តែងវិប្បដិសារីរបស់ ឌុច និងការផ្តល់ជាសេវាថែទាំសុខភាពសម្រាប់ជនរងគ្រោះដែលកំពុងតែទទួលរងគ្រោះថ្នាក់ផ្នែកសតិអារម្មណ៍ និងរូបរាងកាយ ។

ដោយអាក់អន់ចិត្តចំពោះមូលនិធិដែលតុលាការបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ស៊ីលកេ ស្ទូដហ្ស៊ីនស្គីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានសម្តែងនូវអារម្មណ៍មិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបានឲ្យ ឌុច ផ្តល់សំណងថ្លៃខូចខាតដល់រងជនគ្រោះដោយផ្ទាល់ ។ លោកស្រីបានសួរថាហេតុអ្វីបានជាសាលាក្តីខ្មែរក្រហមសន្មតថា ឌុច មានជីវភាពក្រីក្រដោយលើកឡើងថា ឌុច បានរកកម្រៃពីការលក់ប្រវត្តិរូបរបស់ខ្លួន និងចូលរួមថតខ្សែភាពយន្តរឿង «ពេជ្ឈឃាតចុងក្រោយ» ។

លោកស្រី ស្ទូដហ្ស៊ីនស្គី បានសោកស្តាយដែលថាអង្គសវនាការនេះគឺជាពេលចុងក្រោយបង្អស់ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចបំពេញតួនាទីរបស់ខ្លួនដោយឯករាជ្យ ។ វិធានផ្ទៃក្នុង១២ ស្ទួនដែលទើបតែនឹងបង្កើតឡើងនោះចាត់ឲ្យមានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតែពីររូបប៉ុណ្ណោះ ចាត់តាំងឲ្យមេធាវីទាំងពីររូបនេះ «ធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតនៅក្នុងអង្គសវនាការ និងផ្តល់នូវ «ការទទួលខុសត្រូវខ្ពស់ឲ្យមេធាវីទាំងពីររូបនេះលើការស្វែងរកមតិគាំទ្រភាគច្រើនយុត្តិសាស្ត្រ និងការធ្វើបទបង្ហាញតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងអំឡុងអង្គសវនាការ» ។

## សេចក្តីសន្និដ្ឋានបញ្ចប់របស់ ឌុច

អង្គសវនាការសម្រាប់សំណុំរឿង០០១ទាំងអស់ត្រូវបានបញ្ចប់ដោយការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ពី ឌុច ដែល ឌុច បានព្យាយាមបង្ហាញនូវវិប្បដិសារីសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួន និងស្នើសុំឲ្យមានការដោះលែងឲ្យរួចទោស ។ ឌុច បានចាប់ផ្តើមឡើងដោយសង្កត់ធ្ងន់គោលជំហរចម្បងរបស់ខ្លួនថាសាលាក្តីខ្មែរក្រហមមិនមានយុត្តាធិការផ្នែកបុគ្គលដើម្បីកាត់ទោស ឌុច ទេពីព្រោះ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនោះទេ ។ ឌុច បានប្រឆាំងនឹងការអះអាងរបស់ព្រះរាជអាជ្ញាដែលបានចាត់ទុកមន្ទីរស-២១ជាផ្នែកមួយដ៏សំខាន់របស់គណៈកម្មការអចិន្ត្រៃយ៍ ។ ឌុច បានចាត់ទុកខ្លួនឯងជាកម្មាភិបាលថ្នាក់កណ្តាល ហើយបាននិយាយថា «មន្ទីរស-២១មិនមែនខុសប្លែកគ្នាពីមន្ទីរសន្តិសុខផ្សេងទៀតឡើយ ។ វាគឺមានស្ថានភាពដូចគ្នា និងមន្ទីរសន្តិសុខផ្សេងទៀតដែលមានការអនុវត្តការធ្វើទារុណកម្មលើអ្នកទោស» ។ បន្ទាប់មកទៀត ឌុច បានផ្លាស់ប្តូរមកលើកឡើងពីករណីការប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមការបង្ខិតបង្ខំ ដោយនិយាយថាខ្លួនបានរួចរស់រានមានជីវិតពីរបបខ្មែរក្រហមដោយសារតែខ្លួនបាន «អនុវត្តទៅតាមបញ្ជាថ្នាក់លើយ៉ាងខ្ជាប់ខ្ជួន» ។ ជាមួយគ្នានេះ ឌុច ក៏បានអះអាងថាខ្លួនបានបំពេញតួនាទីជាសាក្សី ដែលសហការ និងដែលមានវិប្បដិសារី ។ នេះគឺជាការអះអាងមួយដែលមិនសមហេតុផលបើយើងពិចារណាពីការប្រានចោលមិនទទួលកំហុស និងការស្នើសុំឲ្យដោះលែងរួចពីទោសដែលធ្វើឡើងដោយឌុច» ។ «ខ្ញុំសូមសម្តែងនូវវិប្បដិសារីចំពោះជនរងគ្រោះ ហើយសូមការលើកលែងទោស...ជាចុងក្រោយខ្ញុំសូមលើកឡើងពីគោលការណ៍របស់ខ្ញុំថា ខ្ញុំមិនមែនជាជនដែលឋិតនៅក្រោមយុត្តាធិការផ្នែកបុគ្គលរបស់តុលាការឡើយ» ។

**ឆាល ឆេកសាន់**

# គេចខ្លួនដើម្បីរស់

យឿន ពិល សព្វថ្ងៃ អាយុ៦៥ឆ្នាំ រស់នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានរៀនត្រឹមថ្នាក់ទីប្រាំពីរនៅសាលាស្វាយចេក ស្ថិតក្នុងស្រុកស្វាយចេក ។ នៅឆ្នាំ១៩៧៥ ក្រុមគ្រួសារ ពិល ត្រូវបានជម្លៀសទៅរស់នៅស្រុកថ្មពួក ស្ថិតក្នុងតំបន់៥ ។ នៅទីនោះ អង្គការក៏បានចាត់តាំងឲ្យ ពិល ទៅលើកទំនប់នៅអាងត្រពាំងថ្មជាមួយប្រជាជនចាស់និងប្រជាជនថ្មីជាច្រើនទៀត ។ នៅទីនោះអង្គការបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំង និងផ្តល់បបរឲ្យហូបមិនគ្រប់គ្រាន់ទើបបណ្តាលឲ្យប្រជាជនមួយចំនួនមានជំងឺហើមដៃ-ជើងនិងស្លាប់ជាបន្តបន្ទាប់ ។

មួយឆ្នាំក្រោយមក ពិល ត្រូវបានអង្គការផ្លាស់មកខាងដឹកជញ្ជូនស្បៀងនៅទំនប់អាងជើងគ្រួស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានសហករណ៍ឈ្មោះ ម៉ូវ ។ នៅទីនោះ អង្គការចាត់តាំង ពិល ឲ្យដឹកស្បៀងតាមរទេះគោពីភូមិយកទៅទុកនៅឃ្លាំងស្ថិតនៅក្នុងស្រុកបន្ទាយឆ្មារ មានចម្ងាយប្រហែល ២០គីឡូម៉ែត្រ ។ ទោះបី ពិល ខិតខំធ្វើយ៉ាងណាក៏ដោយ ក៏គាត់នៅតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនទៀតដែរ ព្រោះប្រជាជនដែលទើបជម្លៀសមកពីភ្នំពេញភាគច្រើនបាត់ខ្លួនជារៀងរាល់ថ្ងៃ ។

ពិល មិនដឹងថាអង្គការយកស្បៀងទាំងនោះទៅណាទេ ។ ដោយសារតែមិនអាចទ្រាំទៅនឹងការងារទាំងនោះបាន ក្រោយមកនៅឆ្នាំ១៩៧៧ ពិល និងមិត្តភក្តិដទៃទៀតក៏បានលួចរត់ចេញពីទីនោះ ដោយមិនឲ្យអង្គការដឹងឡើយ ។ ពិល និងមិត្តភក្តិប្រាំបីនាក់បានដើរកាត់តាមព្រៃទាំងថ្ងៃទាំងយប់រហូតដល់ព្រំដែនថៃ ។ ពិល និងមិត្តភក្តិបានត្រេកអរយ៉ាងខ្លាំង ដោយគិតថាអាចរួចផុតពីការងារធ្ងន់ធ្ងរ និងសង្ឃឹមថានឹងមានអាហារហូបប្រសើរជាងមុន ។ ប៉ុន្តែ សំណាងអាក្រក់ ពិល និងមិត្តភក្តិទាំងប្រាំបីនាក់ត្រូវទាហានថៃចាប់យកទៅដាក់គុកមួយរយៈទើបដោះលែងវិញ ។

នៅពេលដែលកងទ័ពវៀតណាមបានចូលរំដោះនៅឆ្នាំ១៩៧៩ ប្រជាជនមួយចំនួនបានត្រឡប់ទៅរស់នៅស្រុកកំណើតរៀងៗខ្លួនវិញ ។ ប៉ុន្តែ ពិល បានសម្រេចចិត្តចូលធ្វើជាទាហានប៉ាវ៉ា ក្រោមការដឹកនាំរបស់ សឺន សាន ។

ក្រោយមក ពិល ត្រូវបានតំឡើងតួនាទីជាវរសេនីយ៍ត្រី ដឹកនាំកងទ័ពចំនួនបីរយនាក់វាយប្រយុទ្ធជាមួយទាហានវៀតណាមនៅស្រុកស្វាយចេក ។ នៅពេលវាយប្រយុទ្ធក្នុងសមរភូមិ កងទ័ពរបស់ ពិល បានស្លាប់ និងរងរបួសជាច្រើននាក់ ។

នៅឆ្នាំ១៩៩៣ ពិល និងគ្រួសារ បានទៅរស់នៅក្នុងជំរំសាយធូ ដែលជំរំមានប្រជាជន ប្រមាណ១០គ្រួសារប៉ុណ្ណោះ ក្រោមការជួយឧបត្ថម្ភពីអង្គការរបស់បារាំង ក្នុងមួយគ្រួសារបួនពាន់បាត ។ នៅទីនោះបានមួយរយៈ ពិល បានសម្រេចចិត្តវិលត្រឡប់មករស់នៅក្នុងភូមិកំណើតវិញឡើយ ប្រកបមុខរបរធ្វើស្រែចម្ការរហូតដល់ពេលបច្ចុប្បន្ននេះ ។

**ស៊ិន សុធីតា**

## អានទស្សនាវដ្តីតាមគេហទំព័រ

*ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។*

**សូមអរគុណ!**

# ជីវិតម្ដាយខ្ញុំក្នុងរបបខ្មែរក្រហម

ម្ដាយខ្ញុំឈ្មោះ លាង ខេង ។ គាត់កើតនៅភូមិព្រែកកុយ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧០ ម្ដាយខ្ញុំមានអាយុ១៣ឆ្នាំប៉ុណ្ណោះ ។ នៅពេលនោះ ម្ដាយខ្ញុំមិនដែលមានពេលសប្បាយរីករាយទេ ព្រោះយន្តហោះអាមេរិកបានហោះមកទម្លាក់គ្រាប់បែកមកលើផ្ទះប្រជាជន និងភូមិកំណើតគាត់ជាញឹកញាប់ ។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧០ ជាថ្ងៃពិធីបុណ្យចូលឆ្នាំខ្មែរ ស្រាប់តែឮសំឡេងយន្តហោះនៅពីលើភូមិ ម្ដាយខ្ញុំ យាយ តា ព្រមទាំងបងប្អូនទាំងអស់របស់គាត់ទាំងអស់បាននាំគ្នារត់ចូលទៅក្នុងលេណដ្ឋានដើម្បីលាក់ខ្លួន ។

រយៈពេលមួយម៉ោង បន្ទាប់ពីសំឡេងយន្តហោះបានស្ងប់ស្ងាត់ ម្ដាយខ្ញុំបានចេញមកក្រៅវិញ ស្រាប់តែឃើញគំនរភ្លើង និងផ្សែងគ្រាប់ហុយពេញភូមិ ។ ពេលនោះ ផ្ទះប្រជាជនទាំងអស់នៅក្នុងភូមិត្រូវគ្រាប់បែកបំផ្លាញខ្ទេចខ្ទី ហើយផ្ទះរបស់ម្ដាយខ្ញុំក៏ឆេះគ្មានសល់ឡើយ ប៉ុន្តែសំណាងល្អការទម្លាក់គ្រាប់បែកនេះមិនបានបណ្ដាលឲ្យសមាជិកគ្រួសាររបស់គាត់បាត់បង់ជីវិត ឬទទួលរងគ្រោះថ្នាក់ទេ ។ យាយ តា បានសម្រេចចិត្តនាំម្ដាយខ្ញុំព្រមទាំងកូនៗរបស់គាត់ទៅរស់នៅភ្នំដិលវិញ ព្រោះខ្លាចយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកម្ដងទៀត ។

នៅទីនោះ ម្ដាយខ្ញុំចូលរៀនអក្សរនៅសាលារៀនភ្នំដិលបានត្រឹមថ្នាក់ទី៩ចាស់ ។ រហូតដល់ឆ្នាំ ១៩៧៣ នៅពេលកងទ័ពខ្មែរក្រហមបានចូលមកកាន់កាប់នៅតំបន់នោះ គាត់ក៏ផ្លាស់មករស់នៅភូមិព្រែកដំបងវិញ ។ មួយរយៈក្រោយមក ក្រុមគ្រួសាររបស់ម្ដាយខ្ញុំបានត្រឡប់ទៅរស់នៅស្រុកកំណើតនៅភូមិព្រែកកុយ ស្រុកកងមាស ។ ទៅដល់ដំបូង ភូមិរបស់ម្ដាយខ្ញុំធ្លាប់រស់នៅត្រូវដើមឈើ និងវល្លិ៍ដុះព័ទ្ធជុំជិត ជីតាខ្ញុំបានកាប់ឆ្ការនិងដើរកាប់ដើមឈើ ស្លឹកត្នោត និងស្លឹកដូងដើម្បីសង់ខ្ទមរស់នៅ ។ នៅពេលនោះ ពុំទាន់មានប្រជាជនទៅរស់នៅទេ ព្រោះកន្លែងនោះស្ទុះសឹងជាព្រៃស្ងាត់ជ្រងំ ក្រោយមកទើបមានគ្រួសារដែលពីមុនភៀសទៅនៅបឹងបានត្រឡប់មករស់នៅក្នុងភូមិនេះវិញជាបន្តបន្ទាប់ ។

រហូតដល់ឆ្នាំ១៩៧៤ ប្រជាជនក្នុងភូមិបានបង្កើតជាក្រុមធ្វើស្រែចម្ការប្រវាស់ដៃ ហើយម្ដាយខ្ញុំក៏បានចូលក្នុងក្រុមនេះដែរ ប៉ុន្តែរយៈពេលពីរបីខែក្រោយមក គាត់បានទទួលដំណឹងថាកងទ័ពខ្មែរក្រហមរំដោះបានភ្នំពេញហើយ ។ ម្ដាយខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ព្រោះគាត់សង្ឃឹមថានឹងបានទៅលេងបងស្រី បងថ្លៃ និងក្មួយៗ ដែលបានរស់នៅខេត្តបាត់ដំបងតាំងពីឆ្នាំ១៩៧០ ម្ល៉េះ ។ ប៉ុន្តែក្ដីស្រមៃរបស់ម្ដាយខ្ញុំបានបាត់ទៅវិញ ព្រោះខ្មែរក្រហមបានប្រមូលប្រជាជនឲ្យទៅធ្វើស្រែចម្ការវិញ ។ ក្រោយមក ខ្មែរក្រហមបានប្រកាសរកអ្នកណាដែលមានចំណេះដឹង និងធ្លាប់ធ្វើការធំៗនៅក្នុងរបបចាស់ មកជួយធ្វើការងារអង្គការវិញ ។ ពេលមាននោះ អ្នកខ្លះដែលជឿការឃោសនានេះក៏បានប្រាប់អំពីប្រវត្តិរូបពិតរបស់ខ្លួន ក្រោយមកអ្នកទាំងនោះត្រូវ



រូបថតក្រុមគ្រួសាររបស់ ជ័យទត្ត

ខ្មែរក្រហមយកទៅសម្លាប់ចោលអស់ ។ ចំណែក អ្នកដែលមានប្រវត្តិមិនជាប់ពាក់ព័ន្ធនឹងរបបចាស់ត្រូវបានបញ្ជូនឲ្យទៅរស់នៅតាមស្រុកកំណើតរៀងៗខ្លួនវិញ ។

នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមប្រមូលប្រជាជនឲ្យចូលកងចល័ត ហើយម្តាយខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការឆ្ងាយពីផ្ទះ យាយតា និងបងប្អូនគាត់ ។ នៅទីនោះ ម្តាយខ្ញុំត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការរហូតស្ទើតែគ្មានពេលសម្រាក រីឯអាហារប្រចាំថ្ងៃមានតែទឹកបបររាវៗប៉ុណ្ណោះ ។ ថ្ងៃមួយ ម្តាយខ្ញុំធ្វើការរហូតដល់អស់កម្លាំងដួលនៅការដ្ឋាន ។ ក្រោយមកនៅឆ្នាំ១៩៧៦ ម្តាយខ្ញុំចាប់ផ្តើមឈឺកខាងឆ្វេង និងកើតពិសខ្ទុះ បណ្តាលឲ្យគាត់អន្ទុយយំរាល់ថ្ងៃ ។ ឃើញដូច្នេះ ពេទ្យខ្មែរក្រហមបានយកឡាមមកវះលើពិសខ្ទុះរបស់ម្តាយខ្ញុំដែលមិនទាន់ធ្លាយ ដោយមិនមានការចាក់ថ្នាំស្ពឹក ធ្វើឲ្យគាត់ឈឺចាប់រហូតសន្លប់បាត់ស្មារតី ។

ក្រោយមកអង្គការ បានផ្លាស់ម្តាយខ្ញុំឲ្យទៅធ្វើការនៅរោងកងមើលថែទាំដំណាំ ទោះបីដឹងថាគាត់មិនទាន់ទាំងជាសះមុខរបួសក៏ដោយ ។ នៅទីនោះ ប្រធានកងបានចាត់តាំងម្តាយខ្ញុំដេញមាន់ ទា កុំឲ្យចូលរងដាំស្លឹកខ្ទឹម ។ ថ្ងៃមួយ ម្តាយខ្ញុំបានចេញទៅយកទឹកមកដាំថ្នាំដឹក ស្រាប់តែ មាន់ ទា ចូលទៅកាយដើមស្លឹកខ្ទឹមដាច់អស់បួនគុម្ព ។ ខណៈនោះ ម្តាយខ្ញុំបានប្រញាប់ប្រញាល់ទៅរើសដើមស្លឹកខ្ទឹមទាំងអស់នោះដាក់ក្នុងកាម៉ែលបាយ ស្រាប់តែកងឈ្លបខ្មែរក្រហមឃើញ រួចហើយចោទម្តាយខ្ញុំថា លួចដកដើមខ្ទឹម ។ ប្រធានកងបានដាក់ពិន័យម្តាយខ្ញុំឲ្យធ្វើដីលេខមួយ (ដីលាមកមនុស្ស) ដោយក្នុងមួយថ្ងៃត្រូវធ្វើឲ្យបានមួយរយគីឡូ ។ ម្តាយខ្ញុំត្រូវខិតខំប្រឹងធ្វើការងាររហូតគ្រប់ផែនការរបស់អង្គការ ។ បន្ទាប់មក អង្គការបានចាត់តាំងម្តាយខ្ញុំឲ្យដកសំណាបឲ្យបានបីផ្លូនក្នុងមួយថ្ងៃ ។

នៅខែមិថុនា ឆ្នាំ១៩៧៦ អង្គការបានផ្លាស់កងចល័តរបស់ម្តាយខ្ញុំឲ្យទៅនៅធ្វើការនៅឯឃុំខ្ចៅ ក្នុងស្រុកកងមាសវិញ ។ រៀងរាល់ថ្ងៃ វេលាម៉ោងបីទៀបភ្លឺ ប្រធានកងផ្តើមវាយជួងប្រមូលកងចល័តទាំងអស់មកទទួលរបបអាហារ និងចេញទៅធ្វើការងារ ។ ពេលនោះ ម្តាយខ្ញុំត្រូវទៅស្ទូងនៅក្នុងភូមិរាយប៉ាយ ដោយគាត់ត្រូវដើរឆ្លងកាត់បឹងចម្ងាយជាង១០គីឡូម៉ែត្រពីកន្លែងស្នាក់ទៅការដ្ឋាន ។ មានថ្ងៃមួយ ពេលមេឃងងឹតខ្លាំង ម្តាយខ្ញុំបានរអិលដួលធ្លាក់ចូលក្នុងប្រឡាយ ធ្វើឲ្យគាត់ខ្វាយបបរអស់ ។ ម្តាយខ្ញុំធ្វើការដោយអត់អាហារចាប់តាំងពីព្រឹកព្រលឹមរហូតដល់យប់ ប៉ុន្តែដោយសារគាត់ឃ្លានខ្លាំងពេកគាត់បានទៅលួចបេះស្លឹកដំឡូងឈើយកមកស្ងោរជាមួយនឹងអំបិលហូប ។

នៅដើមឆ្នាំ១៩៧៧ អង្គការចាត់តាំងមិត្ត កាន ជាគណៈស្រុកកងមាស មកប្រជុំនៅក្នុងឃុំខ្ចៅ ហើយហៅកងចល័តឲ្យចូលរួម ។ បន្ទាប់ពីប្រជុំបានរយៈពេលបីថ្ងៃ អង្គការចាប់ផ្តើមប្រមូលប្រជាជនថ្មីទាំងអស់ទៅសម្លាប់ចោលជាបន្តបន្ទាប់ ។ ថ្ងៃមួយ នៅពេលម្តាយខ្ញុំកំពុងជីកប្រឡាយជាមួយបុរសម្នាក់ បុរសនោះក៏និយាយត្អូញត្អែរប្រាប់ម្តាយខ្ញុំថា គាត់មិនសង្ឃឹមរស់បានជួបមុខក្រុមគ្រួសារទេ ព្រោះឈ្លបបានតាមដានរូបគាត់ជារៀងរាល់ថ្ងៃ ។ មួយថ្ងៃក្រោយមក នៅវេលាយប់ ឈ្លបបានមកចាប់បុរសនេះទៅបាត់ ។

នៅឆ្នាំ១៩៧៧ ដដែល ម្តាយខ្ញុំបានធ្វើការងារទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ព្រោះអង្គការត្រូវការកម្លាំងធ្វើការឲ្យហើយទាន់ផែនការ ។ អង្គការបានបញ្ជាឲ្យម្តាយខ្ញុំធ្វើការមួយថ្ងៃបីពេល ប៉ុន្តែគាត់ទទួលបានមកវិញត្រឹមទឹកបបររាវពីរបីវែកប៉ុណ្ណោះ ។ ពេលរដូវប្រាំងមកដល់ អង្គការតម្រូវបោកស្រូវនៅពេលយប់ ហើយរដូវទឹកឡើងនៅពេលយប់ អង្គការបានតម្រូវឲ្យកាប់ដី លើកទំនប់ ដើម្បីផ្ទុកទឹកធ្វើស្រែទៀត ។ ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏ម្តាយខ្ញុំបានប្តេជ្ញាថែរក្សាជីវិតបន្តទៅទៀតដែរ ដោយរៀងរាល់ថ្ងៃគាត់ខិតខំប្រឹងប្រែងធ្វើការគ្មានពេលឈប់ ព្រោះគាត់ខ្លាចអង្គការតាមដាន ។

រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ម្តាយខ្ញុំបានផ្លាស់មកជីកទំនប់១៧មេសា ស្ថិតនៅភូមិកំពង់សៀម ស្រុកជើងព្រៃវិញ ។ រាល់ថ្ងៃ ប្រធានកងបានបែងចែកជាក្រុមដោយមួយក្រុមមានមនុស្សបីនាក់ដើម្បីវែកដី និងកំណត់មនុស្សមួយនាក់ត្រូវជីកឲ្យបានបីម៉ែត្រគូប ។ ពេលនោះ ម្តាយខ្ញុំបានធ្វើការរហូតដួលដោយសារគាត់មានជំងឺគ្រុនក្តៅ ហើយគាត់ត្រូវបានពេទ្យសែងយកទៅដាក់ក្នុងរោងដើម្បីព្យាបាលដោយឲ្យគាត់ផឹកថ្នាំ (ថ្នាំគ្រាប់ខ្មៅៗ) និងចាក់ថ្នាំ (ថ្នាំទឹករក្សាទុកក្នុងដបទឹកក្រូច) ។ ប៉ុន្តែ

សំណាងល្អម្តាយខ្ញុំបានដឹងខ្លួនវិញ ហើយគាត់បានទៅបេះស្លឹកស្តៅមកប្រូបាច់ដឹកបន្ថែមទៀត ដើម្បីឲ្យត្រជាក់ខ្លួន និងទៅរែកដីបន្តទៀត ។ ម្តាយខ្ញុំបានធ្វើការនៅការដ្ឋាន ១៧ មេសា រយៈពេលប្រាំបីខែ រហូតទំនប់នោះធ្វើហើយរួចរាល់ ។ បន្ទាប់មកអង្គការបានបញ្ជាម្តាយខ្ញុំ និងកងចល័តនៅមើលថែរក្សាទំនប់នោះរហូតដល់រដូវទឹកឡើង ។

នៅរៀងរាល់ពេលយប់ មានសត្វពស់ជាច្រើនបានវារឡើងលើដំបូលរោងរបស់ម្តាយខ្ញុំដេក ធ្វើឲ្យគាត់ភិតភ័យយ៉ាងខ្លាំង ប៉ុន្តែគាត់មិនដែលហ៊ាននិយាយតវ៉ានឹងអង្គការឡើយ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល ។ នៅទីនោះ ម្តាយខ្ញុំនិងកងចល័តទទួលបានរបបបបរ និងទឹកប្រហុកស្ងោរម្នាក់មួយស្លាបព្រាប៉ុណ្ណោះ ។ រយៈពេលបីឆ្នាំចាប់តាំងពីម្តាយខ្ញុំចេញទៅធ្វើការនៅក្នុងកងចល័ត គាត់មិនដែលទទួលដំណឹងពីក្រុមគ្រួសារឡើយ ។

នៅចុងឆ្នាំ១៩៧៨ មានកងចល័តតំបន់មកពីខេត្តកំពង់ចាម បានមកដល់ការដ្ឋានដែលម្តាយខ្ញុំរស់នៅ ហើយបានប្រាប់ថា មានកងទ័ពរណសិរ្សគេចូលរំដោះដាយដែននៅស្រុកមេមត់ និងចម្ការកៅស៊ូហើយ ។ ពេលទទួលដំណឹងនេះភ្លាមម្តាយខ្ញុំត្រេកអរយ៉ាងខ្លាំង ព្រោះគាត់នឹងបានត្រឡប់ទៅជួបឪពុកម្តាយ និងបងប្អូន ។ ម្តាយខ្ញុំបានបួងសួងទេវតា និងវត្ថុស័ក្តិសិទ្ធិឲ្យបងប្អូនគាត់បានជួបជុំគ្នាឡើងវិញ ។ នៅវេលាយប់មួយម្តាយខ្ញុំបានសុបិន្តឃើញមានសំពៅហោះលើដំបូលរោងរបស់គាត់ និងមានមនុស្សស្រែកប្រាប់ថា បងប្អូនកូនចៅស្រុកយើងបានសុខហើយ ធ្វើឲ្យម្តាយខ្ញុំភ្ញាក់ដឹងខ្លួនទាំងសប្បាយរីករាយ ។ ស្រាប់តែល្ងាចថ្ងៃនោះ មេកងបានប្រកាសប្រាប់កងចល័តទាំងអស់ឲ្យរៀបចំសម្ភារ ខោអាវ ដើម្បីផ្លាស់ទៅទីតាំងថ្មី ធ្វើឲ្យម្តាយខ្ញុំមានការភិតភ័យឡើងវិញព្រោះមិនដឹងទៅទីណាច្បាស់លាស់ ។

ព្រឹកឡើងប្រធានកង បានបញ្ជាឲ្យកងចល័តធ្វើដំណើរទៅតាមផ្លូវជាតិលេខ៦ សំដៅឆ្ពោះទៅខេត្តកំពង់ធំ និងបន្តទៅព្រំដែនថៃ ។ ប៉ុន្តែពេលនោះ ម្តាយខ្ញុំ និងមិត្តភក្តិគាត់ប្រមាណ១០នាក់បានចូលទៅលាក់ខ្លួននៅផ្ទះរបស់បងប្អូនគាត់នៅឯភូមិស្តើងជ័យ ស្រុកជើងព្រៃរយៈពេលមួយយប់ ។ មួយថ្ងៃក្រោយមក ឡានរថក្រោះរបស់កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមជាច្រើនបានបើកមកដល់ស្គន់ និងបានប្រកាសឲ្យប្រជាជនត្រឡប់ទៅជួបជុំឪពុកម្តាយបងប្អូននៅស្រុកកំណើតវិញ ។

ដំណឹងនេះ បានធ្វើឲ្យម្តាយខ្ញុំសប្បាយយ៉ាងខ្លាំង ហើយគាត់បានដើរអស់រយៈពេលពីរថ្ងៃទើបមកដល់ស្រុកកំណើតវិញ ។ ម្តាយខ្ញុំបានឃើញសាកសពជាច្រើននៅតាមផ្លូវ ហើយពេលគាត់មកដល់មាត់បឹងមួយស្រាប់តែវង្វេងផ្លូវ ភ្លាមនោះម្តាយខ្ញុំក្រឡេកឃើញទូកអ្នករាយមង គាត់ក៏យកជិះឆ្លងទៅត្រើយម្ខាង ។ សំណាងល្អ ម្តាយខ្ញុំបានជួបយាយតាពីរនាក់ដែលបានប្រាប់ផ្លូវគាត់ ។ ម្តាយខ្ញុំអុំទូករយៈពេលមួយថ្ងៃទើបបានមកដល់ស្រុកកំណើត ។ ម្តាយខ្ញុំបានជួបយាយមុនគេ ពេលនោះដោយសារយាយខ្ញុំរន្ធត់ចិត្តខ្លាំងពេក គាត់បានស្រែកយំរួចស្ទុះមកឱបម្តាយខ្ញុំ និងសួរម្តាយខ្ញុំថា ចុះប្អូនប្រុសកូនម្តេចមិនឃើញមកជាមួយ ម្តាយខ្ញុំឆ្លើយតបទាំងអស់សង្ឃឹមវិញថា គាត់ធ្វើការនៅកន្លែងផ្សេងពីគ្នា គាត់មិនមានដំណឹងពីប្អូនទេ ។ រយៈពេលបីថ្ងៃក្រោយមក ទើបឃើញពូខ្ញុំត្រឡប់មកផ្ទះដែរ ។ ចំណែកបងស្រីពីរនាក់ទៀតដែលទៅរស់នៅខេត្តបាត់ដំបងបានបាត់ដំណឹង ។

រយៈពេលកន្លះខែក្រោយមក អ្នកភូមិដែលត្រឡប់មកពីខេត្តបាត់ដំបង បានមកប្រាប់យាយតាខ្ញុំថា កូនស្រីគាត់ទាំងពីរនាក់បានស្លាប់អស់ហើយ ។ ពេលឮដំណឹងនេះភ្លាម យាយតាខ្ញុំយំរហូតបាត់ស្មារតី ចំណែកម្តាយខ្ញុំអាណិតបងប្អូនគាត់ខ្លាំងណាស់ដែរ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ ម្តាយខ្ញុំបានជួបនឹងបងស្រីធំ និងបងប្រុសរបស់គាត់ពីរនាក់វិញ ។

រហូតមកដល់សព្វថ្ងៃនេះ ម្តាយខ្ញុំនៅតែមិនអាចបំភ្លេចបាននូវរឿងរ៉ាវឈឺចាប់ ភាពខ្លោចផ្សា ការបែកបាក់បងប្អូនជាទីស្រឡាញ់របស់គាត់បាន ។ របបខ្មែរក្រហមបានឆក់យកជីវិតបងប្អូនរបស់ម្តាយខ្ញុំដែលមិនបានប្រព្រឹត្តកំហុសអ្វីទាំងអស់តែក្នុងមួយរយៈខ្លីប៉ុណ្ណោះ ។ រយៈពេលជាង៤០ឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែរាល់ពេលរំឭកពីអតីតកាលដែលដក់ជាប់នៅក្នុងអារម្មណ៍ឡើងវិញ ម្តាយរបស់ខ្ញុំតែងតែបង្ហូរទឹកភ្នែក ។ ម្តាយខ្ញុំនៅតែចាំពាក្យរបស់យាយខ្ញុំប្រាប់គាត់ថា ជីវិតគាត់ពិតជាមានសំណាងជាងប្អូនគាត់ដែលបានបាត់បង់ទៅ ហើយម្តាយខ្ញុំតែងតែយកពាក្យនេះ និងរឿងរ៉ាវរបស់គាត់ប្រាប់បងប្អូនខ្ញុំ ។ **លឹម ជ័យធត្ត**

# ការបែកបាក់ក្នុងរបបខ្មែរក្រហម

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាន់ ស៊ីថា ទើបតែមានអាយុ៩ឆ្នាំប៉ុណ្ណោះ ។ ស៊ីថា ត្រូវអង្គការចាត់តាំងឲ្យចូលកងកុមារនៅភូមិព្រៃស្វាយ ។ ស៊ីថា មិនបានចងចាំអ្វីច្រើនទេក្រៅពីឪពុកឈ្មោះ ចាន់ ថុក ជាកម្មាភិបាលខ្មែរក្រហម និងជាពេទ្យស្រុកមោងឫស្សី ខេត្តបាត់ដំបងដែលតែងតែយកចិត្តទុកដាក់ព្យាបាល និងជួយសង្គ្រោះជីវិតអ្នកជំងឺ និងជីវិតដែលគាត់រស់នៅក្នុងពេលនោះ ។ ប៉ុន្តែ អ្វីដែលធ្វើឲ្យ ស៊ីថា បំភ្លេចមិនបាន ហើយចងចាំមកដល់បច្ចុប្បន្ន គឺគាត់រត់ភៀសខ្លួនទៅទិសខាងលិចតាមបណ្តោយព្រំដែនខ្មែរ-ថៃ ។ ស៊ីថា បានរៀបរាប់ថា ៖

នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ខេត្តបាត់ដំបង ខ្ញុំបានឮពាក្យចចាមអារាមថា ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងសម្លាប់ចោលជាមិនខាន ។ ពេលនោះ ដោយសារតែខ្ញុំមានការភ័យខ្លាចខ្លាំង ខ្ញុំបានបីប្អូនប្រុសអាយុប្រាំបីខែ និងប្អូនប្រុស២នាក់ទៀត រត់ភៀសខ្លួនទៅតាមពូ សារុន មានតួនាទីជាគណៈស្រុកដែលធ្វើការជាមួយឪពុកខ្ញុំ ។ យើងទាំងអស់គ្នាធ្វើដំណើរ ដោយមានដរីមួយក្បាលជាអ្នកដឹកនាំផ្លូវចូលក្នុងព្រៃ ។

ពេលធ្វើដំណើរក្នុងព្រៃជ្រៅ ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះខ្ញុំត្រូវមើលថែទាំប្អូនតូចៗទាំងបីនាក់ និងត្រូវដើរឲ្យទាន់មនុស្សចាស់ឡើងភ្នំទៀត ។ ពេលធ្វើដំណើរ ប្អូនតូចអាយុ៨ខែចេះតែស្រែកយំតាមផ្លូវជានិច្ច រហូតធ្វើឲ្យកម្មាភិបាលផ្សេងទៀតចង់យកវាទៅសម្លាប់ចោលជាញឹកញាប់ ។ ប៉ុន្តែជាសំណាងល្អមាននារីពេទ្យម្នាក់ (មិនស្គាល់ឈ្មោះ) ដែលធ្លាប់ធ្វើការជាមួយឪពុកខ្ញុំជួយនិយាយលួងលោមថា «ឪពុកក្មេងនេះចិត្តល្អណាស់ សូមទុកជីវិតឲ្យក្មេងនេះផង» ទើបធ្វើឲ្យអ្នកទាំងនោះអាណិតខ្ញុំ និងបងប្អូនខ្ញុំ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្អូនប្រុសតូចរបស់ខ្ញុំបានត្រឹមតែបន្តក់ទឹកបន្តិចៗ ចូលក្នុងពោះ និងចេះតែរាគមិនឈប់សោះ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំពរប្អូនខ្ញុំរហូត ទោះជាខ្លួនខ្ញុំមានក្លិនស្អុយដោយសារតែលាមកប្អូនក៏ដោយ ។

ខ្ញុំត្រូវដើរកាត់ព្រៃភ្នំនិងឆ្លងទឹកអូរជ្រោះទៅតាមការដឹកនាំរបស់ពូ សារុន ។ ខ្ញុំហេវហត់ខ្លាំងណាស់ ព្រោះត្រូវមើលថែទាំប្អូនៗ និងដើរផ្លូវឆ្ងាយទៀត ។ ពេលយប់មួយ ដោយសារតែខ្ញុំអស់កម្លាំងខ្លាំង ខ្ញុំដេកឱបប្អូនដោយមិនដឹងខ្លួន ។ លុះដល់មានមនុស្សដើរកាត់ ទើបខ្ញុំភ្ញាក់ដឹងខ្លួន និងចាប់ផ្តើមភិតភ័យព្រោះខ្ញុំដេកនៅក្បែរជម្រាលភ្នំ ។ នៅរដូវវស្សាថ្ងៃមួយ មានភ្លៀងធ្លាក់យ៉ាងខ្លាំង ប្អូនខ្ញុំម្នាក់បានស្លាប់ ។ ខ្ញុំបានបីសពប្អូន រួចនាំប្អូនប្រុសពីរនាក់ទៀតចុះពីលើភ្នំ ដោយមានពូ ឡោម ជូនខ្ញុំត្រឡប់ទៅស្រុកកំណើតវិញ ។

ពេលទៅដល់វាលធំមួយ ខ្ញុំបានកប់សពប្អូនខ្ញុំនៅទីនោះ រួចបន្តដំណើរចុះពីលើភ្នំរហូតដល់ភូមិឫស្សីក្រាំង ។ នៅទីនោះ អ្នកស្រុកបានផ្តល់បាយឲ្យខ្ញុំហូប ពេលនោះខ្ញុំហូបបានច្រើនណាស់ ទោះជាមិនមានម្ហូបក៏ដោយ ។ បន្ទាប់ពីខ្ញុំសម្រាកនៅទីនោះបានបីថ្ងៃ ខ្ញុំនិងប្អូនប្រុស២នាក់ទៀតបានបន្តដំណើរទៅរកស្រុកកំណើតទៀត ។ ពេលខ្ញុំដើរមកដល់ថ្នល់ជាតិ ខ្ញុំបានជួបពូម្នាក់សួរខ្ញុំថាទៅណា? ខ្ញុំបានប្រាប់ថា ខ្ញុំទៅផ្ទះ ពូនោះក៏ឃាត់ឲ្យខ្ញុំនៅស្នាក់ផ្ទះគាត់មួយយប់ ដោយសន្យាថានឹងជូនខ្ញុំទៅរកម្តាយ ។ តាមការពិតពូម្នាក់នោះឈ្មោះ ម៉ៅ ត្រូវជាប្អូនម្តាយខ្ញុំ ។

ថ្ងៃបន្ទាប់ ពូម៉ៅ បានជូនខ្ញុំ និងប្អូនប្រុសពីរនាក់ទៅជួបម្តាយ ។ ម្តាយខ្ញុំស្រក់ទឹកភ្នែកពេលឃើញខ្ញុំដំបូង ហើយគាត់បានសួររកប្អូនប្រុសខ្ញុំ ។ ខ្ញុំមានអារម្មណ៍ក្តុកក្តួល និងអាណិតម្តាយខ្លាំងណាស់ ព្រោះគាត់បានបាត់បង់កូន ចំណែកឪពុកក៏មិនឃើញត្រឡប់មកផ្ទះវិញដែរ ។

ដោយសារតែមានជីវភាពក្រីក្រខ្លាំងពេក ម្តាយខ្ញុំ និង-បងប្អូនខ្ញុំទាំងអស់បាននាំគ្នារត់ទៅរស់នៅតាមជាយព្រំដែនខ្មែរ-ថៃ ដែលនៅទីនោះមានអាហារហូប មានកន្លែងស្នាក់នៅ និងអាចមានឱកាសទៅបរទេសទៀត ។ ខ្ញុំបានទៅរស់នៅជំរំ ស្ថិតនៅខាងជើងប៉ោយប៉ែត ។ ក្រោយមកដោយសារតែមានការប្រយុទ្ធគ្នាញឹកញាប់រវាងកងទ័ពខ្មែរក្រហម និងទាហានប៉ារ៉ា អង្គការជួយជន

ក្បៀសខ្លួន បានបញ្ជូនគ្រួសារខ្ញុំទៅនៅជំរំខាវអ៊ីដាងវិញ ។ នៅទីនោះ ម្ដាយខ្ញុំបានពឹងពាក់អ្នកធានាម្នាក់ឲ្យជួយរៀបចំឯកសារសម្រាប់រត់ទៅរស់នៅប្រទេសទីបី ។ ប៉ុន្ដែ ក្រោយមក អ្នកធានានោះចាប់ពង្រត់នារីម្នាក់នៅក្នុងជំរំខាវអ៊ីដាងនេះ ធ្វើឲ្យគ្រួសារខ្ញុំមិនអាចទៅប្រទេសទីបីបាន ។ ម្ដាយខ្ញុំបានសម្រេចចិត្តទៅនៅជំរំមួយផ្សេងទៀតដើម្បីបានទៅរស់នៅប្រទេសទីបីបន្តទៀត ។

ខ្ញុំបានមករស់នៅជំរំចម្ការគ នៅចុងឆ្នាំ១៩៨១ ។ ក្រោយមក ម្ដាយខ្ញុំបានធ្វើដំណើរតាមព្រះសង្ឃមួយអង្គមករស់នៅតំបន់ម៉ាឡៃ ។ ដំបូង ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជានារីជញ្ជូនគ្រាប់យកទៅសមរភូមិ ចំណែកក្មេងប្រុសជំទង់ៗបញ្ជូនឲ្យទៅធ្វើការកងទ័ព ។ ឃើញដូច្នេះ ម្ដាយខ្ញុំក៏នាំប្អូនប្រុសខ្ញុំទៅលាក់ខ្លួននៅក្នុងអូរជ្រៅជាយដែនខ្មែរ-ថៃ ដើម្បីគេចពីការចាត់តាំងនេះ ។ ពេលនោះ ដោយស្ថានភាពរស់នៅជួបការលំបាកខ្លាំងពេក ខ្ញុំក៏សម្រេចចិត្តរៀបការប្ដីនៅទីនោះ ។

នៅឆ្នាំ១៩៨៥ កងទ័ពវៀតណាមបានវាយសម្រុកចូលមកតំបន់ម៉ាឡៃ គ្រួសារខ្ញុំរត់ភៀសខ្លួនទៅនៅជំរំតាង៉ុក ប្រទេសថៃម្ដងទៀត ។ រហូតឆ្នាំ១៩៩៣ គ្រួសារខ្ញុំបានត្រឡប់មករស់នៅតំបន់ម៉ាឡៃវិញ និងបានចាប់ផ្ដើមប្រកបរបររកស៊ី ទោះជាតំបន់នោះសំបូរមីនក៏ដោយ ។ នៅឆ្នាំ១៩៩៤ អ្នកគ្រប់គ្រងនៅតំបន់ម៉ាឡៃមានផែនការប្រមូលទ្រព្យសម្បត្តិឯកជន ដាក់ជារបស់សមូហភាព ហើយប្រសិនបើចង់ទិញម្ហូបអាហារ ឬសម្ភារប្រើប្រាស់ ត្រូវមកទិញនៅសេដ្ឋកិច្ចតំបន់១០២ (ម៉ាឡៃ) ដោយមិនអនុញ្ញាតឲ្យមានរកស៊ីលក់ដូរនៅផ្ទះ ឬផ្សារ ឬទិញទំនិញពីប្រទេសថៃទេ ។ ប៉ុន្ដែ ទោះជាមានការហាមឃាត់យ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែលួចទៅទិញទំនិញយកមកលក់ដើម្បីផ្គត់ផ្គង់ជីវភាពដែរ ។ ខ្ញុំបានយកសម្ភារទាំងនោះទៅលាក់នៅក្នុងទឹកស្រះ និងជីកកប់ក្នុងដីកុំឲ្យគេរឹបអូសយក ព្រោះនេះជាទ្រព្យសម្បត្តិរបស់ខ្ញុំដែលខំរកយ៉ាងលំបាក ។ ក្រោយពីមានរឹបបន្តឹងខ្លាំងប្រជាជននៅម៉ាឡៃបានធ្វើការបះបោរ រហូតធ្វើឲ្យអ្នកគ្រប់គ្រងនៅទីនោះសម្រេចចិត្តលែងរឹបអូសទ្រព្យសម្បត្តិឯកជន ។

នៅឆ្នាំ១៩៩៦ តំបន់ម៉ាឡៃ បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ។ ការចុះចូលនេះ បានធ្វើឲ្យប្រជាជននៅម៉ាឡៃរស់នៅក្នុងសុខសន្តិភាព លែងមានសង្គ្រាម និងមានសិទ្ធិសេរីភាពក្នុងការរកស៊ីចិញ្ចឹមគ្រួសារបានយ៉ាងប្រសើរ ។ សព្វថ្ងៃខ្ញុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ការសិក្សារបស់កូនខ្ញុំទាំងបួននាក់ឲ្យបានរៀនដល់មហាវិទ្យាល័យទាំងអស់ ។ **ហ៊ិន សុធានី**

# ដំណឹងស្វែងរកលោក អៀត អ៊ិត

តាមរយៈវេទិការអប់រំសាធារណៈដែលធ្វើឡើងនៅក្នុងភូមិពន្លាក ឃុំចុងចៀក ស្រុកដំបែ ខេត្តកំពង់ចាម ក្រុមការងារបានជួបជាមួយគ្រូបង្គោលថ្នាក់ខេត្តដែលមានឈ្មោះថា ឯក បៀង ដែលបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលគ្រូស្ដីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងជជែកជាមួយម្ដាយរបស់គាត់ដែលមានឈ្មោះថា អៀត ឃន ។ អ៊ំស្រី អៀត ឃន បានប្រាប់ក្រុមការងារយើងពីការបាត់ខ្លួនប្អូនប្រុសតែម្នាក់របស់គាត់តាំងពីឆ្នាំ១៩៧៣ និងការបាត់ខ្លួនរបស់បងស្រីឈ្មោះ អៀត ផន និងកូនបីនាក់របស់គាត់នៅក្នុងរបបប៉ុលពត ។

អ៊ំស្រី អៀត ឃន បាននិយាយថា គាត់មានបងប្អូនបង្កើតប្រាំមួយនាក់ ដែលរួមមានបងស្រីប្រាំនាក់ និងប្អូនប្រុសម្នាក់ ។ បងស្រីធំឈ្មោះ អៀត អ៊ុត ទីពីរឈ្មោះ អៀត អ៊ិន ទីបីនិងទីបួនដែលជាកូនភ្លោះឈ្មោះ អៀត អេង និង អៀត ផន ទីប្រាំគឺគាត់ និងទី៦ អៀត អ៊ិត ។

អ៊ំស្រី អៀត ឃន បានប្រាប់ថា បងស្រីរបស់គាត់ឈ្មោះ អៀត ផន ដែលកើតនៅឆ្នាំ១៩៤៤ និងកូនបីនាក់របស់គាត់ត្រូវអង្គការយកទៅអប់រំនៅក្នុងរបប ប៉ុល ពត ប៉ុន្ដែមិនដែលឃើញមកវិញទេ ។ គ្រួសាររបស់អ៊ំស្រី អៀត ឃន ជឿថា ផន និងកូនៗរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ទៅហើយពីព្រោះឪពុកក្មេករបស់គាត់គឺជាចៅហ្វាយស្រុកនៅក្នុងរបប លន់ នល់ ។

ចំពោះ អៀត អ៊ិត ដែលជាប្អូនប្រុសពៅ និងជាកូនប្រុសតែម្នាក់បានចាកចេញពីផ្ទះនៅអាយុ១៧ឆ្នាំទៅបម្រើទ័ព លន់

នល់ ។ អ៊ិត បានមកលេងផ្ទះពីរដង ។ លើក ទីមួយ គាត់បានមកផ្ទះដោយដៃរបស់គាត់ត្រូវរបួស ហើយគាត់បានសុំប្រាក់ អ៊ំស្រី អៀត យន ចំនួន៣០០០រៀលដើម្បីឲ្យថ្លៃព្យាបាលទៅគ្រូពេទ្យព្យាបាលតាមវិធីបុរាណ ។ អ៊ំស្រី យន បាននិយាយថា ការព្យាបាលត្រូវចំណាយអស់២០០០រៀល ហើយ អ៊ិត បានយក១០០០រៀល ដែលនៅសល់ទៅទិញសម្លៀកបំពាក់នៅស្វាយរៀងឲ្យគាត់ ។ លើកទីពីរដែល អ៊ិត មកផ្ទះ គាត់បានសុំលុយអ៊ំស្រី យន ម្តងទៀត ។ អ៊ំស្រី យន បានឲ្យប្រាក់គាត់ចំនួន ១០០០រៀល ពីព្រោះការប្រើប្រាស់ប្រាក់នៅទីនោះបានបិទ ទោះបីជានៅស្វាយរៀងប្រហែលជាមានការប្រើប្រាស់ប្រាក់ខ្លះក៏ដោយ ។ នៅពេលនោះ អ៊ិត មានអាយុ២២ឆ្នាំ ។ ចាប់ពីពេលនោះមក គ្រួសារទាំងអស់មិនដែលជួបគាត់ម្តងទៀតទេ ។

នៅពេលដែល អ៊ិត មកលេងផ្ទះ គាត់បានទៅហាងថតរូបដើម្បីថតជាមួយមិត្តភក្តិរបស់គាត់ ។ ក្មួយប្រុសរបស់គាត់ដែលមានឈ្មោះ ឡាយ អាន ដែលមានអាយុ១០ឆ្នាំ និងត្រូវជាកូនប្រុសច្បងរបស់អ៊ំស្រី យន និងបងរបស់ ឯក ប៊ីង បានទៅហាងថតរូបនៅភូមិស៊ីង ឃុំស៊ីង ស្រុកពញាក្រែកជាមួយគាត់ ។

អ៊ំស្រី យន បានរៀបរាប់ថា ឪពុករបស់គាត់ប្រាប់ឲ្យគាត់ទៅរកគ្រូទាយ ហើយគាត់ក៏បានទៅរកគ្រូទាយបីនាក់ផ្សេងគ្នាដែរ ។ គ្រូទាយបានសួរនាំពីព័ត៌មានទាក់ទងនឹងការបាត់ខ្លួនរបស់ អ៊ិត ដូចជាឈ្មោះនិងកិនភាគ ហើយពេលខ្លះចាប់ផ្តើមទស្សទាយទៅតាមអាយុនិងថ្ងៃខែឆ្នាំកំណើត និងមើលបាតដៃរបស់គាត់ ។

អ៊ំស្រី អៀត យន សង្ឃឹមថាគាត់អាចជួបប្អូនគាត់ម្តងទៀត ។ គាត់សង្ឃឹមថា ប្អូនរបស់គាត់នៅរស់ ហើយត្រឡប់មកផ្ទះវិញ ពីព្រោះគាត់បានទៅរកគ្រូទាយជាច្រើន ហើយគ្រូទាយទាំងនោះបាននិយាយថាជើងលេខរបស់ប្អូនគាត់វិជ្ជមាន គាត់នឹងត្រឡប់មកវិញនៅរដូវរំហើយ ។

ព័ត៌មានខាងលើគឺជាព័ត៌មានសម្រាប់ឲ្យបងប្អូន មិត្តភក្តិ និងអ្នកអានទស្សនាវដ្តី ស្វែងរកការពិត ជួយស្វែងរកប្អូនរបស់ អ៊ំស្រី យន គឺ អៀត អ៊ិត ។ បើបងប្អូនណាដឹង ឬមានព័ត៌មានពី អៀត អ៊ិត សូមទាក់ទងអ៊ំស្រី អៀត យន ដែលរស់នៅនៅក្នុងភូមិពន្លាក ឃុំចុងចៀក ស្រុកដំបែ ខេត្តកំពង់ចាម ឬសូមទាក់ទង ឯក បៀង ដែលជាកូនប្រុសរបស់អ៊ំស្រី អៀត យន និងដែលជាគ្រូប្រវត្តិសាស្ត្រនៅក្នុងវិទ្យាល័យនៅក្នុងឃុំតាមលេខរយៈទូរស័ព្ទលេខ ០៩២ ៥៥០ ៩០៥ ឬទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ឌើ សាយ្យាណា**



រូបពីឆ្វេងទៅស្តាំ អៀត អ៊ិត, ក្មួយប្រុស ឡាយ អាន, ច្រឹង និង ប៊ុន

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមក ហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុ ផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 137, May 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.